# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ២៧ ខែមីនា លេខ ៣

ព.ស. ២៤៩៧ – គ.ស. ១៩៥៥

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ


## បញ្ជីរឿង

ទំព័រ

### ផ្នែកសាសនា


— វិចារណកថា ................ លោក ជាប - ពិន ......... ១៦៣

— ភជវិសតិកថា ................ ព្រះអាចារ្យ ហែន . ធឿង .... ១៦៩

— វិរុទ្ធវត្តកថា ................ ព្រះវិភទ្ធញាណ សោម-ឡុច .. ១៧៩

— បញ្ញាសជាតក ភាគទី ៣ (តមក) .... បណ្ឌិតមហា ឈឹម -ស៊ុម .... ១៨៥


### ផ្នែកអក្សរសាស្ត្រ


— រឿងសៅរសោយ (តមក) ........ ព្រះមហាឧត្តមវិជ្ជា ប៊ុង—ប៉ម ... ២០៣

— អនុស្សាវរីយ៍ ចំពោះព្រះបាទសម្តេច
ព្រះនរោត្តម-សីហនុ វរ្ម័ន ........... លោក អ៊ុង - ស៊ុមន៍ ......... ២១២

— រឿងសាមកុក (តមក) .......... ឧកញ៉ា នូ- កន ......... ២១៦

— ដំណឹងតាមខ្យល់ក្នុងកន្តារៈ (តមក) ... លោក ផេង - ជ្រីវ ......... ២២២

— រឿងបល្ល័ង្កទិព្យ (តមក) .......... លោក ភ៉ាយ- ប៊ុក ........ ២២៩


### កំណត់ទីនប្រវត្តិការណ៍


— ពិធីបុណ្យស្រោចទឹកចំរើនព្រះជន្មសម្តេច
ព្រះសុគន្ធាធិបតី អ៊ុង-ស្រី សង្ឃនាយក
គណៈធម្មយុត្តិ ............... អាចារ្យវត្តបទុមវតី ........ ២៣៥

—បញ្ជីភាយនាមចៅអធិការដែលតាំងថ្មី (តមក) ក្រសួងធម្មការ .......... ២៣៩



មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ២១០រ.០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

## TABLE DES MATIÈRES


PARTIE RELIGIEUSE: Page

Editorial . . . . . . . . . . *M. CHAP-PIN* . . . . . . . . 163
– Rajavasatikåtha.. . . . . . . *Vén. HEN-THŒUNG* . . . . 169
— Viruddhavatthukatha . . . . *Vén. SOM-LOCH* . . . . . 179
— Pannasajataka- vol.3 (suite) . *M. CHHIM-SOUM* . . . . . . 185

PARTIE LITTERAIRE:

— Le «SAU SOY» ou l'influence saturnienne (suite) . . . . . *Vén. PEUNG-PAM* . . . . . . 203
— Souvenirs du Roi Norodom Sihanouk . . . . . . . . . *M. OUNG-SOUM* . . . . . . 212
— Histoire de samkok (suite). . *Oknha NCU-KAN* . . . . . . 216
— Le souffle du désert (suite) . . *M. PHENG-CHRIV* . . . . . 222
— Les trente deux récits du Trône (suite) . . . . . . . . *M. RAY-BUC* . . . . . . . . 229

NOTES ET CHRONIQUES:

— Cérémonie du bain religieux de S. E le Chef de la secte Dammayutti . . . . . . . . *Achar vat Botoum-vaddey* . . 235
— Nomination des nouveaux Chau-Adhikars (suite) . . . . . . . *Ministère des Cultes* . . . 239


Prix d'abonnement annuel (comprenant 12 numéros) 210$00

# វិចារណកថា

## ជីវភាពពលរដ្ឋឯករាជ្យ

លោក ចាប - ពិន រៀបរៀង

សម័យនេះ ប្រទេសខ្មែរបានផ្លាស់ស្ថានភាពជាប្រទេសឯករាជ្យបរិបូណ៌ រួចរំដោះចាកនឹមអាណានិគមហើយ, តែប្រជាជនខ្មែរមិនទាន់ផ្លាស់ជីវភាពរបស់ខ្លួន ឲ្យសមជាពលរដ្ឋប្រទេសឯករាជ្យពេញទីនៅឡើយ ។

កាលប្រទេសខ្មែរនៅក្នុងនឹមអាណានិគម, ខ្មែរយើងបណ្ដែតជីវភាពរបស់ខ្លួនទៅតាមតែគេជាអាណាព្យាបាល, វេលានេះឯករាជ្យពេញលេញដូចសព្វថ្ងៃ, ខ្មែរយើងមិនគប្បីបណ្ដែតជីវភាពដូច្នោះទៀតទេ គប្បីតែរង្កៀកខ្លួនរើខ្លួនឲ្យផុតចាកជីវភាពសម័យអាណានិគម; គួរនាដូចជនជាបាវព្រាវគេ ឬកូនចៅនៅក្នុងបន្ទុកម្ដាយឪពុក តែងតែបណ្ដែតខ្លួនទៅតាមសេចក្ដីដឹកនាំរបស់ចៅហ្វាយនាយឬមេបាគ្រួសារ, ប៉ុន្ដែលុះគេបានរួចខ្លួនជាអ្នកជាឬជាអ្នកមានភរិយាស្វាមី ជាមេបាគ្រួសារ តាំងខ្លួនផ្ទាល់ខ្លួនឯងកាលណា គេមិនត្រូវបណ្ដែតបណ្ដោយខ្លួនដូច្នោះទៀតទេ, គេត្រូវតែតាំងខ្លួនគេជាដកាប ហើយគេត្រូវតែផ្លាស់ជីវភាពរបស់ខ្លួន ទៅតាមឋានៈជាអ្នកជា ជាមេបាគ្រួសារ តាំងខ្លួនឲ្យមានជំហររឹងប៉ឹងឡើង ។

ពួកទេសចរ (អ្នកដើរពិនិត្យមើលប្រទេស) កាលគេចូលប្រទេសណា គេឃើញតែផ្ទះសម្បែងរបស់ប្រជាជន ដែលទុកជាស្រោមខាងក្រៅ

របស់រដ្ឋ ហើយនឹងឃើញតែសម្លៀកបំពាក់ឫកពាអាកប្បកិរិយារបស់ប្រជាជន ដែលទុកជាស្រោមខាងក្រៅរបស់ពលរដ្ឋ ក្នុងប្រទេសនោះ គេអាចទាយបានភ្លាមថាជាប្រទេសចំរើន ឬមិនចំរើន ដោយសារសំបកក្រៅរបស់ប្រទេសនោះឯងសំដែងប្រាប់ឲ្យគេស្គាល់បាន ។

ដូច្នេះ, នៅវេលាដែលប្រទេសខ្មែរបានឯករាជ្យពេញទី អាចគ្រប់គ្រងខ្លួនដោយខ្លួនឯងដូចសព្វថ្ងៃនេះ, ប្រជាជនខ្មែរត្រូវតែប្រយ័ត្នរឿងសំបកក្រៅឲ្យមែនទែន ហើយត្រូវតែប្រញាប់អប់រំខ្លួនឲ្យបានជាអារ្យជន ដោយស្រុះគ្នារៀបចំសម្លៀកបំពាក់ ព្រមទាំងឫកពានឹងការបេះដឹងរបស់ខ្លួន ដែលជាស្រោមរបស់ឯករាជ្យឲ្យល្អ ឲ្យរៀបរយ ឲ្យសមរម្យតាមអារ្យធម៌របស់ប្រទេសឯករាជ្យ ដូចបរិយាយគោលៗ តទៅនេះ :

សំលៀកបំពាក់ចាត់ជា ៣ សម្រាប់ គឺ

១– សម្រាប់នៅផ្ទះ;

២– សម្រាប់ចេញក្រៅ;

៣– សម្រាប់ចូលកាន់ទីប្រជុំ ។

វេលានៅក្នុងផ្ទះ ឬនៅក្នុងភូមិរបស់ខ្លួន ជាធម្មតា ទោះបីស្លៀកពាក់យ៉ាងណាក៏បាន តាមចូលចិត្ត តាមមានតាមបាន ឲ្យតែសមរម្យ កុំឲ្យតែជោកទាបពេក, តែបើម្ចាស់ផ្ទះជាសុភាពបុរសកំពុងធ្វើការអ្វីនៅផ្ទះ ដោយស្លៀកតែខោ ឬសារុងមិនពាក់អាវ ហើយបើមានភ្ញៀវមករក ត្រូវយកអាវទ្រនាប់មកពាក់សិន សឹមអង្គុយសំណេះសំណាលនឹងភ្ញៀវ ទើបថ្លៃថ្នូរពេញជាម្ចាស់ផ្ទះដ៏មានសេរី ។

សម្លៀកបំពាក់មិនល្អ នាំអ្នកស្លៀកពាក់ឲ្យថោកទាបឲ្យអ្នកផង មើលងាយ, សម្លៀកបំពាក់ល្អឲ្យថ្លៃថ្នូរ ឲ្យគេញញើត, បើស្លៀកពាក់ល្អ ហើយអ្នកស្លៀកពាក់ចេះរៀបចុកពាអាកប្បកិរិយាឲ្យថ្លៃថ្នូរផង ទៀតក៏រឹតតែនាំឲ្យគេសំគាល់ថាជាមនុស្សចំណាប់ចំនួនថែមឡើង សម ជាពលរដ្ឋខ្មែរឯករាជ្យមានអារ្យធម៌ខ្ពង់ខ្ពស់មែន ។

ការស្លៀកពាក់ល្អនិងមិនល្អឲ្យលទ្ធផលផ្ទុយគ្នាស្រឡះ ដូចមាន ឧទាហរណ៍តទៅនេះ :

ថ្ងៃមួយ, នៅក្រុងភ្នំពេញមានអ្នកមានមុខមានមាត់ម្នាក់ស្លៀកក្រមា ពញាក់ចាស់ពត្ញក់ មិនពាក់អាវ មិនសិតសក់ នៅធ្វើការក្នុងភូមិរបស់ ខ្លួន ។ ចួនជាពេលនោះ មានបុរសម្នាក់ដើរមករកការធ្វើ, ដោយ សំគាល់ថា ជាគូលីផ្ទះនោះ, បុរសនោះ ក៏សួរថា "ពូ! ម្ចាស់ផ្ទះនេះត្រូវការគូលីម្នាក់ទៀតទេ?" ។ អ្នកនោះប្រាប់ថា "ចាំសួរលោកឲ្យ, ១ ម៉ោងទៀតទើបដឹងការ" ។ ក្រោយបុរសនោះចេញទៅ, អ្នកនោះ ងូតទឹកសិតសក់ស្លៀកពាក់ស្អាតបាត រៀបចំបុកពាស្រួលបួល ។ បុរស នោះមកវិញ ឃើញរូបដែលស្លៀកពាក់ល្អ ក៏ត្រឡប់ជាហៅថា "ព្រះតេជព្រះគុណ !" ... ។

នេះជាលទ្ធផលនៃការស្លៀកពាក់អាក្រក់ - ល្អ ដែលជាគ្រឿងធ្វើ ឋានៈមនុស្សឲ្យទាបខ្ពស់ខុសគ្នា, ត្រូវតាមសុភាសិត ១ បទថា "មាន់ល្អ ព្រោះរោម, រូបឆោមល្អព្រោះតែង", ដែលបានសេចក្ដីថា: ប្រទេស

ចំរើនរុងរឿងពីព្រោះពលរដ្ឋមានសម្លៀកបំពាក់ល្អនិងឫកពាថ្លៃថ្នូរ សុភាព រាបសារ ប្រាជ្ញាឈ្លាសវៃ ។

វេលាចេញក្រៅភូមិ, គប្បីប្រើសម្លៀកបំពាក់ដែលបោកអ៊ុតមានផ្ទត់ល្អ កុំចេញទៅឆ្ងាយទាំងស្លៀកសារុង ឬទាំងស្លៀកតែខោឥតពាក់អាវ ព្រោះជាការស៊ិសពុំគួរសមសៀបប្រៀបណាស់ នាំឲ្យថោកទាបជាតិ ឲ្យជនបរទេសមាក់ងាយ ។

នៅទីក្រុងធំៗ ក្នុងប្រទេសយើង មានក្រុងភ្នំពេញជាដើម តែងតែមានការប្រជុំធំៗ រឿយៗ. នៅពេលប្រជុំម្តងៗ តែងតែមានមនុស្សច្រើនហើយច្រើនជាតិផងដែលកាត់មកពីទីផ្សេងៗ; ពួនកាលមានទេសចរដែលមិនធ្លាប់ស្គាល់ប្រទេសខ្មែរសោះមកក្នុងទីនោះផងទៀត ។ ដូច្នេះ, ដើម្បីឲ្យរុងរឿងប្រទេសខ្មែរ ប្រជាជនជាតិខ្មែរទាំងបុរសទាំងស្ត្រី គប្បីប្រើសម្លៀកបំពាក់ប្រកបដោយព័ណ៌ផ្សេងៗ មានព័ណ៌សជាដើម ទាំងអស់គ្នា; យ៉ាងហោចណាស់ត្រឹមខោខ្មៅ ឬសំពត់ខ្មៅ អាវស កុំគប្បីប្រើសម្លៀកបំពាក់ខ្មៅស្លុះដែលមើលទៅឃើញខ្មៅងឹតដូចយប់ ឬដូចហ្វូងក្អែក; នាំឲ្យស្រអាប់ឯកភាពខ្មែរ ។ មួយទៀត បើមានកិច្ចទៅហែអ្វី ឬទៅមើលពិធីអ្វី កុំគប្បីស្លៀកក្រមាពាក់លែងខ្លួនវែលឈរនុបដៃ ឬអង្គុយត្រះបោមក្បាលដង្គង់នៅចំណោមថ្នល់ នាំឲ្យថោកទាបអារ្យធម៌ខ្មែរក្រៃពេក, ប៉ុន្តែ ទោះបីស្លៀកពាក់ល្អត្រឹមត្រូវហើយ បើមិនរៀបឫកពាឲ្យថ្លៃថ្នូរផងទេ ក៏នៅតែមិនរុងរឿងទៀត; ព្រោះហេតុនេះ សូមបញ្ជាក់ថា

លក្ខណៈដែលប្រជាជនខ្មែរត្រូវរៀបចំខ្លួន ឲ្យសមជាពលរដ្ឋនៃរដ្ឋឯករាជ្យនោះ និយាយដោយបំព្រួញមាន ៣ យ៉ាង គឺ

១ – ត្រូវរៀបចំសម្លៀកបំពាក់ឲ្យល្អតាមថ្នាក់ តាមពេល ដូចពណ៌នាមកហើយ;

២ – ត្រូវរៀបចំអាកប្បកិរិយាបុគ្គលឲ្យថ្លៃថ្នូរ ស្វាហាប់ សណ្ដាប់ធ្នាប់ ចំណាប់ចំនួន, កុំធ្វើព្រួយៗ ព្រួនៗ ដែលនាំឲ្យជនបរទេសមើលងាយ, ប៉ុន្តែកុំឲ្យក្លាយទៅជាព្រហើនកោងកាច ហើយនឹងកុំបរិភោគស្រា ឬទឹកត្នោតជូរ និយាយប៉ប៉ាច់ប៉ប៉ូច ឡូឡា ស៊ើយឈាត់ តាមតៀមស្រា តាមផ្សារផ្សា ឬតាមចិញ្ចើមថ្នល់ ដែលនាំឲ្យជនបរទេសថ្កោលមារយាទខ្មែរ;

៣ – ត្រូវខំស្វែងរកការចេះដឹងនិងរៀបចំចិត្តគំនិតឲ្យក្លៀវក្លា ក្លាហាន រឹងប៉ឹង ម៉ឺងម៉ាត់ ដោយសំដែងអាការកិរិយា ឧស្សាហ៍ ស្រក់ស្រទេញ រហ័សរហួន ចង់មានចង់បាន កុំបំអៀក ទម្រន់ ទន់ខ្សោយ ។

កាលបើប្រទេសខ្មែរផ្លាស់ស្ថានភាព ជាប្រទេសឯករាជ្យពេញទីហើយ, ប្រជាជនខ្មែរត្រូវតែប្រញាប់ប្រញាល់ផ្លាស់ជីវភាពរបស់ខ្លួនរៀងខ្លួនឲ្យបានជាការប្រជន ដោយប្រកបតាមលក្ខណៈ ៣ យ៉ាងដូចពោលមក ដោយសង្ខេបខាងលើនេះ ទើបសមជាពលរដ្ឋឯករាជ្យពេញទី ។

ឯករាជ្យពេញទីនៃប្រទេសកម្ពុជា ជាកម្លាំងដ៏ធំមួយចំពោះព្រះពុទ្ធសាសនា ជាសាសនាសម្រាប់ខេមរជាតិក្នុងកម្ពុជរដ្ឋ ដែលរដ្ឋធម្មនុញ្ញប្រទេសកម្ពុជាបានធានាអះអាងថា ជាសាសនារបស់រដ្ឋ ។

យើងសូមប្រសិទ្ធពរឲ្យកម្លាំងនេះ បានចំរើនឡើង ទនឹងរឹងប៉ឹង មាំមួនតទៅ ដើម្បីឧបត្ថម្ភត្រៃសរណដ្ឋាន គឺជាតិ សាសនា មហាក្សត្រ ឲ្យបានថ្កើងរុងរឿងជាកិយោភាព រហូតកល្បាវសាន !

## និគមវិបន:

គ្រឹះស្ថានស្រោមរដ្ឋប្រាកដជាក់ សម្លៀកបំពាក់ស្រោមពលរដ្ឋ
ជនខ្មែរគួរតែឲ្យហ្មត់ចត់ ដើម្បីឲ្យរដ្ឋបានចំរើន ៗ
ឲ្យសមតាមភាពរដ្ឋឯករាជ្យ ឲ្យមានអំណាចប្រសើរឡើង
កសាងប្រទេសជាតិខ្មែរយើង ឲ្យល្អឲ្យថ្កើងទាន់សម័យ !

បាប-ពិន

# ផ្នែកសាសនា

## រាជវសតិកថា

ព្រះអាចារ្យ ហោង - ធឿង វត្តមហាមន្ត្រី
រៀបរៀង

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្ការចំពោះព្រះភគវន្តមុនី អរហំសម្មាសម្ពុទ្ធ ព្រះអង្គនោះ (ព្រមទាំងព្រះធម៌ នឹងព្រះអរិយសង្ឃ ដោយសេចក្ដីគោរព) ។

ក្នុងឱកាសនេះ អាត្មាភាពសូមសំដែងអំពី "រាជវសតិកថា" ជាឱវាទរបស់សម្ដេចព្រះបរមសាស្ដា ដើម្បីជាផ្លូវចំរើនក្នុងការសិក្សានៃពុទ្ធសាសនិកជន តាមគោលនៃព្រះពុទ្ធភាសិតដែលមានក្នុងមហានិបាតជាតក ខុទ្ទកនិកាយ ដូចបទនិពន្ធគាថាយ៉ាងនេះថា:

ឧដ្ឋាតា កម្មធេយ្យេសុ អប្បមត្តោ វិចក្ខណោ
សុសំវិហិតកម្មន្តា ស រាជវសតឹ វសេ

ប្រែថា: បុគ្គលអ្នកប្រឹងប្រែងក្នុងការងារ ជាអ្នកមិនប្រមាទ មានបញ្ញាឃើញប្រចក្ស ចាត់ចែងការងារបានរៀបរយ បុគ្គលនោះគប្បីតាំងនៅក្នុងរាជការបាន" ។

ព្រះពុទ្ធភាសិតនេះសរសើរថា អ្នកដែលអាចតាំងនៅក្នុងវង្ស រាជការបាន ដោយគុណធម៌ ៤ ប្រការ ដែលហៅថា រាជវសតិ :

១ - ជាអ្នកប្រឹងប្រែងតស៊ូក្នុងការងារ ;

២ - ជាអ្នកមិនប្រមាទធ្វេសប្រហែស ប្រាសចាកសេចក្ដីខ្ជិលច្រអូសក្នុងមុខក្រសួង;

៣ - ជាអ្នកមានបញ្ញាពិចារណា គិតគូរមើលសេចក្ដីចំរើន-វិនាសក្នុងការងារ;

៤ - ជាអ្នកចាត់ចែងការងារឲ្យមានរបៀបរៀបរយ មិនច្របូកច្របល់ ។

ដូចអធិប្បាយតទៅនេះ ៖

ការប្រឹងប្រែងតស៊ូព្យាយាមក្នុងករណីយកិច្ចគ្រប់ប្រការ ចាត់ថាជាគុណសម្បត្តិសំខាន់យ៉ាងក្រៃលែង អាចធ្វើឲ្យអ្នកប្រកបដល់នូវសន្តិសុខនិងបរមសុខបាន ។ ការងារទាំងឡាយមានការរកស៊ីចិញ្ចឹមជីវិតដោយប្រក្រតី ដូចជាកសិកម្ម, វាណិជកម្ម, វេជ្ជកម្ម, ទេសាហកម្ម, ហត្ថកម្ម, និងការសិក្សាអក្សរសាស្ត្រ, លេខសាស្ត្រ, ប្រវត្តិសាស្ត្រ, សាសនសាស្ត្រ, វិទ្យាសាស្ត្រ, តក្កសាស្ត្រជាដើម រហូតដល់កិច្ចការជាមុខក្រសួងរបស់ខ្លួន ដែលចាត់ថាជាករណីយកិច្ចត្រឹមត្រូវ ក៏សុទ្ធតែត្រូវអាស្រ័យសេចក្ដីព្យាយាមជួយដឹកនាំគាំទ្រផង, សមដោយនិពន្ធពុទ្ធភាសិតថា: ឧដ្ឋាតា វិន្ទតេ ធនំ "អ្នកមានសេចក្ដីព្យាយាមរមែងបានទ្រព្យសម្បត្តិ" ។ មនុស្សដែលមានទ្រព្យសម្បត្តិស្ដុកស្ដម្ភ តែងបានសេចក្ដីសុខ ។ ការដែលមានភោគសម្បទ ក៏ដោយអាស្រ័យសេចក្ដីព្យាយាមលះកាត់សេចក្ដីសុខបន្តិចបន្តួចបរយកសេចក្ដីសុខធំ ទាត់ចោលសេចក្ដី

ខ្ជិលប្រអូស ព្រោះសេចក្ដីខ្ជិលប្រអូស រមែងធ្វើអាការដូចមិត្តឲ្យសេចក្ដីសុខក្នុងខាងដើម លួងលោមបុគ្គលល្ងង់ឲ្យលង់លិច ពេលមកខាងក្រោយផ្ដល់សេចក្ដីទុក្ខឲ្យមិនមានទីបំផុត; ឯសេចក្ដីព្យាយាមនោះ រមែងធ្វើអាការដូចជាសត្រូវ ឲ្យសេចក្ដីលំបាកក្នុងខាងដើម តែពេលខាងក្រោយត្រឡប់ទៅជាមហាមិត្ត អាចជូនសេចក្ដីសុខយ៉ាងធំរកទីបំផុតគ្មាន ហេតុនេះសេចក្ដីខ្ជិលប្រអូសជាគ្រឿងកសាងសេចក្ដីទុក្ខ ការព្យាយាមជាគ្រឿងផ្សាំបណ្ដុះសេចក្ដីសុខ ។ បុគ្គលដែលឆ្លងសេចក្ដីទុក្ខបាន ក៏ព្រោះការព្យាយាម, បើគេធុញទ្រាន់នឹងការព្យាយាមដោយឃើញតែសេចក្ដីលំបាកក្នុងករណីយកិច្ចមុនហើយ គេនឹងឆ្លងសេចក្ដីទុក្ខក៏ពុំបាន ដូចជាបុគ្គលចូលលត់ភ្លើងក្នុងពេលដែលឆេះផ្ទះ បើខ្លាចក្ដៅក៏លត់ពុំបាន ។ ពិតណាស់ សេចក្ដីលំបាករមែងកើតជាមួយនឹងការព្យាយាម ព្រោះមនុស្សដែលមានឧបសគ្គក្នុងវេលាធ្វើ បើចុះចាញ់ឧបសគ្គនោះក៏ត្រូវរងទុក្ខវេទនាជាដរាប តែបើយកជ័យជំនះឧបសគ្គនោះបាន សេចក្ដីទុក្ខព្រួយក៏ឃ្លាតចេញពីខ្លួនឯង ។ ការដែលមិនខ្លាចនឿយហត់នេះឯងឈ្មោះថា "វិរិយៈ" ។ ពោលដោយមូលហេតុមាន ២ យ៉ាង គឺកាយនឹងចិត្ត ។ ដែលប្រព្រឹត្តទៅតាមផ្លូវកាយ ហៅថា "កាយិកៈ" តាមផ្លូវចិត្ត ហៅថា "ចេតសិកៈ" ។ ដូច្នេះ វិរិយៈមិនមែនមានក្នុងទីដទៃគឺមានក្នុងកាយនឹងចិត្ត កាយនឹងចិត្តនេះឯងជាទីតាំងនៃការព្យាយាម កាលបើបុគ្គលឃើញច្បាស់យ៉ាងនេះហើយ គួរប្រកបការប្រឹងប្រែងអង់អាចខាងផ្លូវកាយនឹងផ្លូវចិត្ត ដែលធម្មតាគាត់តែងឲ្យមក មិនគួរទុកកាយនឹងចិត្តឲ្យនៅទំនេរឥតប្រយោជន៍ទេ ។

ចំណែកករណីយកិច្ចដែលត្រូវធ្វើដោយផ្លូវកាយនិងចិត្ត ទាំងផ្នែកគតិលោកនិងគតិធម៌ តាំងពីជាន់ទាបរហូតដល់ជាន់ខ្ពស់ សុទ្ធតែត្រូវអាស្រ័យការតស៊ូប្រឹងប្រែងជាគ្រឿងទំនុកបំរុង ទើបអាចសំរេចសមតាមបំណងបាន ។ សេចក្តីព្យាយាមមានកម្លាំង តែងដឹកនាំបុគ្គលអ្នកប្រកបឲ្យប្រសព្វសន្តិសុខទាន់ពេលសម័យ ប្រៀបដូចគ្រឿងចក្រដែលបង្វិលរថយន្ត, អាកាសយាន, កប៉ាល់និងកាណូតឲ្យទៅកាន់មាគ៌ាដ៏ឆ្ងាយបានដោយសុវត្ថិភាព ។ កាលបើបុគ្គលមានព្យាយាមមាំជាគ្រឿងទំនុកបំរុងហើយ នឹងបានជាដើមទុនកកើតផលគឺវរសុខនិងសេរីធម៌ ។ តែករណីយកិច្ចដែលត្រូវធ្វើ និងដើរលឿនទៅដោយសេចក្តីរៀបរយល្អបានដោយអាស្រ័យសេចក្តីមិនប្រមាទ ប្រាសចាកការធ្វេសប្រហែសក្នុងមុខការងាររបស់ខ្លួន ទើបរួចចាកវិបត្តិកាត់ចូលទៅរកសួស្តី ហេតុនេះព្រះទសពលញាណប្រទានអប្បមាទធម៌ជាគុណសម្បត្តិចាត់ទុកក្នុងបទទី ២ ។

សេចក្តីមិនប្រមាទនេះ បានដល់សេចក្តីប្រយ័ត្នមិនធ្វេសប្រហែស មិនភ្លេចភ្លាំង មិនភាន់កាំងទៅក្នុងអារម្មណ៍, បើពោលដោយសេចក្តីបានដល់ការមិនវង្វេងភ្លេចស្មារតី មិនបណ្តោយចិត្តឲ្យដើរទៅតាមសេចក្តីស្រវឹងជ្រុលជ្រប់ ។ សេចក្តីមិនប្រមាទនេះជាទីតាំងនៃគុណប្រយោជន៍ដ៏ធំទូលាយ ទាំងគតិលោកនិងគតិធម៌ គួយ៉ាងដូចអ្នករកស៊ីឈ្នួលទទួលរក្សាចិញ្ចឹមគោក្របីឲ្យគេ កាលបើធ្វេសប្រហែសមិនយកចិត្តទុកដាក់ក្នុងការថែទាំរក្សាសត្វដែលខ្លួនចិញ្ចឹមទេ ហ្វូងសត្វនោះក៏នឹងអន្តរាយ ព្រោះរោគវិបត្តិខ្លះ ព្រោះចោរភ័យខ្លះ រកផលល្អគ្មាន; កាលបើប្រុងប្រយ័ត្ន

មិនបណ្ដែតបណ្ដោយ អន្តរាយបែបនោះក៏មិនមាន ហេតុជាមានខ្លះ ក៏តិចជាងមិនប្រយ័ត្ន ។ ឯអ្នកគ្រប់គ្រងផ្ទះ បើមិនអើពើក្នុងការរាំងមើលគេហស្ថាន មិនរាំងទ្រព្យសម្បត្តិបណ្ដោយឲ្យការងារច្របូកច្របល់គ្នា ភោគសម្បទដែលមិនទាន់កើតក៏មិនកើត ដែលកើតហើយក៏វិនាសបាត់ទៅ នឹងទៅជាចន្លោះបើកឲ្យចោរចូលលុកលុយយកសម្បត្តិទ្រព្យបានទៀត ។ ចំណែករាជបុរសអ្នកបដិបត្តិរាជការ បើធ្វេសប្រហែសមិនប្រយ័ត្នក្នុងមុខការរបស់ខ្លួន ក៏រមែងមិនរួចពីកំហុស ។ កាលបើមានចិត្តស្វាមីភក្តិក្នុងករណីយកិច្ចរបស់ខ្លួន មិនមានសេចក្ដីប្រមាទ ទើបបានជាអ្នកចំរើនក្នុងកិច្ចការទៅតាមលំដាប់ ។ ឯអ្នកជាប្រធានរបស់គណៈវង្សត្រកូល បើមិនប្រយ័ត្នថែទាំយកចិត្តទុកដាក់ក្នុងនាទីរបស់ខ្លួន មិនបីបាច់រក្សាទំនុកបំរុងនូវអន្តោជននឹងពាហិរជនដោយធម្មិកោបាយទេ អន្តរាយនឹងកើតឡើងដល់គណៈត្រកូលវង្ស មិនបានចំរើនមាំមួនទៅតាមផ្លូវល្អ ពួកជនពាលនឹងបានឱកាសបង្កសេចក្ដីរំខាន ហេដ្ឋិមជនក៏នឹងបានសេចក្ដីទុក្ខក្ដៅក្រហាយ មិនមានសេចក្ដីស្ងប់ងាសុខ; កាលបើតាំងចិត្តថែទាំរក្សាទំនុកបំរុងដោយសេចក្ដីមិនប្រមាទ ទើបអាចកំចាត់ទោសភ័យ-វិបត្តិ បានសម្រេចសេចក្ដីសុខ-សួស្ដីដ៏ធំទូលាយ ។ ចំណែកអ្នកត្រូវការខាងផ្លូវធម៌ បំពេញកុសលចរិយាវត្ត រក្សាគ្រាក់ទុកនូវសតិមិនឲ្យសេចក្ដីប្រមាទលុកលុយ ទើបអាចហាមឃាត់អកុសលដែលមិនទាន់កើតមិនឲ្យកើតឡើង ធ្វើកុសលដែលកើតឡើងហើយ ឲ្យរឹតតែចំរើនឡើងជាភិយ្យោភាព ជាគោលនៃសន្តិសុខក្នុងព្រះពុទ្ធសាសនា

សមដោយទេសនាន័យ ដែលសម្តេចព្រះសម្ពុទ្ធជាម្ចាស់ត្រាស់សរសើរ សេចក្តីមិនប្រមាទក្នុងធម្មបទ ខុទ្ទកនិកាយថា: "បណ្តាកុសលធម៌ទាំងអស់ សេចក្តីមិនប្រមាទជាធំជាង ដូចស្នាមជើងសត្វទ្វេបាទ ចតុប្បាទ ដែលសញ្ចរលើប្រថពី ស្នាមជើងដំរី ធំជាងស្នាមជើងទាំងអស់" ។ កាលបើបុគ្គលមិនប្រមាទហើយ កុសលធម៌ដែលមិនទាន់កើតនឹងកើតឡើង, ដែលកើតឡើងហើយ ក៏នឹងរឹតតែចំរើនឡើង អ្នកមិនប្រមាទរមែងទាញយកនូវប្រយោជន៍ទាំងពីរផ្លូវបាន គឺ ប្រយោជន៍ក្នុងបច្ចុប្បន្នដែលឃើញជាក់នឹងភ្នែក បានដល់ប្រយោជន៍ក្នុងគតិលោក, ប្រយោជន៍ក្នុងសម្ប-រាយិកគតលោកនាយ បានដល់ប្រយោជន៍គតិធម៌ ឈ្មោះថាអ្នកមានជ័យជំនះទាំងពីរផ្លូវ ឬពោលដោយវោហារថា បានសំរេចសម្បត្តិទាំងពីរយ៉ាងគឺ ភោគសម្បទ បានដល់មាស, ប្រាក់, កែវ, កង ដែលជាគ្រឿងទំនុកបំរុងដល់សាមិសសុខ នឹងគុណសម្បត្តិ បានដល់កុសលធម៌នឹងសេចក្តីបរិសុទ្ធកាយ វាចា-ចិត្ត ដែលជាឧបការដល់និរាមិសសុខ ។ តែសេចក្តីមិនប្រមាទនេះដែលអាចកើតឡើងដល់បុគ្គល ក៏ដោយសារការដូចប្រទះនូវវត្ថុអស់ទៅនឹងសូន្យទៅជាសាក្សី គតិនេះ ទើបអប្បមាទធម៌កើតចំរើនឡើង ដូចបុគ្គលអ្នកឃើញការវិនាសទៅនឹងសូន្យទៅនៃភោគសម្បទ រមែងជាមូលហេតុមិនឲ្យប្រមាទក្នុងការស្វែងរកភោគទ្រព្យ មិនឲ្យប្រមាទក្នុងការបរិហាររក្សាទ្រព្យ មិនប្រមាទក្នុងការចាយវាយទ្រព្យ ។ កាលបើឃើញការសាបសូន្យចាកយស ជាមូលហេតុឲ្យប្រយ័ត្នរក្សាក្នុងករណីយ៍ផ្សេងៗ ហេតុនេះ អប្បមាទធម៌ជាគុណសម្បត្តិ របស់

បុគ្គលអ្នកត្រូវការចំរើនគុណភាពវិសេស គួរអប់រំឲ្យកើតមានគុណសន្តាន របស់ខ្លួន ជាថ្នាក់ទី ២ ។ តែថាបើខ្វះបញ្ញាជាគ្រឿងពិចារណាលៃលក មើលសេចក្តីវិនាសទៅនឹងសួស្តីទៅនៃកិច្ចការ ក៏ជាហេតុឲ្យការងារដែលខ្លួនធ្វើឲ្យប្រព្រឹត្តទៅដោយលំបាក មិនមានរបៀបរៀបរយ បើមានបញ្ញាជាគុណជាតិខ្ពង់ខ្ពស់ចូលអែបនៃបផង នឹងត្រិះរិះឬពិចារណា ឬក៏នឹងធ្វើអ្វី ៗ បានមិនទើសទាក់ ហេតុនេះទើបទ្រង់ត្រាស់ថា បញ្ញា ជាគុណ-សម្បត្តិថ្នាក់ ៣ ។

ប្រាជ្ញដែលស្គាល់ច្បាស់ហេតុផល ឈ្មោះថា បញ្ញា ។ គុណសម្បត្តិនេះល្អទាំងគតិលោកនឹងគតិធម៌ ព្រោះថាសត្វក្តីទាំងចំណែកល្អឬអាក្រក់ រមែងជាហេតុឲ្យផលគួគ្នា ហេតុល្អឲ្យសម្រេចផលល្អ ហេតុអាក្រក់ឲ្យសម្រេចផលក៏អាក្រក់ ហេតុនៃសេចក្តីសុខឲ្យសម្រេចផលក៏ជាសុខ ហេតុនៃសេចក្តីទុក្ខឲ្យសម្រេចផលក៏ជាទុក្ខ ធម្មជាតិទាំងអស់សុទ្ធតែមានហេតុផលជាគូ ៗ គ្នា មិនផ្លាស់ប្តូរទៅរកធម្មជាតិដទៃឡើយ ហេតុនៅមានត្រឹមណាផលក៏នៅមានត្រឹមនោះ កាលបើអស់ហេតុទើបផលរលត់ ។ អ្នកមានបញ្ញាដឹងច្បាស់ហេតុផល តាមគន្លងវិជ្ជាធម៌ បានឈ្មោះថា អ្នកស្គាល់ហេតុស្គាល់ផល, និស្ស័យចិត្តគំនិតរបស់បុគ្គលនោះ រមែងភ្លឺស្វាង ព្រោះពន្លឺគឺបញ្ញា បណ្តេញបោលនូវងងឹតគឺអវិជ្ជា មិនឲ្យមានឱកាសរួបរិតចូលមកព័ទ្ធព័ន្ធបាន ។ ព្រះអាទិត្យព្រះចន្ទមានដួងប្រទីបបញ្ចេញពន្លឺច្បាស់ដល់ចក្ខុរបស់សត្វយ៉ាងណា បញ្ញាក៏បញ្ចាំងពន្លឺឲ្យធ្លុះចេញក្នុងចិត្តគំនិតបានដូច្នោះ, លោកនឹងរុងរឿងផ្លូវទូលាយបាន ក៏ព្រោះតែអាស្រ័យ

បុគ្គលអ្នកមានប្រាជ្ញាដឹងផ្លូវហាយនធម៌ វឌ្ឍនធម៌ច្បាស់ ប្រកបដោយជាគ្រឿងលុបលាងសេចក្ដីវិនាសចោលចេញ ដើរទៅតាមបដិបទានៃសេចក្ដីចំរើន ៗ ផ្លូវធម៌ក៏ដូចគ្នា បើចិត្តប្រាសចាកបញ្ញា អវិជ្ជាក៏រួបរឹតឲ្យងងឹតចិត្តសន្តានមានតែពេលដែលកករល្អក់មិនមានពេលថ្លា ប្រសិនបើបញ្ញាចូលទៅទំនុកបំរុងផង ក៏ជួយបង្ហាញផ្លូវឲ្យស្គាល់ច្បាស់ធម្មតារបស់ឧប-ស័គ្គបាន កាលបើចិត្តដើរទៅកាន់ផ្លូវត្រូវដូចនេះហើយ អាចទទួលពន្លឺបញ្ញាមកអំពីផលដែលធ្វើខ្លួនឲ្យប្រាកងងឹតបាន ៗ ឯពន្លឺព្រះអាទិត្យព្រះចន្ទមានជួនអាចបញ្ចេញពន្លឺបាន តែក្នុងទីដែលមិនមានវត្ថុបិទបាំង បើមានវត្ថុបិទបាំងក៏ផ្សាយពន្លឺទៅមិនដល់ ចំណែកពន្លឺគឺបញ្ញាទុកណាជាវត្ថុជាឧបស័គ្គយ៉ាងណាក៏ដោយ ក៏អាចភ្លឺធ្លុះទៅរហូតបាន ថែមទាំងជាគុណជាតិមាំមួនផង ព្រោះជាពន្លឺយ៉ាងកំពូល សមដោយពុទ្ធនិពន្ធដែលទ្រង់ត្រាស់ទុកថា នត្ថិ បញ្ញា សមា អាភា "ពន្លឺស្មើដោយបញ្ញាមិនមាន" ៗ បញ្ញាអាចសង្កេតពិចារណារកហេតុដ៏សុខុមល្អិតដែលកំបាំង ឲ្យភ្លឺច្បាស់ប្រាកដឡើង មិនមានពន្លឺដទៃស្មើទឹងជាគ្រឿងដាស់តឿនឲ្យដើរទៅរកផ្លូវត្រូវជាផ្នែកសុចរិត ៗ បុគ្គលមានអាជីពប្រកបដោយបញ្ញា រមែងធ្វើករណីយកិច្ចប្រាសចាកទោសដើម្បីជាសាធារណប្រយោជន៍ដល់សាធារណជន មិនប្រព្រឹត្តលបក្បត់ព្រោះតែឃើញប្រយោជន៍ផ្ទាល់ខ្លួនតែម្យ៉ាង តែងចែករំលែកផ្សព្វផ្សាយជាសាធារណ៍ដល់ជនដទៃ ដោយទឹកមេត្តាចិត្តអាណិតត្រាប្រណី ទាំងនេះ

ក៏ព្រោះអាស្រ័យបញ្ញាជាគ្រឿងទំនុកបំរុង ។ លោកអ្នកដែលគ្រប់គ្រងប្រជុំជនឲ្យជាពួកគណៈឬក្រុមគ្រួសារទៅបាន រាប់តាំងពីត្រកូលមួយ ឬភូមិភាគឡើងទៅ ក៏ព្រោះមានបញ្ញា ស្គាល់ហេតុផល ដឹងជាក់នូវឧបាយជាគ្រឿងការពារសត្រូវ មិនឲ្យមានឱកាសញាំញីបៀតបៀនបាន, មួយទៀតពួកអ្នករាជការទីងបីបាច់ថែរក្សាមាតុភូមិឲ្យដើរទៅដោយសន្តិវិធី ក៏ត្រូវមានបញ្ញាស្គាល់ហេតុ ផល ពិចារណាគិតគូរ រំពឹងមើលឲ្យធ្ងន់ មានគំនិតយ៉ាងសុខុមជុំវិញមិនខ្វះកន្លះ បេះរកឧបាយជាគ្រឿងកែខៃឧបសគ្គផ្សេងៗបាន ហេតុនេះ បញ្ញាទើបរាប់ជាគុណសម្បត្តិ ដែលបុគ្គលអ្នកប្រាថ្នាការចំរើនក្នុងរាជការគួរអប់រំក្នុងជាក់ទី ៣ ។

ទុកណាជាបរិបូណ៌ដោយគុណសម្បត្តិគ្រប់ទាំង ៣ ប្រការនេះហើយ តែកិច្ចការងារនៅច្រងេងច្រងាងច្រទាំងច្រទើសមិនរៀបរយ ក៏រាប់ថាជាអ្នកមានសមត្ថភាពក្នុងការងារមិនទាន់បាន លុះត្រាតែចាត់ចែងការងារឲ្យមានរបៀបរៀបរយ មិនច្របូកច្របល់ ទើបនឹងជួបផ្លូវនៃវឌ្ឍនធម៌ទៅតាមរាជការ ហេតុនេះទើបសម្ដេចព្រះមហាមុនីត្រាស់នូវភាពនៃបុគ្គលអ្នកចាត់ការមានរបៀបរៀបរយទុកក្នុងគុណសម្បត្តិជាក់ទី ៤ ។

ចម្ពាបុគ្គលអ្នកមានករណីយកិច្ច ដែលនឹងត្រូវធ្វើយ៉ាងណាទីមួយ កាលមិនធ្វើតាមកាលសម័យ បណ្ដោយការងារឲ្យសល់ទុកនៅ ឬមិនចាត់ចែងការងារនោះឲ្យមានរបៀបរៀបរយល្អ ការងារនោះហៅថា ច្របូកច្របល់ លោកតិះដៀលថាជាអពមង្គល មិនជាហេតុនាំមកនូវសេចក្ដីចំរើន ។ ចំណែកការងារដែលចាត់ចែងឲ្យមានរបៀបសមតាមកាលសម័យ

មិនបណ្ដោយឲ្យសល់ទុកទាល់តែលើសប្រមាណ កាលបើមានការងារយ៉ាងណាលេចឡើង ក៏ប្រឹងប្រែងតស៊ូការងារនោះឲ្យសម្រេចដោយសួស្ដី មិនបង្អង់ពេលវេលា មិនបណ្ដោយការថ្ងៃនេះឲ្យអាក់ខានទៅដល់ថ្ងៃស្អែក ដែលជាហេតុនាំឲ្យទៀយណាយក្នុងវេលាត្រូវធ្វើ លោកហៅថាការងារមិនច្របូកច្របល់ ជាទីសរសើររបស់បណ្ឌិតជន សមទីងពុទ្ធភាសិតថា: អនាកុលា ច កម្មន្តា ឯតម្មង្គលមុត្តមំ "ការទាំងឡាយដែលមិនច្របូកច្រឡំ ចាត់ជាមង្គលខ្ពស់បំផុត" ។

ហេតុនេះ សាធុជនអ្នកប្រាថ្នាផលគឺសន្តិសុខ-វឌ្ឍនធម៌ សេរីធម៌និងអារ្យធម៌ គួរអប់រំឲ្យនៅក្នុងក្រមនិងសម្មាបតិបត្តិប្រព្រឹត្តតាមគោលនៃបរ-យាត្រៃ សេចក្ដីបដិបត្តិរបស់ពុទ្ធសាវកៈនាមថា 'ពដ់វសតី" គឺសេចក្ដីប្រឹងប្រែងតស៊ូព្យាយាមត្រងមុខក្រសួងនៃការងារមិនរួញរា, មិនបណ្ដោយឲ្យសេចក្ដីប្រមាទចូលគ្របសង្កត់ទាល់តែខូចខាតការងារ, មានបញ្ញាជាគ្រឿងពិចារណាការអស់ទៅនិងសូន្យទៅរបស់ការងារ, ចាត់ចែងការងារឲ្យមានរបៀបរៀបរយមិនប្រទាំងប្រទើសច្រលូកច្រឡំគ្នា ទើបនឹងប្រសព្វផលនៃសន្តិសុខយ៉ាងក្រៃលែង ជាភូមិភាគនៃសេចក្ដីរីករាយក្នុងវង្សនៃរាជការបាន សមនឹងទេសនាជាឱវាទានុសាសនី ដែលព្រះបរមលោកនាថត្រាស់ទុកថា: "អ្នកប្រឹងប្រែងក្នុងការងារ, មិនប្រមាទ, មានបញ្ញាឃើញច្បាស់, ចាត់ចែងការងារឲ្យរៀបរយ អ្នកនោះតប្បីតាំងនៅក្នុងរាជការបាន" ។

អធិប្បាយមកប៉ុណ្ណេះ ក៏សមគួរដល់ពេលវេលានឹងបញ្ចប់ឯវំ ដោយនូវបការយ៉ាងនេះឯង ។

# វិទូវត្ថុកថា

## សំដែងពីវត្ថុដែលប្លែកគ្នាក្នុងត្រៃលោក (១)

ព្រះវិភទ្ទញ្ញាណ សោម-ឡុប រៀបរៀងកាលពីគង់ព្រះជន្មនៅ

---

ត្រៃលោកតែងទ្រទ្រង់វត្ថុមានវិញ្ញាណនិងវត្ថុគ្មានវិញ្ញាណ; វត្ថុមានវិញ្ញាណបានខាងមនុស្ស អមនុស្ស(២) និងសត្វតិរច្ឆាន, វត្ថុគ្មានវិញ្ញាណបានខាង ដី ទឹក ភ្លើង ខ្យល់ ដើមឈើ ស្មៅនិងវល្លិជាដើម, វត្ថុទាំងអស់នេះកើតឡើងតែងប្លែក ៗ គ្នា ។

វត្ថុមានវិញ្ញាណ ដូចពួកមនុស្ស តែងប្លែកគ្នាដោយសម្បុរខ្លះ ប្លែកគ្នាដោយកិនខ្លះ ប្លែកគ្នាដោយទ្រង់ទ្រាយខ្លះ ប្លែកគ្នាដោយឥរិយាបថខ្លះ ប្លែកគ្នាដោយសំឡេងខ្លះ ។

ចំណែកវត្ថុដែលគ្មានវិញ្ញាណ ដូចដើមឈើ ស្មៅ វល្លិ ដី ទឹក ភ្លើង ខ្យល់ ខ្សាច់ ក្រួសនិងថ្ម ទាំងនេះ ក៏ប្លែក ៗ គ្នាមិនដូចគ្នាឡើយ អស់លោកអ្នកទាំងឡាយបានឃើញច្បាស់នឹងភ្នែកគ្រប់គ្នាហើយ ខ្ញុំមិនបាច់ថ្លែងរៀបរាប់ឲ្យពិស្ដារឡើយ ចូរអស់លោក អ្នកទាំងឡាយពិចារណាមើលចុះ វៀរលែងតែស្ថានព្រះនិព្វានចេញ ក្រៅពីស្ថានព្រះនិព្វានហើយ របស់អ្វី ៗ តែងមិនទៀងទាំងអស់ ឥតលោកអ្នកណានឹងគិតត្រូវបាន ព្រោះហេតុនោះ បានជាមានពុទ្ធភាសិតថា "របស់ដែលមិន

---

១ ប្រែថា: លោកទាំងបី គឺ: កាមលោក ១, រូបលោក ១, អរូបលោក ១ ។ ២ សំដៅយក ខ្មោច ប្រេត យក្ស អសុរកាយនិងទេវតា ។

ត្រូវគិត មាន ៤ យ៉ាងគឺ វិស័យព្រះពុទ្ធ ១, វិស័យឈាន ១, ផលកម្ម ១, គិតពីរឿងលោក ១" ។

១— វិស័យព្រះពុទ្ធ: ព្រះសម្ពុទ្ធព្រះអង្គមានព្រះកាយកំពស់ ១៨ ហត្ថ ព្រះអង្គអាចយាងចូលទៅគង់នៅក្នុងគ្រាប់ស្ពៃបាន បើយ៉ាងនេះយើងនឹងគិតថា ព្រះអង្គនិម្មិតព្រះកាយឲ្យតូច ហើយធ្វើគ្រាប់ស្ពៃឲ្យធំឡើង ឬយ៉ាងណា ក៏គិតមិនត្រូវ ព្រោះព្រះកាយព្រះអង្គទំហំប៉ុន្មាន ក៏នៅប៉ុណ្ណោះដដែល គ្រាប់ស្ពៃទំហំប៉ុន្មាន ក៏នៅប៉ុណ្ណោះដដែល នេះគឺដោយអំណាចបុណ្យបារមីរបស់ព្រះអង្គ គ្មានអ្នកណានឹងគិតត្រូវ តែខំគិតហើយមុខជានឹងត្រឡប់ទៅជាមនុស្សឆ្កួតមិនខានឡើយ ។ មានរឿងដំណាលពីបុរសម្នាក់ ខំរិះគិតពីវិស័យរបស់ព្រះពុទ្ធ ក៏មិនសម្រេចដូចប្រាថ្នា ស្ទើរនឹងត្រឡប់ទៅជាឆ្កួត ។ វេលានោះមានអ្នកមានប្រាជ្ញាម្នាក់មានចិត្តមេត្តាបានយកកញ្ចក់ ១ ទៅឆ្លុះតួព្រះចេតិយកំពស់ ១ រយ ២០ ហត្ថ ទំហំ ៣ រយ ៦០ ហត្ថ ហើយប្រាប់ថា: អ្នកឯងចូរមើលស្រមោលព្រះចេតិយក្នុងកញ្ចក់នេះ ។ ឯបុរសនោះក៏ទៅមើលឃើញមែន ។ ទើបអ្នកមានប្រាជ្ញាសួរថា: តួព្រះចេតិយធំម្ល៉េះ អាចចូលមកជាប់នៅក្នុងផ្ទៃកញ្ចក់នេះបាន បើដូច្នេះតើអ្នកយល់ថា ព្រះចេតិយនេះតូចទៅហើយកញ្ចក់រីកធំឡើងឬដូចម្ដេច? ។ អ្នកនោះតបថា: មិនមែនដូច្នោះទេ តួព្រះចេតិយនឹងតួកញ្ចក់នេះ មានទំហំប៉ុន្មាន ក៏នៅប៉ុណ្ណោះដដែល ។ អ្នកមានប្រាជ្ញាក៏ប្រាប់ថា: អើវិស័យរបស់ព្រះពុទ្ធ ក៏យ៉ាងនោះដែរ អ្នកគិតមិន

ត្រូវទេ តែចំគិតហើយមុខជានឹងឆ្កួតមិនខាន ។ ឯបុរសនោះក៏ជឿចូលចិត្ត ឥតសង្ស័យតទៅទៀតឡើយ ។

២ — វិស័យឈាន: លោកអ្នកដែលបានសម្រេចឈាន ប្រកបដោយអភិញ្ញាហើយ តែងមានឫទ្ធិមានអំណាច អាចនឹងទៅចាប់យកព្រះអាទិត្យព្រះចន្ទ មកធ្វើជាតាំងសម្រាប់ទ្រជើងក៏បាន ឬនឹងចង់និម្មិតខ្លួនឲ្យជាតែអ្វីៗ ក៏សម្រេចបានគ្រប់យ៉ាងឥតមានទើសទាស់ឡើយ ។

៣— ផលកម្ម: មនុស្សដែលបានធ្វើកុសលកម្ម ឬអកុសលកម្ម ហើយ តែងសោយសេចក្ដីសុខទុក្ខតិចច្រើន តាមផលកម្មដែលខ្លួនបានធ្វើមកនោះ, បើចំណែកខាងកុសលកម្ម ផលកម្មនោះនាំទៅកើតជាទេវតា ឬនាំទៅកើតជាមនុស្ស ក៏មិនដូចគ្នា ខ្លះកើតក្នុងត្រកូលខ្ពង់ខ្ពស់ ខ្លះកើតក្នុងត្រកូលថោកទាប ខ្លះមាន ខ្លះក្រ ខ្លះល្អ ខ្លះអាក្រក់ជាដើម ។

បើចំណែកខាងអកុសលកម្មវិញ ផលកម្មនោះនាំទៅកើតក្នុងអបាយភូមិ ទាំង៤ គឺ នរក ប្រេត តិរច្ឆាន នឹងអសុរកាយ រងទុក្ខវេទនាផ្សេងៗគ្នា មិនដូចគ្នាឡើយ ។

៤— ការគិតពីរឿងលោក: បុគ្គលណាមួយគិតថា កាលដើមបង្អស់តើនរណាបង្កើតព្រះអាទិត្យព្រះចន្ទ ដី ទឹក ភ្លើង ខ្យល់ ព្រមទាំងដើមស្វាយ ដើមដូង នឹងដើមស្វាជាដើមនេះមក បានជាមានជាប់មកដល់សព្វថ្ងៃនេះ ក៏វះគិតមិនឃើញឡើយ ព្រោះវត្ថុទាំងនោះតែងកើតមកជាធម្មតា នឹងមានលោកអ្នកណា មានឫទ្ធិ មានអំណាចអាចនឹង

បង្កើតទុកមកក៏ទេ  គឺមានតាំងពីកដី ទឹក  រហូតដល់មកសព្វថ្ងៃនេះឯង ហេតុនោះបានជារកលោកអ្នករិះគិតមិនត្រូវ ។

សូមថ្លែងពីរបស់ដែលដូចគ្នាវិញ  ឯរបស់ដែលដូចគ្នាឥតខានដូចមិនបាននោះ  នឹយមយកត្រង់សេចក្តីស្លាប់តែម្យ៉ាង  ព្រោះរូបយើងកល់-គ្នាតែកើតឡើងហើយតែងស្លាប់ទៅវិញជាធម្មតា  ខុសគ្នាតែខ្វះស្លាប់មុន ខ្វះស្លាប់ក្រោយប៉ុណ្ណោះ  ទីងរវះគេបឲ្យផុតពីសេចក្តីស្លាប់ពុំបាន  ប្រុសក៏ស្លាប់ ស្រីក៏ស្លាប់ ក្មេងក៏ស្លាប់ ចាស់ក៏ស្លាប់ អ្នកធំក៏ស្លាប់ អ្នកតូចក៏ស្លាប់ អ្នកមានក៏ស្លាប់ អ្នកក្រក៏ស្លាប់ អ្នកប្រាជ្ញក៏ស្លាប់ អ្នកខ្លៅក៏ស្លាប់ អ្នកល្អក៏ស្លាប់ អ្នកអាក្រក់ក៏ស្លាប់ អ្នកអាយុវែងក៏ស្លាប់ អ្នកអាយុខ្លីក៏ស្លាប់ សេចក្តីស្លាប់នេះឯងឥតមានយល់មុខថា  អ្នកនេះធំអ្នកនេះតូចឡើយ ។

ក្នុងទីនេះ  ខ្ញុំសូមលើករឿងព្រេង ១ មកថ្លែង  ឲ្យឃើញច្បាស់ក្នុងសេចក្តីស្លាប់នេះទៀត  ក្នុងរឿងព្រេងនោះលោកបានដំណាលតៗមកថា:  មានមនុស្សម្នាក់ក្រទ្រព្យសម្បត្តិពន់ពេកណាស់  ហើយជំពាក់ជាក់-វិនទ្រព្យគេក៏ច្រើន  ក្នុងមួយថ្ងៃៗ គេមកតឹងទារទ្រព្យរបស់ជាច្រើនរូប, ហៅកំសត់នោះដល់ទាល់គំនិតគិតរករកតែអ្វីសងគេពុំបាន  ក៏កាន់តែព្រួយចិត្តឡើងៗ គិតចង់ស្លាប់ចោល  មិនចង់រស់នៅជាមនុស្សតទៅ  ក៏ស្រែកហៅរកព្រះកាល (១) ថា:  "ព្រះកាលអើយមកយកខ្ញុំចោលទៅ  កុំឲ្យខ្ញុំរស់នៅយូរ  ពិបាកចិត្តខ្ញុំពេកណាស់"  ស្រែកហៅយ៉ាងនេះគ្រប់ថ្ងៃ ៗ

---

១  ប្រែថា សេចក្តីស្លាប់ ។

គ្រានោះ ព្រះកាលក៏មកតាមពាក្យដែលបុរសនោះស្រែកហៅម៉ែន ថ្ងៃខ្លួនជាតាចាស់ម្នាក់ដើរមកដល់ហើយសួរថា "ចុះហេតុដូចម្ដេច បានជាអ្នកឯងស្រែកហៅយើងជាព្រះកាលអីដល់ម៉្លេះ អ្នកឯងកើតទុក្ខមិនសុខចិត្តពីរឿងអ្វីខ្លះ? ចូរប្រាប់យើងឲ្យឆាប់" ។ ចៅកំសត់នោះតបថា "ទូលលោកអើយ សព្វថ្ងៃនេះខ្ញុំទាល់ក្រពេកណាស់ កើតព្រួយចិត្តផ្សិតជំពាក់ទ្រព្យគេក៏ច្រើន គេមកតឹងទាររឿយ ៗ រកវត្ថុអ្វីសងគេពុំបានសោះ ព្រោះហេតុនោះបានជាខ្ញុំស្រែកហៅលោក ឲ្យលោកយកខ្ញុំឲ្យឆាប់ទៅ កុំឲ្យវេទនាយូរពេក" ។ ព្រះកាលប្រាប់វិញថា: "បើដូច្នោះអ្នកឯងថប់ចុះពេលនេះយើងមិនទាន់យកអ្នកឯងទៅឡើយទេ យើងជួយអ្នកឯងឲ្យមានទ្រព្យសម្បត្តិមានអាយុវែង បានសប្បាយចិត្តទៅខាងមុខសិន តែត្រូវអ្នកឯងរៀនមន្តអាគមគាថាចាំសង្វាតពីយើង រួចអ្នកយកទៅរកមើលជម្ងឺគេចុះ ទើងបានមានទ្រព្យសម្បត្តិច្រើនទៅខាងមុខមិនខាន" ។ ចៅកំសត់នោះមានចិត្តត្រេកអរ ក៏បានទទួលរៀនតាមពាក្យព្រះកាលប្រាប់ដោយសព្វគ្រប់ ហើយព្រះកាលនោះក៏បាត់ខ្លួនពីទីនោះមួយរំពេចទៅ ។ គ្រាខាងក្រោយមក ចៅកំសត់នោះបានដើរមើលជម្ងឺអ្នកស្រុកដែលឈឺចាំងប៉ុន្មាន ក៏បានសះជាដូចសេចក្ដីប្រាថ្នា ហើយគេបូជាផ្ទាន់ខាន់ខាវជាច្រើន យូរ ៗ ទៅត្រឡប់ជាអ្នកមានទ្រព្យសម្បត្តិយ៉ាងធំស្ដុកស្ដម្ភមាំមួនឡើង ។ គ្រាខាងក្រោយមកទៀត ព្រះកាលនោះមកប្រាប់វិញថា: "អ្នកឯងរៀបចំខ្លួនប្រាណចុះ ប្រាំពីរថ្ងៃទៀត យើងមកយក

អ្នកឯងហើយ" ។ អ្នកនោះក៏កើតសេចក្ដីទោមនស្សត្រូវចិត្តគិតថា "កាលពីដើមអញកំពុងតាល់ក្រលំបាកវេទនា បានខំស្រែកហៅព្រះកាលឲ្យមកយកឲ្យដាច់ ពេលនោះព្រះកាលមិនព្រមយក ក៏ជួយទំនុកបំរុងអញឲ្យមានទ្រព្យសម្បត្តិឡើង ឥឡូវអញមានទ្រព្យសម្បត្តិស្រួលបួលហើយត្រឡប់ជាមកយកអញទៅវិញ នរណាសុខចិត្តទៅ បើដូច្នេះគួរអញទីងគិតរេះគេចរត់ឲ្យផុតពីព្រះកាល កុំឲ្យតាមរកអញឃើញឡើយ" គិតដូច្នេះហើយក៏ប្រាប់ប្រពន្ធកូនតាមរឿងនោះដោយសព្វគ្រប់ ដល់វេលាយប់ក៏ដឹកនាំទ្រព្យសម្បត្តិទាំងអស់ នាំទាំងប្រពន្ធកូនចុះសំពៅបើកចួងសំដៅភាសមុទ្រទៅក្រៅ ដោយគិតថា: មុខជាទីងផុតពីកណ្ដាប់ដៃព្រះកាលហើយ ។ លុះបើកសំពៅគ្រប់ ៧ ថ្ងៃ ដល់ទៅមហាសមុទ្រ ពេលនោះ កើតមានខ្យល់ព្យុះបក់បោករលកមកផ្ទប់សំពៅលិចទៅក្នុងទឹកមហាសមុទ្រ ជនទាំងនោះក៏ស្លាប់ទាំងអស់គ្នាឥតមានសល់ម្នាក់ឡើយ ត្រូវដូចពាក្យព្រះកាលថា ប្រាំពីរថ្ងៃទៀតនឹងមកយកនោះឯង ។

រឿងនេះជួយឲ្យយល់ច្បាស់ថា មនុស្សសត្វគេចពីស្លាប់មិនផុត ព្រោះជារបស់ត្រូវមានស្មើគ្នា ដូច្នេះ យើងកុំភ្លេចថាខ្លួនយើងមិនស្លាប់ ហើយកុំភ្លេចថាខ្លួនយើងត្រូវចាប់ជាតិជាថ្មីទៀត តាមអំពើជាកម្មដែលខ្លួនបានសាងមក ។

សំដែងមកក្នុងរឿងកថា សូមបញ្ចប់ត្រឹមប៉ុណ្ណេះ ឯវំ ។

# បញ្ញាសជាតក

## ភាគទី ៣

បណ្ឌិតមហា ឈឹម-ស៊ុម សាស្ត្រាចារ្យ

នៅសាលាបាលីជាន់ខ្ពស់ បាត់ឲ្យប្រែហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្លួនឯង

កាលដែលនៅជាភេទបព្វជិតពី ព.ស. ២៤៨៦, គ.ស. ១៩៤៣

(តមក)

---

## ទុក្កម្មានិកជាតក ទី១៣

លោកអាចារ្យ ឈឹម-ស៊ុម ក្រុមជំនុំព្រះត្រៃបិដក

ប្រែពីបាលី

---

យោ បុគ្គលោ ទោសជនោតិ ឥទំ សត្ថា ជេតវនេ វិហរន្តោ អត្តនោ ទុក្ខំ អារព្ភ កថេសិ ។ សត្ថា រីអង្គសម្តេចព្រះបរមសាស្តាចារ្យ កាលទ្រង់សម្រាន្តព្រះឥរិយាបថនៅវត្តជេតពន ទ្រង់ប្រារព្ធនូវសេចក្តីទុក្ខរបស់ព្រះអង្គ ទ្រង់សម្តែងធម៌ទេសនា មានបទព្រះបាលីថា យោ បុគ្គលោ ទោសជនោ ដូច្នេះជាដើម ។

កិរ បានឮថា ភិក្ខុទាំងឡាយ ប្រជុំគ្នានិយាយក្នុងសាលាធម្មសភាថា ទុ ហ្ន៎! ព្រះសាស្តាជាម្ចាស់យើង ទ្រង់អត់សង្កត់នូវទុក្ខវេទនា ដែលប្រព្រឹត្តទៅក្នុងកាយទីងក្នុងព្រះទ័យ ជាបរតែបានត្រាស់សម្មាសម្ពោធិញ្ញាណឡើង ។ តំ សុត្វា សម្តេចព្រះបរមសាស្តា ទ្រង់ព្រះសវនាការឮពាក្យនោះហើយ ទ្រង់ចេញចាកគន្ធកុដី មកគង់លើព្រះបវរពុទ្ធាសនៈ ដែលគេរៀបចំសម្រាប់ព្រះអង្គ ហើយទ្រង់មានព្រះពុទ្ធដីកា

សួរថា ម្នាលភិក្ខុទាំងឡាយ, ឥឡូវនេះអ្នកទាំងឡាយអង្គុយប្រជុំគ្នានិយាយពីរឿងអ្វី? ។ ភិក្ខុទាំងនោះក្រាបបង្គំទូលតាមដំណើរសេចក្ដី ទើបព្រះជិនស្រីទ្រង់មានព្រះពុទ្ធដីកាថា "ម្នាលភិក្ខុទាំងឡាយ, មិនត្រឹមតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ, កាលពីដើម ក៏តថាគតធ្លាប់អត់ទ្រាំនូវទុក្ខវេទនាដែរ គឺកាលដែលតថាគតកើតក្នុងត្រកូលកុដុម្ពិកៈ តថាគតបានដោះខ្លួនរួចអំពីការសម្លាប់នៃស្ដេចមិនប្រកបដោយធម៌ ហើយបានរស់រួចជីវិតឡើងវិញ ដោយឧបាយឆ្លៀសវៃ" សម្ដេចព្រះជិនស្រីទ្រង់ត្រាស់ដូច្នេះហើយ ទ្រង់គង់នៅដោយតុណ្ហីភាព ដរាបតែភិក្ខុទាំងនោះអារាធនា ទើបព្រះសាស្ដាទ្រង់នាំអតីតនិទានមកសំដែងប្រាប់ថា

អតីតេ កាលេ ក្នុងកាលដ៏កន្លងលើសទៅហើយ មានព្រះរាជាមួយព្រះអង្គ ទ្រង់ព្រះនាមព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី ទ្រង់មានព្រះរាជបុត្រមួយព្រះអង្គ ព្រះនាម ធុតធរ បានសោយរាជសម្បត្តិប្រកបដោយធម៌ តពីព្រះរាជបិតាមក; ព្រះបាទធុតធរនោះមានព្រះរាជបុត្រមួយព្រះអង្គ ទ្រង់ព្រះនាម អជិត បានសោយ-រាជសម្បត្តិតមកទៀត ។ គ្រានោះ មានកុដុម្ពិកៈម្នាក់នៅក្នុងជនបទ ។ ព្រះពោធិសត្វទ្រង់បានមកកើតជាកូនកុដុម្ពិកៈនោះ ឈ្មោះ ទុក្ខមានិក ។ កុដុម្ពីជាបិតា បានប្រៀនប្រដៅទុក្ខមានិកនោះ ក្នុងកាលដែលខ្លួនរៀបទទួលអនិច្ចកម្មថា "ហៃបា អ្នកឯងកុំយកស្រីមេម៉ាយបីដងជាប្រពន្ធ, កុំយកបុរសបួសបីដងជាសំឡាញ់ កុំសេពគប់នឹងស្ដេចឥតពិចារណាឡើយ" ។ កុដុម្ពិកៈផ្ដាំពាក្យបីមាត់ដូច្នេះហើយ ក៏ទទួលអនិច្ចកម្មទៅ ។

ពោធិសត្វជាបុត្រគិតថា "បិតាអញបានផ្តាំយ៉ាងនេះ, តើពាក្យនេះនឹងមានផលឬគ្មានអេះ" កំពុងតែគិតដូច្នេះ ក៏ដួនជាមានស្រីម្នាក់មេម៉ាយបីដង មកសំដែងអាការស្និទ្ធស្នាល គួរឲ្យចាប់ចិត្ត, ពោធិសត្វក៏គិតថា "អាត្មាអញគួរល្បងពាក្យបិតាក្នុងគ្រានេះចុះ" គិតតែប៉ុណ្ណោះហើយក៏យកស្រីនោះមកធ្វើជាភរិយារបស់ខ្លួន ។ តមកទៀត មានបុរសម្នាក់បួសបីដង សឹកបីដង មកសំដែងសេចក្តីស្និទ្ធស្នាល ក៏ពោធិសត្វរាប់រកយកបុរសនោះជាសំឡាញ់ទៀត ។ ក្នុងកាលខាងក្រោយមក ទុកមាទិក ពោធិសត្វចង់ល្បងចិត្តភរិយា ក៏ទៅចាប់សុវណ្ណហង្សរបស់ព្រះរាជា ដែលកំពុងត្រាច់ទៅក្បែរមាត់ស្ទឹង យកមកជីករណ្តៅមួយហើយដាក់ហង្សក្នុងរណ្តៅនោះ គ្របជាលពពោកកក់ទុកប្រហោងតូចៗ កុំឲ្យហង្សនោះដាច់ដង្ហើមស្លាប់ ហើយត្រឡប់មកផ្ទះវិញ សម្លាប់ហង្សមួយដទៃទៀតចំអិនស្ងោរស្រេចដាក់ទុក ក្នុងកាលដែលភរិយានោះទៅផ្សារបាត់ ។ កាលបើភរិយាមកដល់, ក៏និយាយកុហកថា ខ្ញុំចាប់សុវណ្ណហង្សរបស់ព្រះរាជាមកសម្លាប់ចំអិនស្ងោរស្រេចទៅហើយ ។ ភរិយាក៏បន្ទោសថា អ្នកប្តីអើយ, អ្នកឯងមិនដឹងទេឬ? អំពើនេះមានទោសធ្ងន់ណាស់! ។ កាលនោះ ក៏កើតសេចក្តីច្រលើមឡើងក្នុងទីក្រុងទាំងអស់ ដោយហេតុដែលបាត់សុវណ្ណហង្សរបស់ព្រះរាជា ។ ព្រះរាជាទ្រង់តាំងឲ្យបំណាយមាស ១ ពាន់ដំឡឹង ឲ្យអាមាត្យដើរប្រទក្សិណផ្សារ ឃោសនាផ្សាយដំណឹងថា បើអ្នកណាដឹងថាសុវណ្ណហង្សបាត់ដោយហេតុដូចម្តេច នោះទ្រង់នឹងព្រះរាជទានមាសមួយពាន់ដំឡឹងនេះ ។ គ្រានោះ ភរិយា

ទុកមានិក  កំពុងចង់បានប្ដីដទៃទៀតផង  កំពុងចង់បានមាសនោះផង ក៏ឆ្លើយជូនទៅនឹងអាមាត្យអ្នកឃោសនាថា នែអ្នកទាំងឡាយអើយ, អ្នករាល់គ្នាយកមាសមកឲ្យខ្ញុំចុះ ខ្ញុំដឹង ។ អាមាត្យសួរថា នរណាចាប់សុវណ្ណហង្ស? ។ ស្រីនោះឆ្លើយថា ប្ដីខ្ញុំ ។ – ពិតមែនឬអ្វី? – ពិតមែន បានជាខ្ញុំថា ។ ទើបអាមាត្យទាំងឡាយនាំសេចក្ដីនោះទៅក្រាបបង្គំទូលព្រះរាជា, ព្រះរាជាទ្រង់បង្គាប់ឲ្យចាប់ទុកមានិកបុរសនោះមក ។ អាមាត្យទាំងឡាយ  ចាប់ទុកមានិកបុរសចងដោយចំណង ៥ ប្រការ វាយដំប្រំនាំមកបង្ហាញព្រះរាជា  ។  ចំណែកខាងបុរសបួស ៣ ដង សឹក ៣ ដងដែលជាសំឡាញ់នោះ  បានឃើញគេចាប់ទុកមានិកបុរសទៅហើយ  ក៏ឥតមានសេចក្ដីឈឺឆ្អាល  ឬជួយដោះសារអ្វីសោះ,  បែរជានិយាយដូច្នេះវិញថា អ្នកឯងឲ្យសំពត់មួយនោះមកខ្ញុំ, អ្នកឯងមើលចុះ សំពត់របស់ខ្ញុំរហែកដូចគេច្រៀក, អ្នកឯងជាប់ទោសទៅហើយ ចាំបាច់ប្រើប្រាស់សំពត់ធ្វើអ្វី ។ ទុកមានិកបុរសនោះ ក៏ឲ្យសំពត់ស្លៀកសំពត់ដណ្ដប់របស់ខ្លួនទៅ ។

គ្រានោះ ព្រះរាជាទ្រង់បង្គាប់ថា អ្នកទាំងឡាយ ចូរនាំវាទៅសម្លាប់ខាងក្រៅនគរក្នុងថ្ងៃនេះកុំខាន ។ ទុកមានិកបុរសនោះ ក៏ទន្ទេញទន្ទូរថា «បើខ្ញុំស្លាប់, ហង្សក៏ស្លាប់; បើខ្ញុំមិនស្លាប់, ហង្សក៏មិនស្លាប់ដែរ» ។ អាមាត្យទាំងឡាយគម្រាមថា «ហង្សអ្នកឯងស៊ីអស់ទៅហើយ មានហង្សពីណារស់ឡើងវិញ!» គម្រាមដូច្នេះហើយក៏នាំទៅដើម្បីសម្លាប់ ។ ថ្ងៃនោះ ដួនជាឆ្មាំទ្វារ បិទទ្វារព្រះនគរក្នុងវេលា

រសៀល ។ អាមាត្យទាំងឡាយនោះ នាំទុក្កមានិកបុរសទៅកាន់ទ្វារខាងកើត ហៅឆ្មាំទ្វារថា នែនាយ, បុរសនេះជាចោរកំណាច, អ្នកឯងបើកទ្វារចាប់ឡើង យើងនឹងនាំទៅសម្លាប់ក្នុងថ្ងៃនេះ ។ ឆ្មាំទ្វារឆ្លើយថា បើព្រះរាជាពុំទាន់ជំនុំជំរះទោសបុរសនេះទេ, ខ្ញុំមិនបើកទ្វារអស់ ៣ ថ្ងៃ, ព្រោះថាព្រះរាជា សម្លាប់មនុស្សមិនមែនជាចោរកំណាច, អំពើដែលទ្រង់ពុំទាន់បានពិចារណាទៅឡើយ ហើយធ្វើហួសទៅ សុទ្ធតែបានសេចក្ដីក្ដៅក្រហាយ ស្ដាយក្រោយ ។ អាមាត្យសួរថា រឿងដែលគេមិនបានពិចារណាកន្ទងទៅហើយនោះតើដូចម្ដេច? អ្នកឯងនិយាយរឿងនោះមកមើល ។ ឆ្មាំទ្វារនិយាយថា ពីដើមមានប្ដីប្រពន្ធពីរនាក់ មានកូនប្រុសមួយ, អ្នកទាំងពីរនាក់នោះ ចិញ្ចឹមស្ការមួយជាទីស្រឡាញ់ប្រហែលនឹងកូន ។ ថ្ងៃមួយ ប្ដីប្រពន្ធទាំងពីរនាក់ផ្ដេកកូនទុកនៅឯផ្ទះ ហើយនាំគ្នាទៅស្រែ ចួនជាមានពស់មួយប៉ុនឈើប្រត់មកចឹកកូនរបស់អ្នកទាំងពីរនោះ ។ ស្ការក៏ស្ទុះទៅប្រខាំគ្នានឹងពស់, ខាំពស់ដាច់ជាកំណាត់ៗ, ពស់ស្លាប់ទៅ កូនគាត់នោះក៏ស្លាប់ដែរ; ស្ការរត់ទៅឲ្យដំណឹងដល់ម្ចាស់ឯស្រែ, ម្ចាស់យល់សេចក្ដីនោះពុំបាន ដោយបានឃើញខ្លួនស្ការប្រឡាក់ឈាម ក៏គិតស្មានថាជាស្ការខាំកូនរបស់ខ្លួន ទើបនិយាយថា "យីអើ! យើងចិញ្ចឹមស្ការនេះស្រឡាញ់ប្រហែលនឹងកូន ឥឡូវវាហ៊ានសម្លាប់កូនយើង", ថាតែប៉ុណ្ណោះ ក៏សំពងស្ការនោះដោយទំពក់រនាស់ទាល់តែស្ការស្លាប់ទៅ ។ ប្ដីប្រពន្ធទាំងពីរនាក់ មកដល់ផ្ទះបានឃើញខ្មោចពស់នៅកៀនជញ្ជាំង ឃើញទាំងកូនស្លាប់នៅក្បែរពស់

នោះផង ទើបដឹងពិតជាកូនស្លាប់ដោយពស់ចឹក ក៏យំទួញឡោកប្រះប្រែះ នទៀលនៅទីនោះ ។ ឆ្មាំទ្វារនិយាយថា ហេតុដែលស្តេចម្ចាស់យើង មិនបានគិតឲ្យស្រេច ក្រែងគន្លងទៅៗជាដូច្នោះទេដឹង ។

អាមាត្យទាំងអស់ ក៏នាំទុកមាតិកបុរសទៅកាន់ទ្វារខាងត្បូងទៀត, ហៅឆ្មាំទ្វារប្រាប់ថា ម្នាលនាយ, បុរសនេះជាចោរកំណាច, អ្នកឯងបើកទ្វារឆាប់ឡើង យើងនឹងនាំទៅសម្លាប់ក្នុងថ្ងៃនេះ ។ ឆ្មាំទ្វារឆ្លើយថា បើព្រះរាជាពុំទាន់ដំនុំជំរះទោសបុរសនេះទេ, ខ្ញុំមិនបើកទ្វារអស់ ៣ ថ្ងៃ ព្រោះព្រះរាជាសម្លាប់មនុស្សមិនមែនជាចោរកំណាច, អំពើដែលទ្រង់ពុំទាន់បានពិចារណានៅឡើយ ហើយកន្លងហួសទៅ សុទ្ធតែបានសេចក្តីក្តៅក្រហាយស្តាយក្រោយ ។ អាមាត្យសួរថា រឿងដែលគេមិនបានពិចារណាកន្លងទៅហើយនោះតើដូចម្តេច? អ្នកឯងនិយាយរឿងនោះមកមើល ។ ឆ្មាំទ្វារនិយាយថា មានបុរសម្នាក់ជាព្រានសត្វស្លាប ចិញ្ចឹមសត្វខ្លែងមួយ ។ ថ្ងៃមួយ បុរសនោះទៅព្រៃ ដើម្បីសម្លាប់សត្វស្លាប ។ ខ្លែងក៏បានទៅជាមួយផង ។ បុរសនោះស្រេកទឹកក៏ចូលទៅក្នុងស្ទឹងដើម្បីផឹកទឹក ។ មានពស់មួយនៅក្នុងទឹកជ្រាំង; បុរសស្រេកទឹកខ្លាំង ប្រឹងតែមុលចូលទៅដើម្បីផឹកទឹក មិនបានឃើញពស់នោះសោះ ។ ខ្លែងឃើញពស់នោះហើយ ក៏គិតថា "ឱហ្ន៎! ម្ចាស់អញមិនឃើញពស់នេះទេតើ, បើដូច្នេះអញនឹងឃាត់គាត់អេះ", គិតដូច្នេះហើយក៏ទទះស្លាបគ្រោកទឹកកុំឲ្យផឹក ។ បុរសនោះ ក៏វាយក្បាលខ្លែងដោយដងធ្នូ ខ្លែងនោះក៏ស្លាប់ទៅ ។ បុរសឈ្លោកផឹកទឹកទៀត

ពស់ស្ទុះក្អែតមកចឹកផ្ទប់ចំភ្នែក; បុរសក៏ស្រែកទ្រហោយំឡើងដោយគិតថា ខ្លួននេះឃើញភ័យនេះហើយតើ បានជាក់យាត់អញ ៗ បុរសនោះវែង កើតទុក្ខម្នេញ ដោយស្តាយខ្លួនជាទីស្រឡាញ់ផ្សំតាំងខ្វួចភ្នែកនោះផង ៗ ឆ្មាំទ្វារនិយាយនឹងអាមាត្យទាំងឡាយថា ហេតុដែលស្តេចម្ចាស់យើងមិន បានគិតឲ្យស្រេច ក្រែងកន្ទួនហួសទៅៗជាជូរប្លោះទេដឹង ៗ

អាមាត្យទាំងឡាយនោះ នាំទុក្ខមានិកបុរសទៅកាន់ទ្វារខាងលិច ទៀត, ហៅឆ្មាំទ្វារប្រាប់ថា ម្នាលនាយ, បុរសនេះជាចោរកំណាច, អ្នកឯងបើកទ្វារឆាប់ឡើង យើងនឹងនាំទៅសម្លាប់ក្នុងថ្ងៃនេះ ៗ ឆ្មាំទ្វារឆ្លើយថា បើព្រះរាជាពុំទាន់ដំនុំជំរះទោសបុរសនេះទេ ខ្ញុំមិនបើកទ្វារ អស់៣ថ្ងៃ ព្រោះថា ព្រះរាជាសម្លាប់មនុស្សមិនមែនជាចោរកំណាច, អំពើដែលទ្រង់ពុំទាន់ពិចារណានៅឡើយ ហើយកន្ទួនហួសទៅ សុទ្ធតែបានសេចក្តីក្តៅក្រហាយស្តាយក្រោយ ៗ អាមាត្យសួរថា រឿងដែលគេមិនបានពិចារណាកន្ទួនទៅហើយនោះ តើដូចម្តេច? អ្នកឯងនិយាយរឿងនោះមកមើល ៗ ឆ្មាំទ្វារនិយាយថា បពិត្រអ្នកទាំងឡាយដ៏ចំរើន, បានឮតមកថា មានព្រះរាជាមួយព្រះអង្គ ទ្រង់ព្រះនាមព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី; ព្រះរាជាអង្គនោះ មានព្រះរាជធីតាមួយព្រះអង្គ ព្រះនាមនាងសុទ្ធា តែងទៅស្រង់ក្រសាល ក្នុងស្រះបោក្ខរណីរាល់ៗថ្ងៃ; មានក្អែមួយតែងទៅតាមព្រះរាជធីតានោះផង, ព្រះរាជធីតាទ្រង់ពាក់គ្រឿងប្រដាប់ញ្ជ័ព្រះសូរងសុទ្ធសឹងតែមាស នឹងពេជ្រ ទ្រង់ស្តេចទៅដល់ទីជិតស្រះបោក្ខរណី ចួនជាមានបុរសម្នាក់

ថាអ្នកមានពៀរនឹងព្រះរាជា មកលបបង្កប់ចំរូងក្បែរមាត់ស្រះបោក្ខរណី ដើម្បីឲ្យដង់ព្រះរាជធីតានោះ ឥតមាននរណាមួយដឹងហេតុនោះសោះ ។ ក្តែបានឃើញហេតុនោះហើយ ក៏ស្ទុះទៅស្ទាក់ឃាត់ព្រះរាជធីតា ដែលកំពុងយាត្រាទៅ ៗ ព្រះរាជធីតានោះក៏បបេសតែទៅៗ ជាន់ចំរូងដែលបុរសមានពៀរបង្កប់ទុក មុតសុគតក្នុងទីនោះទៅ ។ ក្តែដឹងជាមានគ្រោះថ្នាក់ពុំល្អដូច្នោះ ក៏ស្ទុះទៅពាំទាញគ្រឿងប្រដាប់របស់ព្រះរាជធីតា នាំយកទៅដាក់កល់ទុក ក្នុងទីជិតព្រះរាជា ដើម្បីថ្វាយដំណឹង ។ ព្រះរាជាទ្រង់ទស្សនាការឃើញក្តែពាំគ្រឿងប្រដាប់រត់មកដូច្នោះ ក៏ទ្រង់គិតស្មានថា "ធីតារបស់អញប្រាកដជាក្តែនេះសម្លាប់ហើយ បានជាវាពាំគ្រឿងប្រដាប់មក", ហើយទ្រង់ឲ្យសម្លាប់ក្តែនោះភ្លាម ។ លុះទ្រង់ជ្រាបថាព្រះរាជធីតាសុគតដោយហេតុដទៃវិញ, ទើបទ្រង់ជាទុក្ខម្នេញទ្រង់ព្រះកន្សែងសោកបោកប្រះព្រះអង្គ គន់ដប់នូវអស់កាលជាយូរអង្វែង ទ្រង់ព្រះកន្សែងថ្ងូររំយោគសោកស្តាយថា ឱអាត្មាអញអើយ, មិនដឹងហេតុនោះសោះ! ឥឡូវនេះខុសគស់ឲ្យគេសម្លាប់ក្តែដ្រលទៅ ។ ឆ្មាំទ្វារនិយាយនឹងអាមាត្យទាំងឡាយថា ហេតុដែលស្តេចម្ចាស់យើងមិនបានគិតឲ្យស្រេច ក្រែងកន្លងហួសទៅៗជាដូច្នោះទេដឹង ។

អាមាត្យទាំងឡាយនោះ នាំទុក្កម្មាទិកបុរសទៅកាន់ទ្វារខាងជើងទៀត, ហៅឆ្មាំទ្វារប្រាប់ថា ម្នាលនាយ, បុរសនេះជាចោរកំណាច, អ្នកឯងបើកទ្វារឆាប់ឡើង យើងនឹងនាំវាទៅសម្លាប់ក្នុងថ្ងៃនេះ ៖ ឆ្មាំទ្វារឆ្លើយថា បើព្រះរាជាពុំទាន់ដំរុំជំរះទោសបុរសនេះទេ, ខ្ញុំមិនបើកទ្វារ

អស់ ៣ ថ្ងៃ, ព្រោះថា ព្រះរាជាសម្រាប់មនុស្សមិនមែនជាចោរកំណាច, អំពើដែលទ្រង់ពុំទាន់បានពិចារណានៅឡើយ ហើយកន្លងហួសទៅ សុទ្ធតែបានសេចក្តីក្តៅក្រហាយស្តាយក្រោយ ៗ អាមាត្យសួរថា រឿងដែលគេមិនបានពិចារណាកន្លងទៅហើយនោះតើដូចម្តេច? អ្នកឯងនិយាយរឿងនោះមកមើល ៗ ឆ្មាំទ្វារនិយាយថា បានឮមកថា មានបុរសជាសំឡាញ់នឹងគ្នាពីរនាក់ស្រឡាញ់គ្នាណាស់ ម្នាក់នៅស្រុកខាងលិច ម្នាក់នៅស្រុកខាងកើត ៗ សំឡាញ់នៅស្រុកខាងលិច ទៅផ្ទះសំឡាញ់នៅស្រុកខាងកើត ៗ សំឡាញ់នៅស្រុកខាងកើតនោះ មានចិញ្ចឹមឆ្កែមួយ ជាទីស្រឡាញ់ពេញចិត្តណាស់, ប៉ុន្តែទាល់ទឹងគ្មានអ្វីឲ្យជាទីរពុកដល់សម្លាញ់ដែលមកលេងសោះ ក៏ឲ្យឆ្កែនោះថា សំឡាញ់, ឆ្កែនេះ ខ្ញុំឲ្យអ្នកឯង, ចូរអ្នកឯងយកវាទៅចិញ្ចឹមចុះ ៗ សំឡាញ់នៅស្រុកខាងលិចនោះ ក៏ទទួលយកឆ្កែហើយលាសំឡាញ់ថា "សំឡាញ់អើយ, អ្នកឯងឲ្យឆ្កែខ្ញុំៗអរគុណហើយ, ចូរអ្នកឯងនៅឲ្យសុខ កុំបីមានទុក្ខសោករោគភ័យឡើយ" ហើយក៏បបោសអង្អែលឆ្កែនោះ នាំទៅកាន់ទីលំនៅរបស់ខ្លួន ដោយសេចក្តីពេញចិត្ត ៗ លុះចំណេរមកខាងក្រោយបុរសនោះចងខ្សែ(១) នៅកឆ្កែ ហើយបញ្ជូនទៅកាន់សំឡាញ់ខាងកើត ដើម្បីឲ្យដំណឹងសុខ-ទុក្ខ ៗ ឆ្កែគិតថា "ម្ចាស់អញនេះ ចងខ្សែឲ្យអញដោយផ្ចិតផ្ចង់ណាស់, បើដូច្នេះ គួរតែអញទៅប្រាប់ដល់ម្ចាស់ដើមសិនចុះ" គិតតែប៉ុណ្ណោះ

---

១ ខ្សែនេះប្រហែលជាខ្សែមាសឬខ្សែអ្វីដែលមានដម្លៃច្រើន, បានជាម្ចាស់ដើមសំគាល់ថា ឆ្កែនេះល្អប ៗ

ក៏ទៅក្លាម ។ បុរសនៅស្រុកខាងកើតឃើញឆ្កែមកដល់ ក៏គិតថា "ឆ្កែនេះលួចទ្រព្យសំឡាញ់អញរត់មកហើយតើ" គិតតែប៉ុណ្ណោះក៏សំពងក្បាលឆ្កែដោយដំបង ឆ្កែនោះក៏ស្លាប់ទៅ ។ បំណែកខាងសំឡាញ់នៅស្រុកខាងលិច កាលបើបាត់ឆ្កែនោះយូរពេក ក៏ទៅតាម, សួរសំឡាញ់នៅស្រុកខាងកើតថា ខ្ញុំបានចងខ្សែនៅកឆ្កែហើយបញ្ជូនវាមក, តើអ្នកឯងបានឃើញវាឬទេ? ។ សំឡាញ់នៅស្រុកខាងកើតឆ្លើយថា ខ្ញុំឃើញដែរ, ប៉ុន្តែខ្ញុំស្មានថាវាលួចទ្រព្យអ្នកមក បានជាខ្ញុំវាយវា, ឥឡូវវាក្ស័យទៅហើយ ។ បុរសទាំងពីរនាក់ក៏ជាទុក្ខខ្វល់យំក្ដៅក្រហាយស្ដាយក្រោយយ៉ាងខ្លាំង ។ ឆ្មាំទ្វារនិយាយនឹងអាមាត្យទាំងឡាយថា ហេតុដែលស្ដេចម្ចាស់យើង មិនបានគិតឲ្យស្រេចក្រែងកន្លងហួសទៅៗ ជាដូច្នោះទេដឹង ។

កាលឆ្មាំទ្វារនឹងអាមាត្យទាំងនោះ កំពុងនិយាយគ្នាយ៉ាងនេះ ក៏ព្រឹកភ្លឺស្វាងឡើង; អាមាត្យទាំងឡាយ ក៏នាំទុក្កមានិកបុរសនោះទៅក្រាបបង្គំទូលព្រះរាជាវិញ ។ ព្រះរាជាទ្រង់ទស្សនាការ ឃើញរាជបុរសទាំងឡាយនាំទុក្កមានិកបុរសមកវិញ ទ្រង់ត្រាស់សួរថា អញឲ្យយកវាទៅសម្លាប់ ម្ដេចក៏មិនសម្លាប់ បែរជានាំវាមកវិញ? ។ អាមាត្យទាំងឡាយនោះ ក្រាបបង្គំទូលព្រះរាជាតាមដំណើរសេចក្ដីដែលឆ្មាំទ្វារទាំងឡាយនិយាយ សព្វគ្រប់ប្រការ ។ ព្រះរាជាទ្រង់ព្រះសវនាការ ហើយទ្រង់សួរទុក្កមានិកបុរសថា អ្នកឯងចង់និយាយដូចម្ដេច? ។ គ្រានោះទុក្កមានិកពោធិសត្វក្រាបបង្គំទូលព្រះរាជាថា បពិត្រព្រះរាជសម្ភារ,

កាលដែលបិតារបស់ទូលព្រះបង្គំជាខ្ញុំ រៀបនឹងទទួលអនិច្ចកម្មទៅ គាត់បានឲ្យទ្រព្យដល់ទូលព្រះបង្គំជាខ្ញុំសព្វគ្រប់ ទើបគាត់ទទួលអនិច្ចកម្មទៅ, ទូលព្រះបង្គំជាខ្ញុំចង់ល្បងពាក្យបិតា បានជាធ្វើយ៉ាងនេះ, ប៉ុន្តែឥតប្រាប់នរណាដទៃផុតម្នាក់សោះ ប្រាប់ត្រឹមតែប្រពន្ធមួយប៉ុណ្ណោះ. ដល់ម្ល៉ោះគង់តែមានគេដឹងសាយសុះ; កាលដែលព្រះអង្គឲ្យគេចាប់ទូលព្រះបង្គំជាខ្ញុំមកនោះ ស្រាប់តែទូលព្រះបង្គំជាខ្ញុំបានឃើញសំឡាញ់ម្នាក់ស្រុះមក, វាក៏គើបសំពត់មួយរបស់ទូលព្រះបង្គំជាខ្ញុំ ដែលប្រឡាក់ដោយឈាមយកបាត់ទៅ, ទូលព្រះបង្គំជាខ្ញុំ ក៏សុខចិត្តឲ្យវាឥតស្តាយស្រណោះ; ហើយរឿងសំឡាញ់នោះ កុំបាច់ថ្លែងចុះ, ចំណែកទាំងហង្សនោះទូលព្រះបង្គំជាខ្ញុំទុកនៅទីត្រង់ណោះ ពុំបានសម្លាប់ទេព្រះអង្គ ៗ ព្រះរាជត្រាស់ថា អ្នកឯងចូរទៅយកហង្សមក ៗ ព្រះពោធិសត្វក៏ទៅនាំហង្សមកដាក់តល់ទុកក្នុងព្រះរាជឈាន ៗ គ្រានោះ ព្រះរាជទ្រង់ត្រាស់សួរអំពីបណ្តាំបិតា លុះបានជ្រាបសព្វគ្រប់ប្រការ ទើបទ្រង់ត្រាស់ថា "ហៃមហាបុរស, ចូរអ្នកទទួលយកនូវសម្បត្តិទបរាជចុះ" ហើយទ្រង់ប្រគល់រាជសម្បត្តិពាក់កណ្តាល ៗ មហាបុរសក៏ទូលទាស់ព្រះរាជឧង្ការថា "បពិត្រព្រះរាជសម្ភារ, បិតារបស់ទូលព្រះបង្គំជាខ្ញុំ បានផ្តាំថា "ស្តេចណាឥតពិចារណា, កូនឯងកុំនៅក្រោមបង្គាប់ស្តេចនោះឡើយ", ឥឡូវនេះព្រះសម្មតិទេព ជាស្តេចឥតពិចារណា, ឲ្យគេសម្លាប់ទូលព្រះបង្គំជាខ្ញុំ ដែលជាមនុស្សមិនគាន់គួរដល់ការសម្លាប់, ទូលព្រះបង្គំជាខ្ញុំពុំនៅក្នុង

ដែនព្រះអង្គទេ", មហាសត្វទូលទាស់ព្រះរាជឱង្ការដូច្នេះហើយ ទើបពោលជាបទគាថាដូច្នេះថា:

យោ បុគ្គលោ ទោសជិនោ ន សហាយោ ទុក្ខប្បត្តោ
សុខិតោ យាជិយំ មិត្តំ ទីឃំ កាលំ ទុក្ខំ បត្តោ
យា ឥត្ថីបិ តិរិជា. ន ភរិយា ទុក្ខប្បត្តោ
សុខិតា យាតិ វិនាសំ ទីឃំ កាលំ ទុក្ខំ បត្តោ

បុគ្គលឯណា ជាជនកាចកាត្រក់, អ្នកផងមិនត្រូវយកជាសំឡាញ់ឡើយ, ព្រោះវានឹងនាំឲ្យដល់នូវសេចក្ដីទុក្ខ, គឺថាបើវាបានសុខហើយ អាចនឹងហ៊ានសម្លាប់មិត្ត ធ្វើមិត្តឲ្យដល់នូវសេចក្ដីទុក្ខអស់កាលជាយូរអង្វែងទៅ, ស្រីដែលមេម៉ាយបីដង អ្នកផងមិនត្រូវយកជាភរិយាឡើយ, ព្រោះវានឹងនាំឲ្យដល់នូវសេចក្ដីទុក្ខ, គឺថាបើវាបានសុខហើយ វានឹងនាំទៅកាន់សេចក្ដីវិនាស ធ្វើឲ្យដល់នូវសេចក្ដីទុក្ខអស់កាលជាអង្វែង; បុគ្គលឯណាប្រព្រឹត្តកន្លងធម៌ គឺលុះក្នុងអំណាចឆន្ទាគតិ ទោសាគតិ ភយាគតិ មោហាគតិ, បុគ្គលនោះនឹងសាបសូន្យបាត់យស ដូចជាព្រះចន្ទខាងរនោច, បុគ្គលឯណាមិនប្រព្រឹត្តកន្លងធម៌ គឺមិនលុះក្នុងអំណាច ឆន្ទាគតិ ទោសាគតិ ភយាគតិ មោហាគតិទេ, បុគ្គលនោះនឹងពេញដោយយសដូចព្រះចន្ទខាងខ្នើត, បពិត្រព្រះរាជា, ព្រះចន្ទ

រនោច  រមែងសាបសូន្យទៅមួយថ្ងៃបន្តិចៗដូចម្តេចមិញ, បុគ្គលដែលសមាគមគប់នឹងអសប្បុរស  ក៏ដូចជាព្រះចន្ទខាងរនោចដូច្នោះ; បពិត្រព្រះរាជា  ឯព្រះចន្ទខាងខ្នើត  រមែងចំរើនឡើងមួយថ្ងៃបន្តិចៗដូចម្តេចមិញ បុគ្គលដែលសមគប់នឹងសប្បុរស ក៏ដូចជាព្រះចន្ទខាងខ្នើតដូច្នោះ ។ មួយយ៉ាងទៀត ជាតិសត្វទឹកមានត្រីជាដើម ដែលធ្លាប់នៅក្នុងទឹទំនាប រមែងពុំត្រេកអរលើទួលសោះ ដូចម្តេចមិញ, ក៏ចិត្តរបស់ទូលព្រះបង្គំជាខ្ញុំ  ពុំបានលូតលាស់ស្រស់ស្រាយទៅរកការសេពគប់នឹងអសប្បុរសដូច្នោះដែរ,  បពិត្រព្រះជិនិន្ទពិនប្រជា,  ជាតិសត្វទឹកបូលបិត្តៈនៅក្នុងទឹក   ដែលខ្លួនធ្លាប់អាស្រ័យនៅយូរហើយយ៉ាងណា,  ទូលព្រះបង្គំជាខ្ញុំ  ក៏ពេញចិត្តចំពោះការសមគប់នឹងសប្បុរស   ដែលធ្លាប់សមគប់មកយូរហើយយ៉ាងនោះដែរ ។  ស្តេចឯណា  ផ្ចាញ់មនុស្សដែលមិនគួរផ្ចាញ់, ស្តេចនោះ ឈ្មោះថាស្តេចកំណាចកាចកាត្រក់; បុគ្គលឯណាផ្ចាញ់មិត្តសំឡាញ់របស់ឯង,  បុគ្គលនោះមិនឈ្មោះថាសំឡាញ់ទេ; ស្រីឯណាហ៊ានប្រច្ឆាអាក្រក់តតូច, ស្រីនោះមិនឈ្មោះថាភរិយាទេ;   ជនឯណាមិនចិញ្ចឹមមាតាបិតា, ជននោះមិនឈ្មោះថាកូនទេ;  ជនឯណាមានចិត្តមិនស្ងប់រម្ងាប់, ជននោះមិនឈ្មោះថាសប្បុរសទេ;  ជនឯណាមិនគោលទូវធម៌, ជននោះឈ្មោះថាអសប្បុរស ។

កាលបើព្រះពោធិសត្វ និយាយយ៉ាងនេះហើយ, ព្រះរាជាទ្រង់ត្រាស់ថា បពិត្រមហាបុរស, ខ្ញុំនឹងតាំងនៅក្នុងឋានៈរបស់អ្នកឯងដោយពិត, សូមអ្នកនៅក្នុងទីនេះចុះ ។ ព្រះពោធិសត្វ ក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព, ពាក្យបិតារបស់ទូលព្រះបង្គំជាខ្ញុំផ្ដាំយ៉ាងណា ទូលព្រះបង្គំជាខ្ញុំធ្វើតាមយ៉ាងនោះពុំឲ្យឃ្លៀងឃ្លាត, ឯព្រះរាជឱង្ការរបស់ព្រះអង្គ សូម្បីមួយព្រះឱស្ឋ ឬពីរព្រះឱស្ឋ ក៏ទូលព្រះបង្គំជាខ្ញុំពុំធ្វើតាមដែរ ។ ព្រះរាជាទ្រង់ត្រាស់តទៅទៀតថា បពិត្រមហាបុរសដ៏ចំរើន, បួរអ្នកឯងជាស្ដេចសោយរាជ្យប្រកបដោយធម៌ចុះ កុំទៅប្រទេសដទៃឡើយ ។ មហាបុរសក្រាបបង្គំទូលថា "បពិត្រព្រះសម្មតិទេព, ទូលព្រះបង្គំជាខ្ញុំពុំនៅក្នុងនគររបស់ស្ដេច ដែលធ្វើការឥតពិចារណាទេ", ថាតែប៉ុណ្ណេះក៏សូមឲ្យព្រះរាជាអត់ទោសខ្លួន ហើយចេញក្រសទៅឯនគរតក្កសិលា ទៅសម្រាន្តសម្រាកអាត្មានៅលើថ្មដ៏លសិលា នាព្រះរាជឧទ្យាន ។ ខណៈនោះ ព្រះរាជាក្រុងតក្កសិលា ទ្រង់សោយព្រះទិវង្គតលេតព្រះជន្មទៅ ។ ពួកអាមាត្យក៏បានរៀបពិធីបុណ្យបូជាព្រះបរមសពអស់ ៧ ថ្ងៃ; ដល់ថ្ងៃគំរប់ ៧ អាមាត្យទាំងនោះ ក៏បានប្រជុំមហាសន្និបាតប្រឹក្សាគ្នាថា ឥឡូវនេះ យើងឥតពីព្រះរាជាទៅ មិនអាចរក្សានគរបានទេ, ចុះយើងនឹងធ្វើដូចម្ដេច? ។ គ្រានោះ មានអាមាត្យអ្នកឆ្លាតម្នាក់និយាយឡើងថា អស់លោកទាំងឡាយ, គួរតែយើងទាំងឡាយ ទឹមបុស្សរថ បញ្ជូនទៅ,បើបុស្សរថទៅសំដៅផ្ទះអ្នកណាអ្នកនោះឯងហើយជាស្ដេច ។ អាមាត្យទាំងនោះ ក៏ទឹមបុស្សរថ

ដោយសេះសទ្ធព ៤ គូ និយាយប្អូនស្អូនថា "សូមបុស្សរថចូលទៅកាន់ផ្ទះអ្នកមានបុណ្យ ដែលគួរជាស្តេចម្ចាស់យើង" ដូច្នេះហើយលែងបុស្សរថនោះទៅ ។ បុស្សរថនោះប្រទក្សិណព្រះរាជនិវេសន៍ ឥតទៅកាន់ផ្ទះនរណាមួយសោះ, ចេញទៅខាងក្រៅនគរ ហើយចូលទៅក្នុងឧទ្យាន ។ អាមាត្យទាំងអស់ ក៏ផ្គងត្រូវ្យត ទ្រព្រតប់បែបហែទៅតាមក្រោយបុស្សរថ ។ បុស្សរថ ប្រទក្សិណផែនថ្មមង្គលសិលាដែលព្រះពោធិសត្វសម្រាក ហើយឈរទន្ទឹងថ្កល់នៅកន្លែងនោះ ។ គ្រានោះបុរោហិត បានឃើញលក្ខណៈត្រង់ព្រះបាទមហាបុរស ក៏និយាយឡើងថា "បុរសនេះ ជាអ្នកប្រាជ្ញ អាចសោយរាជ្យក្នុងទ្វីបទាំង ៤ មានទ្វីបតូច ៨ ពាន់ជាបរិវារបាន", ទើបបុរោហិតនិយាយទៅកាន់មហាបុរសថា រាជសម្បត្តិរបស់ព្រះអង្គដល់មកហើយ, សូមព្រះអង្គសោយរាជ្យចុះ ។ ព្រះពោធិសត្វឮពាក្យនោះហើយសួរថា ស្តេចរបស់អ្នកទាំងឡាយ ឥតព្រះរាជបុត្រ ឥតព្រះរាជវង្សានុវង្សទេឬអ្វី? ។ អាមាត្យទាំងឡាយឆ្លើយថា គ្មានទេព្រះអង្គ ។ ព្រះពោធិសត្វសួរទៀតថា ចុះអ្នកទាំងឡាយគាប់ចិត្តចំពោះខ្ញុំ ព្រមចិត្តគំនិតគ្នាហើយឬ? ។ អាមាត្យទាំងអស់ក៏ឆ្លើយព្រមគ្នាឡើងថា បពិត្រព្រះសម្មតិទេព, ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា គាប់ចិត្តចំពោះព្រះអង្គ ឥតមាននរណាមួយយល់ទាស់ឡើយ; សូមទ្រង់ព្រះមេត្តាប្រោស ទទួលសោយរាជសម្បត្តិកុំប្រកែកឡើយ ។ ព្រះពោធិសត្វ ក៏ទទួលព្រម ។ បុរោហិតមានសេចក្តីសោមនស្ស បានរៀបចំអភិសេកព្រះពោធិសត្វក្នុងទីនោះតែម្តង ហើយអញ្ជើញព្រះ

ពោធិសត្វឲ្យឡើងគង់លើបុស្សរថ នាំចូលទៅកាន់ព្រះនគរ ។ បណ្ដាជនទាំងអស់នោះក៏ផ្គងតូរ្យតន្ត្រីឡើង អ្នកខ្លះនៅខាងមុខ អ្នកខ្លះនៅខាងក្រោយ ហែហមតាមលំដាប់លំដោយចូលទៅក្នុងព្រះនគរ ។ ព្រះពោធិសត្វទ្រង់សោយរាជសម្បត្តិប្រកបដោយធម៌ ។ តាំងពីថ្ងៃនោះមកទ្រង់ឲ្យធ្វើសាលាទាន ៦ ខ្នង គឺទៀបទ្វារនគរទាំងបួន ៤ ខ្នង ត្រង់ពាក់កណ្ដាលនគរមួយខ្នង ទៀបទ្វារព្រះរាជនិវេសន៍ ១ ខ្នង ហើយទ្រង់បំណាយព្រះរាជទ្រព្យ ៦ សែនកហាបណៈ ឲ្យជាទានដល់អ្នកកំសត់ទុគ៌តរាល់ៗថ្ងៃ ។

ចំណែកខាងស្រីជាប្រពន្ធដើម និងបុរសជាសំឡាញ់របស់ព្រះពោធិសត្វនោះ បានយកគ្នាជាប្ដីប្រពន្ធ នៅរួមសំពាសជាមួយគ្នា ជាមនុស្សមិនដែលធ្វើបុណ្យកុសលអ្វីបន្តិចបន្តួចសោះ, ប្រព្រឹត្តធ្វើតែអំពើបាបប៉ុណ្ណោះ, ក៏ចុះធ្លាក់ខ្លួនជាអ្នកកំសត់ទុគ៌តទាល់ក្រ ។ ថ្ងៃមួយបុរសនោះនិយាយនឹងភរិយាថា ព្រះរាជាក្នុងនគរតក្កសិលា ព្រះរាជទានទ្រព្យសម្បត្តិដល់អ្នកកំសត់អនាថាច្រើនណាស់, បើដូច្នេះមានតែយើងទៅសូមទានព្រះអង្គគ្រាន់នឹងចិញ្ចឹមជីវិត ។ ជនទាំងពីរនាក់នោះ ក៏ទៅឯនគរតក្កសិលា, ដល់ទៅសាលាទានរបស់ព្រះរាជា ក៏ព្រះអង្គទ្រង់ស្គាល់ច្បាស់ ហើយទ្រង់ត្រាស់សួរថា នែអ្នកទាំងពីរនាក់, អ្នកឯងនាងឯងជាប្ដីប្រពន្ធនឹងគ្នាឬ? ។ ជនទាំងពីរនាក់ ក្រាបបង្គំទូលថា ព្រះករុណាថ្លៃវិសេស ។ ទើបព្រះរាជាទ្រង់ត្រាស់បង្គាប់រាជបុរសទាំងឡាយថា នែហ្ន៎យ, ភ្នាក់ងាររាជការ, ចូរអ្នកទាំងឡាយចាប់អានេះមេនេះចង

ភ្ជាប់គ្នា ហើយបណ្ដេញទៅនគរដទៃឯណោះទៅ ។ រាជបុរសទាំងឡាយ ក៏ទទួលធ្វើតាមព្រះរាជឱង្ការ ។ ព្រះមហាសត្វ ក៏ប្រព្រឹត្តធ្វើបុណ្យទានមានសភាពដូច្នោះជាដរាបតមកទៀត ។

តមត្ថំ បកាសេន្តោ សត្ថា អាហ កាលព្រះសាស្ដាទ្រង់ប្រកាសសេចក្ដីនោះ ទ្រង់ត្រាស់ថា

គ្រានោះ ព្រះបាទតក្កសិលាដែលបុញ្ញកម្មនាំមកហើយ ទ្រង់
បានជាស្ដេចសោយរាជ្យប្រកបដោយសិរីថ្លៃថ្លា មានឫទ្ធិមាន
បុណ្យ មានប្រាជ្ញា មានញាតិ មានយស មានកំឡាំង
មានតេជះជាច្រើន ជាស្ដេចទ្រទ្រង់នូវបុណ្យ ជាស្ដេច
ដ៏ប្រសើរគ្រប់គ្រងនូវសិរីរាជសម្បត្តិ ។

អគ្គសម្ដេចព្រះបរមសាស្ដាចារ្យជាម្ចាស់ ទ្រង់នាំព្រះធម៌ទេសនានេះមកសំដែងហើយ ទ្រង់ប្រកាសនូវសច្ចៈទាំង ៤ ប្រការ, បណ្ដាជនជាច្រើនគ្នា ក៏បានសម្រេចសោតាបត្តិផលជាដើម ។ ទើបសម្ដេចព្រះជិនស្រីទ្រង់ប្រជុំជាតកត្រាស់សំដែងថា

មាតាព្រះពោធិសត្វក្នុងកាលនោះ បរិវត្តមក បានមក
កើតជាព្រះនាងមហាមាយា, បិតាបានជាព្រះបាទសុទ្ធោទនៈ,
បុរសដែលប្រទុស្ដចំពោះព្រះអគ្គ បានជាទេវទត្ត, ភរិយា
ទ្រុស្ដសីល បានជានាងចិញ្ចមាណវិកា, ឆ្មាំទ្វារទាំង ៤
បានជាព្រះថេរៈអ្នកទទ្រង់នូវធុតង្គ, ពួកបរិសទ្យក្រៅពី

នោះ បានជាពុទ្ធបរិសទ្យទាំងអស់; ឯព្រះបាទទុក្កមានិក នោះ បានត្រាស់ជាសម្មាសម្ពុទ្ធ គឺតថាគតដែលជាលោកនាថហ្នឹងឯង; អ្នកទាំងឡាយចូរទ្រទ្រង់ចាំទុកនូវជាតកយ៉ាងនេះចុះ ។

ចប់ ទុក្កម្មានិកជាតក ទី ១៣ ។

## ធម៌ ៤ សម្រាប់បុគ្គល ២ ពួក

ដេកលើផែនដី ១ ប្រព្រឹត្តធ្វើល្អ ១ សភាពជាអ្នកស្គាំងស្គម ១ បរិភោគបន្តិចបន្តួច ១ ធម៌ទាំង ៤ ប្រការនេះ តែងកើតមានចំពោះតែបុគ្គល ២ ពួក គឺ ខ្ញុំបំរើគេ ១ តាបស ១ តែបើពោលដោយវិសេស ពួកមួយកើតបានជាអាក្រក់ ពួកមួយកើតបានជាល្អ ។

ខ្ញុំបំរើគេតែងធន់ទ្រាំនូវសេចក្តីទុក្ខទាំងឡាយ មានត្រជាក់នឹងក្តៅជាដើម តែសេចក្តីទុក្ខដើម្បីប្រាថ្នាទ្រព្យទាំងឡាយនេះបន្តិចបន្តួចទេ ថាបើខ្ញុំបំរើនោះមិនលះបង់ពោលធម៌ ។

បញ្ចត្ថ្រ:

ផ្នែកអក្សរសាស្ត្រ

# រឿងសៅរ៍សោយ

(សិសោរជាតក)

## ព្រះមហាឧត្តមវិជ្ជា ផលញ្ញាណោ ប៉ុង-ប៉ម

អាចារ្យសាលាបាលីរងវត្តបទុមវតី ក្រុងភ្នំពេញ

រៀបរៀងតាមតម្រាយសាស្ត្រាស្លឹករឹត

(តពីខ្សែលេខ ១ ឆ្នាំ· ១៩៥៥)

---

ព្រះបាទក្សត្រា ទំទប់អាត្មា សួរថា "ហេតុអ្វី បានជាពាក្យដំខ្លួនខ្ញុំនេះខ្លី ពុំត្រូវសេចក្ដី ដល់តិចឡើយហោង ៗ បើដេរបើពាក្យ គួរសួរនិយាយ ឲ្យដឹងដើមទង មកពាក្យយ៉ាងហ្នឹង មិនដឹងខុសត្រង់ ពុំសមទំនង ឥតហេតុបច្ច័យ" ៗ

អ្នកទាំង៥នោះ ព្រះស្ដេចថាហ្នោះ រឹងទឹងខ្លាំងក្រៃ ដេរថា "អាពាល បណ្ដាលចង្រៃ មឹងបេះកែខ ថាអញពាក្យខុស ៗ ថាពាក្យមិនត្រូវ បើហ្នោះឥឡូវ មើលទៅខ្លួនចុះ ថាពាក្យមិនត្រូវ ពាក្យទៅពាក្យខុស គ្រាន់តែរលុស ខ្លួនមឹងហ្នឹងនៃ ៗ អាចោរបំណាច់ លួចគោមកកាប់ ឈាមជាប់នៅដៃ លួចគោអញមក អញរកស្មើរក្សែ ឥឡូវនេះនៃ ឃើញមឹងសម្លាប់" ៗ

ទើបពុទ្ធង្កុរ មានព្រះបន្ទូល និយាយប្រាយប្រាប់ "ខ្ញុំមិនចោរលួច ដើរលួចគោកាប់ អ្នកមកប្រចាប់ ខុសច្បាប់ព្រះដើយ ៗ ខ្ញុំមិនបានលួច

ទ្រព្យអ្នកកាន់តួច គិតតួចសោះឡើយ ម្ដេចអ្នកដាក់ប្រែ វាយខ្ញុំអ្នកអើយ

ខ្ញុំមិនចោរឡើយ ពិតជាត្រង់ស្មោះ" ។

បុរស ៥ នាក់ បានស្ដាប់សព្វជាក់ រឹងទឹងទ្រគោះ ដេរថា "អាចួត មកអួតថាស្មោះ ថាអ្វីដូច្នោះ អញឃើញទីងក្លែក ។ ឃើញពិតទាំងអស់ សាច់ឈាមស្រស់ៗ ទាំងពោះវៀនស្បែក ពេញទាំងថ្នាំងធំ នៅទំប្រកែក មាត់រឹងដដែក ប្រកែកកៃខែ" ។

ព្រះបាទសិរីសោរ៍ មានបន្ទូលទៅ ថា "ខ្ញុំសព្វថ្ងៃ មិនមែនជាចោរ លួចគោឡើយនៃ ខ្លួនខ្ញុំសព្វថ្ងៃ អាស្រ័យទីងវត្ត ។ ខ្ញុំមិនជាចោរ ពេលនេះខ្ញុំស្មោរ ក្រាក់ខ្ទរអម្ពត់ ដែលក់ចីពរ វត្តពន្ធប្រាកដ ដោយចិត្តកំណត់ ទីងបព្វជ្ជា ។ បួសធ្វើជាសង្ឃ សំណាក់ក្រែកត្រង់ ក្នុងពុទ្ធសាសនា បើមិនជឿក្បួរ ទៅសួរលោកភ៉ា កុំអ្នកមកថា ខ្ញុំលួចគោកាប់ ។ គួរពិចារណា ឲ្យជាក់សិនភ៉ា សឹមមកប្រចាប់ ដាក់ចុះលោភវាយ យល់ឆាយពុំគាប់ ពុំត្រូវដោយច្បាប់ ទំលាប់ពីទាយ ។ ខ្លួនខ្ញុំត្រង់ស្មោះ អ្នកឥតសួរសោះ លោស្ទុះមកវាយ បើមិនជឿទេ អ្នកទៅនាយៈ សួរលោកទាំងឡាយ នៅក្នុងវត្តស្រាប់" ។

បុរស ៥ នាក់ ស្ដែងស្ដាប់សព្វជាក់ ថា "អើ! ចូរចាប់ វាជាណាស់ណា លោកជាសង្ឃស្រាប់ យើងទឹងសួរច្បាប់ វក្រិត្យវិន័យ" ។ ថាហើយចូលចាប់ ចងជាប្រញាប់ កន្ត្រាក់ដឹកដៃ បណ្ដើរសំដៅ ឆ្ពោះទៅវិវ ដល់លោកហើយនៃ ទូលតាមទំនង ។ "បពិត្រករុណា! ខ្ញុំទូលពុទ្ធដីកា ឲ្យជ្រាបជាម្ដង ដ្បិតលោកជាសង្ឃ ទ្រង់ដោយគន្ធន

ដំណើរនេះហោង សូមទានចាំស្ដាប់ ។ គោខ្ញុំវាបាត់ ខ្ញុំស្វែងខ្វេងខ្វាត់
ស្កាត់ដើរស្មើរស្មោប ឥឡូវឃើញចោរ លួចគោមកកាប់ យើងខ្ញុំប្រចាប់
ប្រាប់ថាខ្លួនត្រង់ ។ ហើយប្រាប់យើងថា ឲ្យយើងនេះណា ទៅសួរ
លោកសង្ឃ ពោះទើបខ្ញុំចាប់ នាំចាប់មកត្រង់ តើលោកគ្រប់អង្គ យល់
ម្ដេចទៅក៏? ។ អស់ភិក្ខុសង្ឃ ស្ដាប់ពិតផិតផង់ គ្រប់អង្គហើយណា
ទើបប្រាប់រឿងពិត ដោយឥតមុសា ថា "មនុស្សនេះណា មិនជា
ចោរសោះ ។ ចូរញោមចាំស្ដាប់ អាត្មាសារសព្ទ ប្រាយប្រាប់រឿង
នោះ ដោយចំត្រមត្រិត្យ ជាពិតចំពោះ ប្រាប់អ្នកជាក់ស្មោះ មិនលោះ
ឡើយណា ។ នេះជាមហាក្សត្រ វង្វេងវង្វែងព្រាត់ ពីរដ្ឋសីមា ដើរ
មកម្នាក់ឯង វង្វេងមាគ៌ា ពុំដឹងទិសា ទុក្ខាខ្លាំងក្រៃ ។ ដើរមកហូរហៃ
កំលោស្រាប់តែ អ្នកស្រែចំរៃ ប្រទមកុដសុវណ្ណ ព្រះខ័នពិជ័យ ទីង
អាជានេយ្យ ទាំងបីទៅហ្មត់ ។ ឥឡូវជ្រះថ្លា ចិត្តគិតប្រាថ្នា បួសជា
ប្រាកដ តែកាលដឹងថា ចីវរពាំខ្សត់ ក៏ដោះសំពត់ ក្បួសាយ៉ាងឆាប់ ។
ឲ្យកាត់ចីវរ យើងក៏ត្រេកអរ នាំគ្នាប្រញាប់ កាត់ដេរស្រេចស្រួល
ក៏ចូលបង្គាប់ ឲ្យស្ដេចប្រញាប់ ជ្រលក់អម្ចត់ ។ អ្នកស្ដេចនេះក៏ យក
ចីវរស ទៅធ្វើក្រៅវត្ត រឿងពិតដូចេះ ទើបយើងកំណត់ អ្នកនេះប្រាកដ
ពុំជាចោរ ។ ពុំមែនអ្នកលួច ដើរទៅលបលួច គោអ្នកឡើយណា
គឺពិតជាក្សត្រ ប្រាសព្រាត់រដ្ឋា មកសូមអាត្មា នៅជាពំនាក់ ។

បញ្ច ជនា បុរស ៥ គ្នា បានស្ដែងស្ដាប់ជាក់ ពាក្យសង្ឃរ៉ាយរ៉ាប់
ប្រាយប្រាប់ជាក់ អ្នកទាំង ៥ នាក់ រំងំខឹងឥតបី ។ ហើយតិះ

ដំណើរនេះហោង សូមទានចាំស្ដាប់ ។ គោខ្ញុំបាត់ ខ្ញុំស្វែងខ្វែងខ្វាត់ ស្កាត់ដើរស្មើរស្មោប ឥឡូវឃើញចោរ លួចគោមកកាប់ ឃើងខ្ញុំប្រញាប់ ប្រាប់ថាខ្ទួនត្រង់ ។ ហើយប្រាប់យើងថា ឲ្យយើងនេះណា ទៅសួរលោកសង្ឃ ហោះទើបខ្ញុំតាប់ នាំគាប់មកត្រង់ តើលោកគ្រប់អង្គ យល់ម្ដេចទៅក៏? ។ អស់ភិក្ខុសង្ឃ ស្ដាប់ពិតថ្កិតថ្កង់ គ្រប់អង្គហើយណា ទើបប្រាប់រឿងពិត ដោយឥតមុសា ថា "មនុស្សនេះណា មិនជាចោរសោះ ។ បួរញោមចាំស្ដាប់ អាត្មាសារសព្វ ប្រាយប្រាប់រឿងនោះ ដោយចំត្រមត្រិត្យ ជាពិតចំពោះ ប្រាប់អ្នកដាក់ស្មោះ មិនលោះឡើយណា ។ នេះជាមហាក្សត្រ វង្វេងវង្វងព្រាត់ ពីរដ្ឋសីមា ដើរមកម្នាក់ឯង វង្វេងមាគ៌ា ពុំដឹងទិសា ទុក្ខាខ្លាំងក្រែ ។ ដើរមកយូរហៃ កំលោស្រាប់តែ អ្នកស្រែចង្រៃ ប្ដូរមកុដសុវណ្ណ ព្រះខ័នពិជ័យ នឹងអាជានេយ្យ ទាំងបីទៅហ្នត់ ។ ឥឡូវជ្រះថា ចិត្តគិតប្រាថ្នា ប្ដូរជាប្រាកដ តែកាលដឹងថា ចិវរពាំឡត់ ក៏ដោះសំពត់ ក្លូសាយ៉ាងឆាប់ ។ ឲ្យគាត់ចិវរ យើងក៏ត្រេកអរ នាំគ្នាប្រញាប់ កាត់ដេរស្រេចស្រួល ក៏ខ្ទួលបន្ទាប់ ឲ្យស្ដេចប្រញាប់ ផ្លាស់អង្គត់ ។ អ្នកស្ដេចនេះក៏ យកចិវរស ទៅធ្វើកៅវត្ត រឿងពិតដូចេះ ទើបយើងកំណត់ អ្នកនេះប្រាកដពុំជាចោរ ។ ពុំមែនអ្នកលួច ដើរទៅលបលួច គោអ្នកឡើយណា គឺពិតជាក្សត្រ ប្រាសព្រាត់រដ្ឋា មកសូមអាត្មា នៅជាតំនាក់ ។

បញ្ចជនា បុរស ៥ គ្នា បានស្ដែងស្ដាប់ជាក់ ពាក្យសង្ឃក៏ឈប់ ប្រាយប្រាប់ជ្រៀកក់ អ្នកទាំង ៥ នាក់ រង់ខ្វង់ឥតបី ។ ហើយគេះ

ដៀលថា "សង្ឃអ្វីប្លេះណា បេះតែស្រដី មានពាក្យអាក្រក់ កុហក ឥតបើ រាល្អតិចអី បួសធ្វើជាសង្ឃ ។ តាមតែបេះថា ស្រដីមុសា អួតថាខ្លួនត្រង់ ទឹងបួសធ្វើអ្វី ខូចបំពារស្បង់ កាន់ក្រិត្យមិនគង់ បង់បាយបាសក ។ បំណាច់ធ្វើសង្ឃ ស្រដីឲ្យត្រង់ កុំបង់កុហក សង្ឃនេះជ្រោកជ្រាក កាន់ពាក្យអាក្រក់ អន់ជាងបាសក គេហៅសង្ឃ សោ ។ បួសសោះថៃខាំ បួសហើយថែខាំ ហោរទុកល្អបគោ ស្មោរ បែកគ្នាស៊ី ជាទីសើចហោ គេឃើញដែរនោ នៅថាមនុស្សជា" ។

បុរស៥នោះ តិះដៀលទ្រគោះ អស់សង្ឃនានា ដោយចិត្តខឹងខេរ តាមតែនឹងថា ផ្សេងៗពីគ្នា រូបតែពីមាត់ ។ ថាហើយស្ទុះទៅ ចាប់ ព្រះសិរសោរ៍ ខ្ទះបង់ខ្ទះទាត់ ទង់ទាញគ្រាក់ ចំណាក់វាយរាត់ អង្គព្រះមហាក្សត្រ ទុក្ខកាត់ស៊ើរក្ស័យ ។ គេធ្វើទុក្ខទោស ពុំមាន សន្តោស ប្រាណក្រោសឡើយនៃ គេវាយគេធាក់ ប៉ុកប៉ាក់ខ្ញាំងក្រែ អួសទង់ទាញដៃ ទៅកាលណោះណា ។

សាមណេរតូចនោះ យល់ហេតុកើតទោះ ស្រណោះក្សត្រា ទប់យំពុំបាន ប្រះប្រាណសោកា គន់គិតអនិច្ចា សង្វេគពេកក្តាត់ ។ ស៊ើរបែកទ្រូងខ្វាក ជា ៧ ភាគ អួលថើមប្រមាត់ រឹងជាផ្កាចិត្ត អាណិតមហាក្សត្រ ទើបស្រែកខាំងឃាត់ អង្វរសូមទោស ។ ថា "ឱ! ញោមអើយ! កុំធ្វើទោសឡើយ សូមមេត្តាប្រោស អាត្មា បិណ្ឌបាត សូមអ្នកសន្តោស កុំបើធ្វើទោស អាត្មាធានា ។ សូម បានប្រណីប្រោស អាត្មាសូមទោស សន្តោសលែងភា៎ បើសិនជាបាត់

អាត្មាជានា អ្នកចាប់អាត្មា ធ្វើទោសតាមចិត្ត ៗ អាត្មាជំនួសទទួលទោសជួស សុំដោះជីវិត បើស្តេចគេចប្រាណ ពុំបាននៅទិត្យខ្លួនអាត្មាពិត រង់ជួសស្រាប់ហើយ ៗ

បុរស ៤ នាក់ ស្តែងស្តាប់សព្ទជាក់ នូវពាក្យនេនធ្វើយ ថាយកខ្លួនតាង ជំណាងប្តោះហើយ ចិត្តទន់ស្រទន់ស្បើយ រហើយក្រោធា ៗ ហេតុតែអាណិត សាមណេរមានចិត្ត យកខ្លួនធានា អ្នកទាំង ៤ នោះព្រមដោះពជា មានចិត្តសទ្ធា សាមណេរនោះឯង ៗ ហើយប្រាប់សង្ឃសត្យ ថា "លោកកន្សែត ប្រយ័ត្នប្រយែង កុំបីសមសេពមនុស្សបែបនេះឯង ជាចោរត្រូវស្បែង ហ៊ានលួចគោកាប់ ៗ ពីថ្ងៃនេះទៅ បើលោករឹងនៅ សេពសមពុំស្តាប់ កុំបន្ទោសយើង ថាយើងមិនប្រាប់ គនិបានទុក្ខធាប់ ចូរស្តាប់ឲ្យច្បាស់" ៗ

ថារួចកាលណា នាំគ្នាយាត្រា លីលាទៅផ្ទះ ក្រោយនោះពជាវេទនាខ្លាំងណាស់ អស់កិត្តិកេងចាស់ រូតរះរក្សា ៗ ផងព្រះសិសៅរ៍គ្រាហ៍នាំយកទៅ លំនៅសាលា រកដាំទឹកក្តៅ ថ្នាំក្រៅក្នុងណា ថែទាំរក្សា ពុំជិនធ្លូនឡើយ ៗ យូរតិចទៅថ្កាន ព្រះមហាក្សត្រក្សត្តកំបានសះស្បើយ ជាចាកពេគា ធម្មតាស្រេចហើយ ក្សត្រក្សត្តគ្រាណាត្រើយ នៅជាសុខហោង ៗ

កិត្តុផងគ្រប់គ្នា យល់ព្រះពជា ជានាហ្មត់ហ្មង ទើបមានពុទ្ធដីកាបរោសាសង តាមដោយទំនង ថា "ហៃមហាពជ! ៗ អាចក្តីនេះណាគិតពិចារណា យល់ថាមិនអាច អះអាងធានា តាំពារមហាពជ មនុស្ស

ឯងប្រែនកាច ពុំខ្លាចខុសត្រូវ ។ ឥឡូវនេះគេ វាយលេងទទេ ឲ្យជាអាស្រូវ ពុំដឹងគិតម្តេច ធ្វើម៉េចឥឡូវ ដ្បិតគេក្រៅផ្លូវ ឃាត់ទៅពុំបាន ។ ដ្បិតខ្លួនជាសង្ឃ ប្រាប់ប្រាមតាមត្រង់ គេរឹងបំពាន ខំជួយគ្រប់យ៉ាង ឲ្យខាងតែបាន ប្រាប់គេប៉ុន្មាន គេគ្មានជឿឡើយ ។ ហេតុនេះតទៅ បើនឹងរឹងនៅ ក្រែងគេមិនស្បើយ គេមកកាលណា យល់មហារាជហើយ ពុំទាន់ស្រន់ស្បើយ គេធ្វើទុក្ខទៀត ។ អាត្មាយល់ថា គួរមហាក្សត្រា លីលាឈប់ធ្មៀត រកទីលំនៅ ឯក្រៅទៅទៀត ក្រែងគេលែងបៀត បានសុខតទៅ” ។

ស្តាប់សព្វគ្រប់ហើយ គិតពុំលង់ឡើយ បរមបមពៅ លាលោកគ្រប់អង្គ ក្នុងទ្រង់ហ្មងសៅ លាលោកចាកទៅ ដោយនូវអាល័យ ។ ហើយទ្រង់ត្រាស់ថា “សូមទានករុណា នៅចុះម្ចាស់ថ្លៃ ឲ្យបាសុខសាន្ត សម្រាន្តព្រះទ័យ ប្រាសចាកភេគភ័យ ទោសពៀរតទៅ” ។

សាមណេរនោះណា យល់ក្សត្រយាត្រា ពុំបិតនិត្យនៅ កុក្កុលអួលចិត្ត អាណិតបមពៅ យំយោគសោកសៅ ក្តួលក្តៅកន្លង ។ ហើយក៏លីលា តាមជូនរាជា ដល់នារបង ឈរយំទីនោះ មើលផ្តោះប្លាស់ប្លង់ លុះលុទកន្ទង ប៉ាំងបាត់ផុតភ្នែក ។ ទើបវិលយាត្រា ចូលវត្តអាត្មា សោកាអនេក ឯព្រះរាជា លីលាឯងឯក ខ្សឹកខ្សួលស្ទើរបែកសព្វោកទេព ។ សង្រែងសង្រៃ ក្សត្រាអាល័យ សាមណេរខ្វាំងក្វា ពុំអាចបរលី ពីទីនោះណា ទើបគង់សោកា នាទីនោះឯង ។ កាល

ទ្រង់ចិន្តា ដល់អង្គអាត្មា រឹងជាចំបែង ខ្សឹកខ្សួលក្តួលក្តៅ ហ្មងសៅ
កន្សែង សោកាឡាថ្ងូង ពិលាបខ្សួញថា ៖

"ឱ! គួរសង្វេគ អាស្សូរខ្លួនពេក កម្មប្លែកប្រេះណា ពីមុនអញធ្វើ
អំពើអ្វីក៏ ទើបអនាថា កំព្រាប្រះហោង ៗ ខ្លួនរកទោសគ្មាន ណោ
ស្រោប់តែមាន ទោសទ័ណ្ឌជាម្តង ពុំគួរគេពាយ មើលងាយឡើយហោង
ណោស្រោប់តែរង អ្នកផងមើលងាយ ៗ ទីពុំសមដេក ខ្លួនឥតដំណេក
កំដេកផ្តួលកាយ អាហារនានា ឃើញជាគួរណាយ តែឃ្លានមាល្បាយ
បរិភោគសោះឃ្លាន ៗ ពីមុនមកក្បូរ ពុំធ្លាប់ដើរផ្លូវ ឥឡូវត្រូវឈាន
ដើរស្មូងឯងឯក រែកលុកលុកពន ពុំដឹងរងឋាន ទៅហាន់ទីណា ៗ
នរណាទៅអើយ ដែលឃើញយើងហើយ មានចិត្តមេត្តា នរណាគេ
ធ្វៀត ជាញាតិសខា មិត្តភក្តិអាត្មា គ្រាន់ជាពំនាក់ ៗ នរណាទីងជីង
ថាខ្លួនយើងនឹង ជាអង្គស្តេចចក្រ នរណានឹងក្រែង ខ្លួនឯងតែម្នាក់
កម្មអ្វីឥតអាក់ ឥតឯរដោះ ៗ ទៅទៅទីណា ទីនោះកើតជា ភ័យកិត
ឥតលោះ កើតភ័យទីណា ទុក្ខាទីនោះ កាលបើដូច្នោះ តើរូបអាត្មា ៗ
ទៅពឹងអាស្រ័យ ទីងអ្នកដទៃ រូបណាទៅក៏ គ្រាន់បានភោជន
សម្រន់គោត្តា គ្មានឃើញនរណា មេត្តាយើងឡើយ ៗ បើដូច្នេះនៃ
តើយើងអាស្រ័យ នរណាទៅអើយ គ្រាន់បានភោជនា គោត្តាជា
ត្រើយ បើគ្មានបានហើយ គង់តែក្សិណក្ស័យ ៗ ក្តស្លាប់ស្មែងសល់
ពុំគួរនឹងយល់ មកដល់ហើយនៃ ព្រោះខ្វះភោជនា គោត្តាអាស្រ័យ
កម្មអ្វីខ្ញុំនៃក្រៃ ឥតបីស្រាកស្រាន្ត ៗ បើអាយុបុណ្យ យើងធ្វើពីមុន

ជាទុននៅមាន អាហារភោជន៍ផង យើងគង់ទីងបាន ប្រសិនបើគ្មាន គង់ស្លាប់ពិតហើយ ។ ទុក្ខទោសនេះក៏ ពុំមាននរណា មកធ្វើឲ្យឡើយ ខ្លួនអញទេតើ បានធ្វើជាត្រើយ ខ្លួននេះឯងហើយ ទីពឹងផងខ្លួន ។ នរណានឹងជា ទីពឹងនរណា ពិតជាគ្មានក្បួន នរណាធ្វើកម្ម អ្វីត្រាំ កង់ខ្លួន អ្នកនោះត្រូវចួន សោយសួនផលនោះ ។ សត្វលោកគប់កាយ កុំបីមើលងាយ នូវកម្មឲ្យសោះ ថាកម្មស្តួចស្តើង ដែលយើងធ្វើនោះ ពុំអាចមកឆ្ពោះ ឲ្យផលយើងឡើយ ។ ព្រោះកម្មនោះណា ទោះតិច ម្តេចម្តា ឲ្យតែធ្វើហើយ គង់តាមឲ្យផល ឥតសល់ខានឡើយ ទុក្ខតាម គ្មានស្បើយ ហើយឥតកំណត់ ។ ដូចយើងនេះណា ដែលរងទុក្ខា កំព្រាកំសត់ ព្រោះកម្មដែលយើង ធ្វើឡើងប្រាកដ ចួបចំកំណត់ ឲ្យទុក្ខឥតស្រាន្ត" ។

លុះស្ងាំងសោកា ស្តេចក្សត្រយាត្រា ដោយព្រៃដងដាន ទៀយ និត្យល្ហិតល្ហៃ ព្រះទ័យពុំក្សាន្ត ទុក្ខពិតឥតមាន លោះខានឡើយនៃ ។ ស្តេចទ្រង់កន្សែង អនិច្ចាថាថែង កណ្តាងកង់ព្រៃ លុះព្រះរាជា បើលា យូរក្រៃ សាយណ្ហក្សត្រថ្ងៃ ដល់ស្រុក១ណា ។ ឃើញផ្ទះគេនៅ ពាលស្រែឯក្រៅ ចម៉ៅទៅគិតថា "អញនឹងចូលទៅ លំនៅនេះណា សូមគេនិទ្រា សម្រាកដេកនៅ" ។ លុះគិតច្នោះហើយ ពិតពុំលង់ ឡើយ ត្រាណត្រើយចូលទៅ ឃើញដូនចំណាស់ តាចាស់និត្យនៅ តែគ្នាឯក្រៅ ប្រពន្ធនឹងប្តី ។ សម្តេចសិសោរ៍ មានបន្ទូលទៅ ទីង យាយនោះខ្វី ថា "ឱ! យាយអើយ! សូមយាយប្រណី ដ្បិតខ្ញុំ

នេះខ្ញុំ មកពីទីឆ្ងាយ ៗ ចួបចួនព្រលប់ ទើបមកសូមឈប់ ស្នាក់ទីនេះលោកយាយ ត្រឹម ១ រាត្រី កុំបីជិនណាយ សូមទានលោកយាយ អាណិតខ្ញុំ" ៗ

រីឯដូនចាស់ បានដឹងទំនងណាស់ ទើបឆ្លាស់ឆ្លើយថា "ឯងកាលពីថ្ងៃ អាស្រ័យឯណា យប់ទើបយាត្រា មកសូមផ្ទះស្នាក់ ៗ យើងពុំដឹងថា ឯងកាចឬជា ជាប្រាកដជាក់" តាព្រោះហើយ ទើបឆ្លើយឡើងស្នាក់ ថា "ឲ្យគ្នាស្នាក់ ទៅចុះណាយាយ ! ៗ កុំខាំងកំនឹក ដ្បិតគ្នាលីលា មកពីទីឆ្ងាយ ស្នាក់១រាត្រី កុំបីហ៊ួនហ៊ាយ នឹកនានិយាយ អាយនាយដូច្នោះ ៗ ចួបចួនព្រលប់ គ្នាមកសូមឈប់ មួយយប់ប៉ុណ្ណោះ ក៏មិនជាអ្វី ឥតបីមានទោះ ទំនងគាត់នោះ ត្រង់ស្មោះទេណា" ៗ

ចមកពនរបតី ស្ដេចស្ដាប់សំដី ពាក្យយាយទំនង យល់ស្មោះស្រះស្រួល ទទួលហើយណា ទើបស្ដេចយាត្រា ចូលក្នុងផ្ទះនោះ ៗ នៅយប់នោះថ្កន យាយតាពីរប្រាណ ដេកគ្មានលក់សោះ ទើបក្រោកសន្ទនា ប្រឹក្សាពីគ្រោះ ពីរឿងនេះនោះ តាមភាពអ្នកក្រ ៗ "យាយអើយ ! យប់ជ្រៅ នេះអញគិតទៅ ឃើញផ្លូវ ១ ល្អ គាប់ឃ្លោករពៅ ត្រឡាចនូវល្ង ត្រសក់នោះក៏ យើងមានជាច្រើន ៗ យើងគិតដាំវា ហើយថែរក្សា ឲ្យវាចំរើន បេះផ្លែទៅលក់ បានលុយមកច្រើន ហើយយើងក្រវើន សន្សំទៅមុខ ៗ បានច្រើនកាលណា យើងលោះទាសា ទាសីមកទុក ឲ្យបក់ផ្លិតយើង ឆ្វេងស្ដាំក្រោយមុខ យើងនឹងបានសុខស្រណុកឯចាស់" ៗ

(មានត)

# អនុស្សាវរីយ៍

## បំពោះព្រះបាទសម្តេច ព្រះនរោត្តម-សីហនុ វរ្ម័ន

ព្រះចៅប្រទេសកម្ពុជា


## លោក អ៊ុង-ស៊ុមន៍ លេខាធិការរង

អនុវិទ្យាល័យ ព្រះសីហនុ កំពង់ចាម

រៀបរៀង

## លោក ចាប-ពិន ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

ពិនិត្យកែសម្រួលតាមក្បួនកាព្យ


---

គេស្ងើចសរសើរព្រលាន់លោក　ជ័យជោគវាសនាកម្ពុជា
ធ្លងទុក្ខបានសុខគ្រប់ៗគ្នា　ដោយព្រះរាជក្យត្រប្រិមប្រិយ ។
ព្រះបាទសីហនុ វរ្ម័ន　ព្រះទ័យណែនណាន់កាន់ខន្តី
ព្យាយាមកសាងផែនទឹកដី　ដោយប្រោសប្រណីខ្មែរយ៉ាងខ្លាំង ។
ទ្រង់ហោះចាកដែនកម្ពុជា　លីលាទៅកាន់ស្រុកប៉ាកាំង
តាមទារឯករាជ្យដោយកម្លាំង　ព្រះប្រីជាខ្លាំងឥតប្រណី ។
ជជែកតវ៉ាទឹងប៉ាកាំង　គេខំបិទបាំងមិនចង់ស្តី
ព្រះអង្គឈ្វេងយល់ហោះចេញខ្ចី　សំដៅបុរីកាណាដា ។
ហើយទ្រង់យាងទៅក្រុងញីវយ៉ក　ទ្រង់ស្រែកសង្ឃ្រកយ៉ាងសង្ហា
ព្រះទស្សព្រះអង្គហាក់សរថ្លា　វិទ្យុឃោសនាផ្អើលផែនដី ។
កាសែតព្រោងព្រាតគ្រប់ជាតិសាសន៍　ផ្សាយដំណឹងជាសលើប្រថពី
ញាប់ញ័រខ្ញូរខ្ញូរគ្រប់ទិសទី　ស្តីពីប៉ាកាំងគ្មានសេសសល់ ។

សាកលលោកស្ញើចមហាក្សត្រយើង ថាប្រាជ្ញាខ្ពង់ឥតគេដល់
ក្មេងព្រះអង្គទៅតែប្រតិពល មានព្រះយោបល់ស្គាល់កោះត្រើយ ។
ព្រះអង្គទ្រង់ប្តូរព្រះជន្មា ឥតមានរួញរាខ្លាចមរណ៍ឡើយ
ព្រោះការស្លាប់រស់តែងមានហើយ ឲ្យតែដល់ត្រើយឯករាជ្យជាតិ ។
ទ្រង់ចាកអាមេរិកទៅជប៉ុន ឲ្យគេការុណ្យជួយគាស់រាត
នាំឯករាជ្យខេមរជាតិ ដល់ត្រើយកុំឃ្លាតឆាប់ ៗ វៃ ។
ដល់ស្រុកជប៉ុនទ្រង់រ៉ាយរ៉ាប់ រឿងឯករាជ្យប្រាប់ឲ្យជួយលៃ
ជប៉ុនបានឮព្រះឱស្ឋថ្លៃ ថានឹងកែខៃជួយកម្ពុជា ។
រួចទ្រង់បន្តបេសកកម្ម ដោយទ្រង់ផ្ញើផ្ដាំព្រះបិតា
អនុសិទ្ធិរាជជួយក្សត្រា លាព្រះមាតាយាងសៀមរាប ។
ប្រគល់រដ្ឋាភិបាលប៉ែន-នុត ឲ្យធ្វើការមុតតាមសភាព
ព្រះអង្គស្ដេចយាងចាកសៀមរាប ដរាបទៅកាន់ប្រទេសថៃ ។
វិទ្យុស្រុកថៃស្រែកឃោសនា ចេញមុខសង្ហាពីរបីថ្ងៃ
ក្រោយមករដ្ឋាភិបាលថៃ ថាមហាក្សត្រថ្លៃទ្រង់ស្ដេចយាង ។
មកនេះជាកៀរកិត្តិយស យ៉ាងខ្ពស់ប្រាកដឃើញរូបរាង
ដោយថៃនឹងខ្មែរនៅជិតខាង គួរតែអះអាងជួយក្សត្រក្សាន្ត ។
ចាកថៃមកកាន់បាត់ដំបង ព្រះទ័យប៉ុនប៉ងមានឡាក់ហាន
ថាបើឯករាជ្យមិនទាន់បាន ក្សត្រក្សាន្តមិនជាន់រាជវាំងជ័យ ។
ទ្រង់ផ្ដើមផែនការណ៍យ៉ាងអង់អាច ព្រះសីហនុរាជយ៉ាងនិរភ័យ
កងជីវពលបាត់យ៉ាងប្រពៃ ឆាប់វៃពេញរដ្ឋខ្មែរគ្មានសល់ ។

នារីក្តាហានហ៊ានតាំងចិត្ត ព្រមព្រៀងគំនិតធ្វើដំណើរ
ជួយជាកម្លាំងព្រះនិមិល ឲ្យធាប់បានដល់ទៅត្រើយនាយ ។
កាំភ្លើងឈើខាត់លោងស្រួល ហាត់បាញ់ឥតខ្ជិលញញឹមព្រោយ
ទុកជាទៀយហាត់គន់ខ្វល់ខ្វាយ ព្រោះចិត្តរីករាយនឹងមហាក្សត្រ ។
រំលងពេលខ្លីមហាក្សត្រា ដៃដែកគតក៏ដោយម៉ឺងម៉ាត់
គតក៏ផ្លូនៗប្រើនស្ងាត់ ខ្លាចកើតវិបត្តិបាក់ថ្ងាយ ។
ឯកពជួរបរិបូណ៌ឲ្យទេមក ថ្ងៃក្រោយព្រះមហាក្សត្រធោមធាយ
ចូលកំពង់តាមតាមផ្លូវឆ្ងាយ ដំណើររៀបថ្វាយទស្សនាការ ។
ដើររៀបជាក្បួនដូរយ៉ាងវែង សំដែងគោរពដ៏ឧឡារ
ទតហើយទ្រង់មានព្រះឧង្ការ ថានេះអស្ចារ្យក្បួនវែងធំ ។
នុះវិទ្យាល័យកំពង់ចាម តាំងនាមពជាដ៏សុខុម
វិទ្យាល័យព្រះសីហនុជុំ– ច្រើនហំសមស័ក្តិអ៊ីម៉េះណា ។
ទ្រង់គន់ត្រសាលដោយគេស្រមក្សាន្ត មិនយូរប៉ុន្មានទ្រង់យាត្រា
ព្រោះគេត្រៀមចាំព្រះពជា អគ្គបញ្ញាលើពលរដ្ឋ ។
ព្រះអង្គយាងចូលពជធានី ទៅតាមវិធីក្បួនហត់ចត់
ពស្ត្រគងក្រងក្រៅញឹកដូចញាត់ ចោមរោមមហាក្សត្រដោយចិត្តស្មោះ ។
ទីក្រុងភ្នំពេញពេញមហាថ្លៃ គ្រប់ផ្លូវជៀតជែកគ្មានចន្លោះ
ណែនណាន់តាន់តាប់ប្រកគៀនគោះ ទទួលចំពោះព្រះបក្រ ។
មើលផ្លូវព្រះប្រិយមហាក្សត្រ ព្រោះស្តេចយាងបាត់យូរពត្រ
ថ្ងៃនោះជាថ្ងៃមានសួស្តី ព្រោះព្រះនរបតីស្តេចយាងមក ។

ទីក្រុងភ្នំពេញៗឡារិក  ក្បៀងឱហូរទឹកគ្រប់ប្រកល្ហក
កងជីវពលឈរកុញកក  គ្មានដកខ្លួនជែកថយក្រោយទេ ។
ពស្ត្រស៊ីបរចិត្តដោយស្នេហា  ទឹងមហាក្សត្រាជាមហាមេ
ប្រឹងដោះទុក្ខពស្ត្របចាំវេ –  ទនាទើបគេអរពេកក្រៃ ។
ពីថ្ងៃនោះពស្ត្របូរជីវិត  ដើរកិតតាមក្រោយមហាក្សត្រថ្ងៃ
ដោយទ្រង់ព្យាយាមទាមកែខៃ  ឯកពជ្យឲ្យថ្ងៃពេញបរិបូណ៌ ។
សត្រូវណាបៀតបៀនកំទេច  ព្រោះគេមិនភ្លេចស្តេចថ្ងៃថ្នូរ
ព្រះមហាក្សត្រខ្មែរមានហៃហូរ  អម្បូរអង្គរច្រើនណាស់អើយ ។

ពន្លឺភ្លើងបន្ទះនៅស្រុកស្រែ

## ពន្យល់ក្បួនកាព្យ

ពាក្យកាព្យដែលមានគោលត្រូវល្អ  ឃ្លាមុនខ្យល់សីប្រកបប្អូន
ឃ្លាក្រោយប្រើខ្យល់សីទៀតផ្ទួន  មិនប្រើពាក្យប្អូនវិសញ្ញនី ។
ឃ្លាមុនវិសញ្ញនីរះមុខ (ះ)  ឃ្លាក្រោយគេទុកប្អូនពេញទី
ជាខ្យល់រះមុខវិសញ្ញនី  តាមទីដែលត្រូវប្រកបប្អូន ។
ឃ្លាមុនមានខ្យល់វិប្រកប  ឃ្លាក្រោយប្រើខ្យល់ ~~មម~~ វិផ្ទួន
មិនឲ្យខ្វែងខ្យល់សម្ពស្សប្អូន  នោះទើបត្រូវក្បួនកាព្យល្អអើយ !

ជាប-ពិន

# រឿងសាមកុក

## ភាគទី ២០

## ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តទៅ)

---

រឿងសាមកុកទុកជាបុរាណសាស្ត្រ
អ្នកវាងវៃឆ្លាស់បើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

---

ពួកយល់ឃើញត្រូវផង ទើបប្រើទៀវហ៊្វីដែលមានសតិបញ្ញាឲ្យទៅបញ្ចុះបញ្ចូលតៀវស៊ីវ ។ ទៀវហ៊្វីក៏លាចូលទៅដល់ស្រុកតេង-អៀង ហើយចូលទៅគំនាប់កាសៀងដែលជាទីប្រឹក្សាតៀវស៊ីវ ហើយនិយាយថា គ្រានេះចូចូបានជាទីមហាឧបរាជមានចិត្តចូរចូលាយ ស្រួកយរាប់អានសេនាទាហានទាំងឡាយទាំងតូចល្អណាស់ បានជាប្រើខ្ញុំឲ្យមកនិយាយនឹងតៀវស៊ីវដែលបានធ្វើសង្គ្រាមនឹងគ្នាមកពីមុននោះ កុំបីឲ្យមានចិត្តគិតអាឃាដព្យាបាទគ្នាតទៅមុខទៀត ចូរគិតគូររួមគំនិតចិត្តមួយនឹងគ្នា ដើម្បីនឹងទំនុកបំរុងផែនដី ។ កាសៀងបានស្តាប់ដូច្នោះឆ្លើយថា ថ្ងៃនេះចួនពេលក៏យប់ទៅហើយ ព្រឹកស្អែកខ្ញុំនឹងនាំអ្នកទៅជួបនឹងតៀវស៊ីវ ។ កាសៀងក៏ឲ្យរៀបតុលៀងភោជនាហារឲ្យ

ទៀតហើយបរិភោគ លុះពេលព្រឹកឡើងកាសៀងក៏ឲ្យឡើងហើយនៅៗ ផ្ទះសិទ្ធិខ្លួនកាសៀងក៏ចូលទៅដកបតៀវស៊ីរគ្រប់ប្រការ ។ តៀវស៊ីរនៅមិនទាន់ឆ្លើយតបថាដូចម្ដេច ស្រាប់តែមានទាហានអ៊ួនសៀវយកសំបុត្រទៅឲ្យតៀវស៊ីរៗ ក៏ទទួលមកលាមើលនៅមុខកាសៀង ក្នុងសំបុត្រនោះមានសេចក្ដីថា "អ៊ួនសៀវចៅហ្វាយស្រុកគីជីវមកដល់តៀវស៊ីរជ្រាប ដ្បិតវេលានេះចូឆូបានជាមហាឧបាជ ទៅក្រុងហ៊ូតោ ធ្វើការអាក្រក់ផែនដី, ព្រះចៅហៀនតេនឹងបណ្ដានាហ៉ឺនសព្វមុខមន្ត្រី នូវអស់អាណាប្រជានុរាស្ត្រទាំងពួងបានសេចក្ដីក្ដៅក្រហាយណាស់ បានជាយើងឲ្យសំបុត្រនេះអញ្ជើញអ្នក ដើម្បីឲ្យទៅជួយគិតការពជការទឹងកំចាត់ចូឆូចេញ ជាទីទំនុកបំរុងព្រះមហាក្សត្រឲ្យបានគង់ជាសុខក្សេមក្សាន្តក្នុងរាជសម្បត្តិ" ។ កាសៀងបានឮសំបុត្រនោះច្បាស់ហើយ ក៏ទាញយកពីដៃតៀវស៊ីរមកកាន់ ហើយសួរបំរើនោះថា កាលពីខែកន្ទេបទយើងបានឮដំណឹងថាអ៊ួនសៀវចៅហ្វាយស្រុកអ្នកឯង លើកឯទ័ពទៅច្បាំងនឹងចូឆូមិនដឹងចាញ់ឬឈ្នះ ។ បំរើនោះឆ្លើយថា ចៅហ្វាយខ្ញុំបាទលើកកងទ័ពទៅដល់ដំបន់ឡើយ៉ុងចុងដែនស្រុកហ៊ូតោ ចូឆូក៏លើកទ័ពមកតាំងបន្ទាយចម្ងាយពីគ្នាប្រហែល ៨០០ សិន (៣២ គ.ម.) ទទួលទេសកាលចូលរដូវរងាអ៊ួនសៀវឲ្យទាហានការពង្គង់ទុកមិនទាន់ចេញច្បាំងនឹងចូឆូទេ ខ្លួនចូឆូនឹងអ៊ួនសៀវទាំងសងខាងក៏លើកទ័ពត្រឡប់ទៅស្រុកវិញរៀងខ្លួន ។

កាសៀងបានស្ដាប់ដូច្នោះខឹងណាស់ យកសំបុត្រឈ្លីចោលហើយស្ដីថា "កាលគ្រាអ៊ួនសុតជាប្អូនចៅហ្វាយអ្នកឯង ក៏មិនបានប្រក្រតី

យកចិត្តគ្នានឹងអ្នួនសៀវជាបង ឥឡូវមកល្បួងលោមអ្នកដទៃ មិនមែនសាច់សារលោហិតទៅរួមគំនិតគិតការជាមួយផង ដូច្នេះធ្វើម្ដេចនឹងយកជាការបាន" ថាហើយក៏បណ្ដេញបំរើដែលកាន់សំបុត្រឱ្យដើរចេញមួយរំពេច ។ គៀវស៊ីវឃើញកាសៀងធ្វើដូច្នោះក៏ភ័យណាស់ទើបថា ហេតុម្ដេចបានជាអ្នកធ្វើផ្ដេសផ្ដាស់ ហែកសំបុត្រអ្នួនសៀវចោលដូច្នេះ ព្រោះវេលានេះ អ្នួនសៀវមានថ្វីដៃខ្លាំងពូកែហើយសេនាទាហានក៏មានច្រើន បើអ្នួនសៀវដឹងការហើយ សូម្បីនឹងលើកកងទ័ពមកធ្វើអន្តរាយស្រុកយើង តើអ្នកនឹងគិតយ៉ាងម្ដេចទៅវិញ? ។

កាសៀងតបថា បើលោកបារម្ភខ្លាចដូច្នោះ ខ្ញុំនឹងនាំលោកចូលទៅនៅធ្វើការខាងប៉ូចូវិញ ទោះបីអ្នួនសៀវនឹងលើកទ័ពមកធ្វើអន្តរាយដល់លោក ប៉ូចូនឹងបានជួយ ។ គៀវស៊ីវតបថា សព្វថ្ងៃនេះប៉ូចូបានជាមហាឧបរាជក៏មែន តែសេនាទាហានតិចជាងអ្នួនសៀវ, ប្រការ ១ ប៉ូចូបានធ្វើសង្គ្រាមនឹងយើងមកពីមុន គង់មានចិត្តអាឃាតព្យាបាទនឹងយើងមិនភ្លេច ។ កាសៀងឆ្លើយថា បើខ្លាចប៉ូចូព្យាបាទនោះ ខ្ញុំសុំកុំឱ្យលោកព្រួយជាទុក្ខឡើយ បើយើងទៅចូលខាងប៉ូចូហើយឃើញត្រូវ ៣ ប្រការ : ប្រកា ១ ប៉ូចូបានជាមហាឧបរាជទោះបីនឹងធ្វើការអ្វី ៗ ក៏កាន់យកព្រះតម្រាស់ព្រះចៅហៀនតេជាប្រមាណ នាហ្មឺនមុខមន្ត្រីគង់ស្រុកក្រុងនឹងខេត្រក្រៅទាំងអស់ រមែងកោតខ្លាចអំណាចប៉ូចូជាច្រើន; ប្រការ ១ ទោះបីប៉ូចូមានទាហានតិចក្ដីណា តែមានដម្រិះប្រាជ្ញាជ្រៅទូលាយណាស់ នឹងធ្វើការសង្គ្រាមនៅទីណារមែងមានជ័យជំនះច្រើន

ផាន់ចាញ់ ដែលលោកគិតខ្វាចអ្នកស្ទៀវ ប្រជុំជនចូលទៅខាងអ្នកស្ទៀវដែលមានទាហានច្រើននោះ ឧបមាដូចជាមនុស្សមានទ្រព្យសម្បត្តិច្រើន ហើយមានគេយកទ្រព្យរបស់ទៅឲ្យ ក៏មិនសូវត្រេកអរប៉ុន្មាន ឯប្អូននោះដូចជាមនុស្សខ្វះខាតទ្រព្យសម្បត្តិ បើមានគេយកទ្រព្យរបស់តែបន្តិចបន្តួចទៅឲ្យក៏មានសេចក្តីត្រេកអរណាស់; ប្រការ ១ ទៀតប្អូនធ្វើការគ្រានេះ មានចិត្តធូរទូលាយស្រឡាញ់ពលទាហានទាំងពួង ទោះបីនរណាធ្វើខុសក៏ធ្វើតាមខុស នរណាធ្វើត្រូវក៏ឲ្យបំណាច់រង្វាន់តាមគុណគាប់គ្រប់គ្នា មិនដែលមានសេចក្តីព្យាបាទដល់អ្នកឯណា គិតតែយកកិច្ចការជាប្រមាណ ខ្ញុំបាទយល់ឃើញហេតុទាំង ៣ ប្រការដូច្នេះ ទើបថាឲ្យលោកទៅចូលខាងប្អូនល្អជាជាងអ្នកស្ទៀវ ។ តៀវស៊ីវក៏យល់ព្រមផង, កាសៀងក៏លាត្រឡប់ទៅផ្ទះវិញ ហើយនិយាយប្រាប់ឡេវហ៊ួគ្រប់ប្រការ ។ ឡេវហ៊ួបានស្តាប់ពាក្យកាសៀងគ្រប់ប្រការក៏មានសេចក្តីត្រេកអរពន់ពេក ឲ្យកាសៀងនាំខ្លួនទៅជួបនឹងតៀវស៊ីវ ដល់ហើយក៏ឱនគំនាប់តាមសមគួរហើយនិយាយថា លោកកុំបីសង្ស័យនឹងមហាឧបាជនោះឡើយ បើជាមានចិត្តព្យាបាទទៅហើយ ក៏នឹងលើកទ័ពមកច្បាំងនឹងលោកយកជ័យជំនះឲ្យគ្រាតែបាន នេះអស់សេចក្តីព្យាបាទហើយទើបប្រើខ្ញុំបាទមក អញ្ជើញឲ្យលោកទៅជួយគិតការទំនុកបំរុងផែនដី ។ តៀវស៊ីវបានឮសំដីឡេវហ៊ួនិយាយដូច្នោះ ក៏មានចិត្តត្រេកអរណាស់ តាំងតាប់ផ្តើមកេណ្ឌប្រមូលសេនាទាហានបានគ្រប់គ្រាន់ ហើយក៏នាំកាសៀងនឹងឡេវហ៊ួលើកទ័ពទៅក្រុងហ៊ូតោ ។

ឡៅហ៊ួក៏នាំគៀវស៊ីវនឹងកាសៀងចូលទៅគំនាប់បូឆូ គៀវស៊ីវនឹងកា-សៀងក៏លុតជង្គង់គំនាប់បូឆូហើយអង្គុយនៅទីទាប ។

បូឆូឃើញគៀវស៊ីវនឹងកាសៀងចូលទៅដល់ ក៏មានចិត្តសោមនស្សណាស់ ចុះទៅទាញដៃគៀវស៊ីវឲ្យក្រោកឡើងមកអង្គុយលើកៅអីដោយសមគួរ ហើយនិយាយថា "ពីដើមយើងបានប្រមាទធ្វើមោះមិនគាប់ត្រឡប់បង់ទោសដល់គ្នានឹងគ្នា សុំឲ្យអ្នកអភ័យទោសដល់យើងចុះ កុំបីមានអាឃាតព្យាបាទតទៅឡើយ" និយាយហើយបូឆូក៏តាំងគៀវស៊ីវឲ្យធ្វើជាទីអៀងប៊ូចុងគុណ គឺនាយទាហានធំ ឲ្យកាសៀងជាទីគិមជិមងឺគីទីប្រឹក្សា ហើយបូឆូនិយាយនឹងគៀវស៊ីវ កាសៀងថា ឲ្យតែងសំបុត្រទៅបញ្ចុះបញ្ចូលឡៅពៀវចៅហ្វាយស្រុកកេងជីវទៀត ។

កាសៀងឆ្លើយថា ឡៅពៀវនោះជាមនុស្សរមែងគប់ប្រសព្វនឹងអ្នកមានសតិបញ្ញា បើនឹងឲ្យទៅបញ្ចុះបញ្ចូលវេលាណា ត្រូវចាត់ប្រើអ្នកមានប្រាជ្ញាស្មារតីចេះសំដីនិយាយដោះស្រាយឲ្យទៅនិយាយទើបបាន ។

បូឆូក៏សួរទៅស៊ុនហ៊ុវថា អ្នកយល់ឃើញនរណាមានប្រាជ្ញាវាងវៃដែលនឹងប្រើឲ្យទៅស្រដីល្បួងលួងលោមឡៅពៀវបាន ។ ស៊ុនហ៊ុវឆ្លើយតបថា ដែលនឹងប្រើទៅបញ្ចុះបញ្ចូលឡៅពៀវនោះ ខ្ញុំបាទយល់ឃើញតែខុងយ៉ុង ១ នេះគួរនឹងប្រើឲ្យទៅបាន ។ បូឆូក៏យល់ព្រមផងពេលនោះទីប្រឹក្សានឹងសេនាទាហានទាំងពួងក៏លាបូឆូទៅផ្ទះរៀងខ្លួន ។

ស៊ុនហ៊ុវក៏ចូលទៅរកខុងយ៉ុងឯផ្ទះហើយនិយាយថា ឥឡូវនេះបូឆូរើសរកអ្នកមានសតិបញ្ញា នឹងប្រើឲ្យទៅនិយាយការដើម្បីនឹងបញ្ចុះ

បញ្ឆលទ្បោញៀវ ខ្ញុំឆ្លើយថា ឃើញតែអ្នកម្នាក់ឯង ទើបអាចទៅបញ្ឆុះបញ្ឆលឡោញៀវបាន ។ ខុនយ៉ុនបានឮដូច្នោះក៏ឆ្លើយថា ខ្ញុំជាអ្នកបេះដូងតិច ហេតុម្តេចបានជាអ្នកទៅនិយាយដូច្នេះ ប្រសិនបើខ្ញុំទៅនិយាយមិនសម្រេចការរបស់បងធំ អ្នកនឹងខ្ញុំគង់មិនរួចអំពីទោសខុសឡើយ ។

ស៊ីនហ៊ុវសួរថា អ្នកឃើញនរណាដែលមានដំរេះប្រាជ្ញាជាងអ្នកទៀត ? ។ ខុនយ៉ុនឆ្លើយតបថា សំឡាញ់របស់ខ្ញុំម្នាក់ឈ្មោះយីអេង មានសតិបញ្ញាយ៉ាងជ្រៅលើសប្រាជ្ញាខ្ញុំ ១០ភាគ កុំថាឡើយតែប្រើទៅនិយាយបញ្ឆុះបញ្ឆលឡោញៀវប៉ុណ្ណោះ ទោះនឹងឲ្យធ្វើនាហ្មឺនធំកាន់រាជការព្រះចៅហើ្មនតេក៏បាន ខ្ញុំគិតនឹងធ្វើរឿងរ៉ាវក្រាបបង្គំទូលព្រះចៅហៀនតេ ឲ្យទ្រង់ប្រោសតាំងយីអេងជានាហ្មឺនមានយសស័ក្តិ រួចសឹមឲ្យទៅនិយាយបញ្ឆុះបញ្ឆលឡោញៀវ ។ ស៊ីនហ៊ុវក៏យល់ព្រមផង ទើបខុនយ៉ុនតែងរឿងរ៉ាវជាសេចក្តីថា ទូលព្រះបង្គំជាខ្ញុំខុនយ៉ុន សូមក្រាបបង្គំទូលថ្វាយ សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ ដ្បិតយីអេងនេះ អាយុ ២០ឆ្នាំ នៅកន្លែងស្រុកខ្សៃ មានសតិបញ្ញាឆ្លៀវឆ្លាតប្រែន ក្អែកក្រឡេកមើលទៅឃើញរបស់អ្វី ត្រចៀកបានឮសំឡេងអ្វី ចិត្តនោះក៏គិតដុះធ្លាយរហូតមិនទើសទាល់ ប្រមាណការអ្វីក៏ត្រូវគ្រប់ប្រការ សូមឲ្យទ្រង់យកយីអេងមកប្រើជាខ្ញុំព្រះរាជការ ហើយចាត់ឲ្យទៅនិយាយបញ្ឆុះបញ្ឆលឡោញៀវឃើញនឹងបានដោយងាយ" ។

(មានត)

ដំណើរតាមខ្យល់ក្នុងកាផ្ទារ:

# លោក ផេង-ជឿវ សាស្ត្រាចារ្យនៅសាលាគរុវិជ្ជាភ្នំពេញ

ប្រែពីភាសាបារាំងមកជាភាសាខ្មែរ

(តពីខ្សែលេខ ១ ឆ្នាំ ១៩៥៥)

---

## លោកអែយ៉ាង មានធម៌សប្បុរស

ព្រះអាទិត្យទើបតែនឹងអស្តង្គត កាលដែលលោកអនុសេនីយ៍ទោ សេលីមជាក្មួយព្រះចៅ មុយន៍ប៉ាហា នាំពួកឈ្លើយចូលដល់ក្រុងកាសិ-កាពប៊ូលី ។

ថ្ងៃពេលថ្មើរនេះ ដែលឈ្លើយទៅដល់ បណ្តាលឲ្យមហាជនផ្អើលឈូឆរមកមើល ព្រោះឱកាសនោះ ត្រូវពួកស្រីៗ កាន់សំបកឃ្លោកសាយ-ដៀវមួយម្នាក់ចេញទៅដងទឹកអណ្តូង ប៉ុន្តែរឿងនេះមិនសូវសប្បាយមើល ដល់ពួកអ្នកកំប្លែង កំលេងចាក់គ្លុកក្រមាប់ក្រម៉ើមនៅកណ្តាលជនអ្នកមើលឡើយ ហើយការកម្សាន្តនេះស្ថិតនៅបន្ទាយពេលរហូតដល់ជិតយប់ ។

ព្រះអាទិត្យជាមេធំនៃកិច្ចការអាជីវៈក្នុងបូព៌ាប្រទេសដោយពិត ប៉ុន្តែមិនត្រូវភ្លេចឲ្យសោះថា ក្នុងវេលាថ្ងៃ គេអាស្រ័យពួនទៅគ្រឹះស្ថានដ៏ត្រ-ជាក់សុខុម មានរបៀងយ៉ាងខ្ពស់សម្រាប់ឲ្យពន្លឺថ្ងៃចាំងចូលខាងក្នុង ត្រូវកុំភ្លេចថា គេត្រូវការចេញពីក្នុងផ្ទះមកលេងខាងក្រៅ នាសាយណ្ហ-សម័យ ។ គឺជាឱកាសដែលពួកកម្មករចេញពីរោងជំនាង ដើរយកអាកាសត្រជាក់ពេលល្ងាច មើលក្មេងលេងល្បែង មើលស្រីដើរដង្ហែគ្នាទៅដងទឹក ។

*
* *

ពួកទាហាននាំឈ្លើយមកបញ្ឈប់ត្រង់កន្លែងមួយ ។

លោកអនុសេនីយ៍ទោ បង្គាប់ឲ្យលោកតាម៉ាព្រុកដើរតាមរហូតបន្ទាយកងទ័ព ហើយដែលជាទីលំនៅរបស់លោកម៉ាហូម៉េដណាប៉ីប៉ី ជាវរសេនីយ៍ត្រីតួរគី ។ ចំណែកឈ្លើយដទៃត្រូវរង់ចាំស្ដាប់ការណ៍របស់នាយទាហាន គេនាំគ្នាឈប់នៅក្នុងទីធ្លា តាមផ្លូវមាននាយទាហានរងនិងកូនទាហានជាអ្នកត្រួតមើល ។ គេហាមមិនឲ្យពួកអារ៉ាប់និយាយគ្នាខ្សឹបខ្សៀវអ្វីឡើយ ។

លោកព្រិនបាលម៉ារីយោលោតចុះពីសេះ មិនរវល់នឹងអ្វីទាំងអស់ គាត់គិតតែប្រែមប្រុំនឹងនារីឈ្លើយរបស់គាត់ ។ ទាហានដែលលោកព្រិនបាលជ្រើសនាងឡីឡា ចង់យកគាប់គួរនឹងនាយចៅហ្វាយ ក៏ដាក់នាងក្រមុំពីខ្នងសេះ ហើយនាំទៅជូនលោកនាយទាហានភ្លាម ។

នាងឡីឡា តាំងពីដំបូង តែងមានសេចក្ដីជិនឆ្អន់ខ្ពើមលោកម៉ារីយោ ដែលជាមនុស្សយកតែកម្លាំងកាយនឹងអំណាចមកប្រើ ។

ពួកស្រីក្រមុំព្រហ្មចារីតែងមានរហស្សញ្ញាណមួយជាធម្មតា គឺរហស្សញ្ញាណនេះហើយដែលឲ្យដំណឹងថា មិនត្រូវស្នេហាចំពោះសាសន៍តួរគី ។ អនិដ្ឋារម្មណ៍ គឺការគុំកួនជាទុក្ខគកើតមានឡើងដល់នាងឡីឡាចំពោះលីសាសន៍នេះ ; មួយគឺមកពីចិត្តនាង មួយទៀត គឺបុព្វបុរសរបស់នាងតែងប្រដៅកុំឲ្យចូលចិត្ត គឺសាសន៍តួរគីជាជាតិព្រៃ ជាជាតិអសប្បុរស ។ នាងឈរញ័ររំប្រប់ទឹកដល់ព្រេងវាសនារបស់បងស្រីនាង ដែលអនាថាតែម្នាក់ឯងលើវាលខ្សាច់ ។ ពេលថ្មើរនេះសុមបងស្រីចាំ

មើលផ្លូវនាង ចំណែកតួរូបនាងៗ មិនសូវជាគិតប៉ុន្មាន ៗ នាងក្រឡេក មើលជុំវិញខ្លួន ក្រែងលោ មានមនុស្សណាស្គាល់នឹងពឹងឲ្យគេជួយ ប៉ុន្តែ មនុស្សទាំងអស់នេះសុទ្ធតែជាជាតិផ្សេងដែលគេទុកជាអ្នកបំរើ ព្រោះ នាងគេចាប់មកនៅក្នុងពួកមនុស្សចុងហ្វូង ៗ លោកតាម៉ាព្រែកដោយ ដំណើរគាត់យឺត បានជាមកនៅជាមួយនឹងពួកនេះ ៗ ចំណែកពួក ហ្វូងដំប្រេកបដោយជនជាសាច់ញាតិនឹងនាងឡូឡា ដូចជាម្តាយរបស់ នាង ត្រូវគេបញ្ជូនឲ្យទៅជាមួយលោកតាម៉ាព្រែក នៅមុខលោកអនុ-សេនីយ៍ត្រឹងណោះ ៗ នាងឡូឡាពេលនេះជានារីឯកា ដាច់សង្វែង បណ្តោយខ្លួនទៅលើអាមនុស្សចិត្តអាក្រក់កណ្តាលស្រុកគេ ៗ

លោកព្រិន្ទបាលម៉ារីយ៉ា ឃើញថាឱកាសនេះជាមហាស្រួល របស់លោក ៗ ព្រោះនៅទីនោះ មនុស្សទាំងប៉ុន្មានសុទ្ធតែជាអ្នកបំរើ នឹងជាទាហានរបស់លោក ហើយនឹងអាក់ខ្លះដែលមកចោមរោមមើល ៗ បើប្រសិនពួកនេះជួយការពារក្នុងពេលដែលនាងមិនព្រមដោយតាម កាន់ តែជាវគ្រីជន្ទួរទៅ អាអស់នេះនឹងគ្រាកអស់មួយរំពេច ហើយគាត់ ជឿជាក់ថា នាងនេះមុខជានឹងតាមគាត់រហូតដល់ខ្ទមដែលនៅខាងក្រៅ ក្រុងជាមិនខាន ៗ អំណាចអានុភាពទឹកស្រវឹងបង្វិលខួរក្បាលគាត់មិន ឲ្យយល់អ្វីទាំងអស់ ៗ គាត់គិតមិនឃើញដល់ការចលាចលនឹងទីកន្លែង ដ៏មិនគួរសម ៗ ចិត្តរបស់លោកខាងក្នុងកើតមានកាមរាគយ៉ាងខ្លាំង ចំពោះនាងកុមារីព្រហ្មចារ្យនេះពេក គឺជាចំណង់ដែលគាត់ត្រូវតែបំពេញ ឲ្យសម្រេច មិនគោរពការគិតក្រែងរអែងអ្វីទាំងពួងឡើយ ៗ

*

* *

លោកព្រឹទ្ធបាលទោ ដើរចូលមករកនាងឡូឡា ចំប្រឹងសំដែងអាការទន់ភ្លន់ញញឹមទាំងមាត់ត្រហុប ។ ឃើញដូច្នោះ នាងថយក្រោយដោយឥតដឹងខ្លួនដូចជាគេឃើញសត្វសាហាវយង់ឃ្នង ។ ខណៈនោះគាត់ក៏ហែងចាប់នាងភ្លាម ទាញមកផ្អោបទនឹងឯកសណ្ឋានរបស់គាត់ហើយនិយាយថា:

— « នាងឯងត្រូវមកនៅនឹងអញ ! មេចព្រមឬទេ ? » ។

ភ្នែកនាងត្រឡប់បើកឡើង នៅចំមុខដ៏គួរស្អប់ដែលខំមករកហាក់ដូចគេបើកភ្នែកនៅចំពោះទឹកជ្រាំកខ្វក់ គឺជាការឃើញគួរឲ្យតក់ស្លុតចំពោះមុខដែលស្រាទឹកហុសផ្សេង ៗ ទុកស្នាមនៅក្រឡៅ ជាមុខឥតធម៌ ខ្លួននាងស្មានដូចជាស្ថិតនៅពីមុខប្រេត ។ នាងនឹកដល់រឿងព្រេងដែលម្ដាយនាងនិយាយប្រាប់កាលនៅពីតូច អំពីពួកធ្មប់ក៏បាបចាប់ម្ចាស់ក្សត្រីយកទៅលែងឲ្យនៅកណ្ដាលហ្វូងកងខ្យាដំរីខ្មៅ ៗ មានពិស ។ ម្យ៉ោះហើយយុវភាពដូចបុប្ផាកំពុងរីក ជាតិសប្បាយទឹងព្រហ្មចារ្យរបស់នាងតាំងចាប់ប្រែក្លាតឡើង ។ នាងស្រែកថា: « ទេ ! ទេ ! » ។

លោកមេទោ សើចចំអកឲ្យ ហើយថាត្រាប់សំដីនាង: ទេ ! ទេ ! មិនប្រែមក ! មិនរួស ! រួចទឹកមុខគាត់ឡើងក្រហម គាត់ចាប់ទាញក្រទ្រាក់នាងនារីទាំងបង្ខំមកជួបនឹងដើមទ្រូងគាត់ ។ ដៃគាត់ចាប់អារម្មណ៍ ដឹងថាតរុណកាយនៃនាងញ័រញាក់ទះទ្រើកពួជខាងក្នុងសំលៀកបំពាក់ គាត់បានជួបប្រទះនឹងកងកាយដ៏ខ្ចីស្រុខុម គាត់ទិកដល់ត្រគាកទាំងពីរស៊ុត្យពេក ហើយនឹងថនាដូចផ្លែទន្លាប់ខាងក្នុង ។ ភ្លើងកក ក៏ឆេះឡើងភ្លាម-

ដូចទឹកស្រវឹងយ៉ាងខ្លាំង ចំពោះរូបគាត់ ដោយអានុភាពសុភ តរុណភាព នឹងរូបសម្បត្តិនៃនាងក្រមុំឡូឡា ។ គាត់ចាប់គ្រញេចក្បាលនាងក្នុងដៃទាំងពីរ ។ នាងខំប្រែងប្រមែះដើម្បីដោះខ្លួនចេញ ប៉ុន្តែគាត់ចាប់ឱបនាងយ៉ាងជាប់រឹងគាំង គំរើកមិនរួច ហើយមុខគាត់ឱនដាក់ទៅលើបបូរមាត់ក្រហមឆ្អិល ។ នាងបិទភ្នែក ហើយស្រែកដោយសំឡេងតក់ស្លុតស្ទើរបាត់វិញ្ញាណ (ឱ! គួរឲ្យខ្ពើមរអើមយ៉ាងណាទៅ មាត់ចាស់គ្រ-ហុប ធុំស្អុយតែក្លិនស្រាអសោចិ៍ ហើយយកមកផ្ទប់ទឹងមាត់បរិសុទ្ធដូចផ្កាកូឡាបទើបនឹងរីកក្នុងបុព្វណ្ហសម័យ) ។ ខណៈនោះ លោកម៉ារីយ៉ោញេញញេញបង្ហើបមាត់ឱនជញ្ជក់មាត់នាងឡូឡា ដែលប្រកបដោយរសជាតិ ដូចគេជញ្ជក់ផ្លែឈើទុំ តែគាត់ពុំទាន់បានចំលុះព្រហ្មចារ្យធម៌របស់នាងនៅឡើយទេ ។

ធម្មតា យុវភាពដ៏បរិសុទ្ធ ហើយយ៉ាងស្អាត មិនសមឲ្យប្រឡាក់ដោយដៃអាមនុស្សប្រែតជិតចូលរណ្តៅឡើយ ។

វេលានោះ ស្រាប់តែមានដៃមួយយ៉ាងរឹងដូចដែក ចាប់សង្កត់ស្មាលោកព្រឹទ្ធបាលម៉ារីយ៉ោ ហើយកន្ត្រាក់ត្រត់ទៅក្រោយ ចំណែកនាងឡូឡាស្រឡាំងកាំងមួយភ្លែត ទើបស្គាល់ជាអ្នកជិះសេះម្នាក់ ដែលនាងបានប្រទះក្នុងប៉ុន្មានថ្ងៃមុន ដោយសារសំលៀកបំពាក់ឯកសណ្ឋានយ៉ាងសម ។ នាងស្រែកថា: — "អ៊ុស្តាអ៊ុល !" ។

ហើយដោយអាការគគ្រញ នាងស្ទុះទៅរក, អ្នកកំឡោះក៏ចាប់ដៃ

នាងសើចញឹមៗ ។ វេលានោះ នាយទាហានរេងដូចគេក្ញាក់ងើបឡើង ញញើតញញាក់ ហើយស្រែកថា:

— " នាងនេះរបស់អញ ចាប់យកតាំងពីក្នុងពលខ្លាចមក" ។ អ៊ុស្មាអ៊ុលឆ្លើយដោយសំដីយ័តម៉ឺងម៉ាត់ថា:

— " នាងក្រមុំនេះ មិនជាស្រីអាយ៉ាត់គេទេ" រួចយកដៃក្តៀកឡើងឡា ដើម្បីជួយការពារឲ្យនាងកក់ក្តៅ ។

កំហឹងឡើងពេញដើមកនៃលោកត្រិទ្ធបាលម៉ារីយោៗស្រែកដេរថា

— " អាវ្ទ្រ ! អាកំណើតពីវ្ទ្រ ! អាឯងមានការណ៍អ្វីមកឈាយឡំងឹងរឿងផងអញ ? អាអាក់បស់អុយ ! អញមិនត្រូវស្តាប់អាឯងទេ អាឯងទេតើត្រូវស្តាប់អញ" ។ ខណៈនោះ គាត់លូកដៃទៅហូតដាវ ប៉ុន្តែរហ័សដូចផ្លេកបន្ទោរ អ៊ុស្មាអ៊ុលចាប់រំពាត់ដងត្រមោងឆ្វើពីក្អក ហើយដាក់ចំសៀតផ្កាលោកត្រិទ្ធបាលទោ ឈាមបាញ់ព្រៃ ។

លោកម៉ារីយោងឹងងោង ទ្រេតទ្រោត ដួលផ្ងាប់មុខទៅដីប្រកាច់ញ័រៗ ដូចត្រីត្រូវក្បាលមួយដំបង មិនយូរប៉ុន្មានក៏បាត់ស្មារតីនៅស្ងៀមស្ងប់ឈឹង ពួកកូនទាហានដែលនៅកៀមជុំវិញ ខំមើល ។ លោកត្រិទ្ធបាលដាច់ខ្យល់ស្រេច ។ ក្នុងពេលនោះដោយការគោឡោ ជ្រួលជ្រើមយ៉ាងខ្លាំងដែលបណ្តាលពីជំលោះនេះ មាននាយទាហានម្នាក់តែមក ។ គេ.គណោកមើលទោចសំឡឹងមើលកូនទាហានដែលនៅជុំវិញរួចដើរសំដៅអ៊ុស្មាអ៊ុល ហើយសួរដោយពាក្យរិតត្បិតថា:

— "ឯងជាអ្វី ?

អ្នកកំឡោះឆ្លើយប្រាប់ដោយសំដីតិចតួចថា:

– "ខ្ញុំបាទឈ្មោះ អ៊ុស្មាអ៊ីល បេនអៃយ៉ាដ ជាកូនលោកតាអ៊ីដ ខ្ញុំធ្វើទណ្ឌកម្មដល់មនុស្សនេះព្រោះវាជាចោរកំណាច!" ។

នាយទាហាននេះ ផញ្ញឹងគិតយ៉ាងជ្រៅ ហើយទឹកថា ដែលនឹងធ្វើទុក្ខទោសដល់កូនលោកតាអ៊ីដ គឺជាការប្រថុយណាស់ ប្ដូចម្ដេចអេះ ដ្បិតសម័យនេះ ជាសម័យដែលរដ្ឋាភិបាលត្រូវតែត្រូវការទីពឹងយ៉ាងមាំខាំនមិនបានលើមេអាកុំបដែលមានអានុភាពទាំងនេះ ។

ម្យ៉ាងទៀត នាយទាហាននេះស្គាល់ច្បាស់នូវចុកជតាលោកព្រិទ្ធបាលទោមារ៉ាយោ គឺជាមនុស្សដែលនាំបណ្ដាលកើរខាសឲ្យកើតមានជាញឹកញយក្នុងកំឡុងកង់ទ័ព ។ ក្នុងទីបំផុត លោកដឹងថា ខាងក្រោយពេលានកម្មនៃពួកអាកុំបចកបរក៍ ហេតុបែបនេះកើតមានឡើង ហើយមិនបាត់ស្ងាត់ នោះនឹងធ្វើឲ្យប្រជាជនមិនតាំងនៅក្នុងរបៀបផង នឹងធ្វើឲ្យមនុស្សដែលកេកលចុះចូលទាំងអស់តាំងពីដើមមក ត្រឡប់ទៅជាបះបោរឡើងវិញផង ។ ឈ្មោយចុះ ការវិនាសនាយទាហានរងមួយនេះក៏ជាអំពើមួយយ៉ាងប្រពៃដល់កងទ័ពគួរតែដែរ ហើយមិនបាច់ជំនុំនឹងមិត្តភ័ក្ដិដែលទៅជួបជុំ លោកបែរទៅរក អ៊ុស្មាអ៊ីល ហើយប្រាប់ថា:

– "ល្អហើយ! ឯងរួចខ្លួន!" ។

កាលនោះ អ្នកកំឡោះកៀកនាងក្រមុំឲ្យឡាដើរតិច ៗ តម្រង់ផ្ទះអាពុក ដែលមើលឃើញកំពូលស ៗ លេចឡើងខ្ពស់ជាងគេក្នុងក្រុង ។

(មានត)

# រឿងបល្ល័ង្កទិព្យ សាមសិបពីររឿង

រឿងព្រេងនិទាន

## លោកសមិន ម្ចត្យនជម: តែង
## លោករ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

---

ដល់វេលាក្រោយមក, មិនយូរប៉ុន្មាន ព្រះអគ្គមហេសីប្រសូតព្រះរាជបុត្រ ហើយព្រះនាងប្រគល់ព្រះរាជបុត្រនោះទៅឲ្យព្រះរាជទីប្រឹក្សា រួចព្រះនាងបូជាព្រះរូបរបស់ព្រះនាងចំពោះព្រះអគ្គី សោយព្រះទិវាល័យ ដោយមានព្រះរាជបំណងនឹងឲ្យបានទៅសោយទិព្វសម្បត្តិជាមួយនឹងព្រះមហាក្សត្រិយ៍វិក្រមទិត្យ ជាព្រះរាជស្វាមីឯស្ថានសួគ៌ ។

ព្រះបាទវិក្រមសេន ព្រះរាជបុត្រនៃព្រះបាទវិក្រមទិត្យ ទ្រង់បានទទួលព្រះរាជាភិសេក ហើយទ្រង់បានឧបត្ថម្ភសត្វលោក ឲ្យបានសុខស្រួលគ្រប់យ៉ាង ដូចជាព្រះរាជបិតា, តែមិនអាចគង់លើព្រះបល្ល័ង្កទិព្យដែលជាអំណោយរបស់ព្រះឥន្ទ្រាធិរាជបាន" ។

ឱមហារាជគោជ:, សូមទ្រង់ជ្រាបថាតាំងពីនោះមិនដែលមានមហាក្សត្រអង្គណាដែលមានសមត្ថភាព អាចគង់លើព្រះបល្ល័ង្កទិព្យនេះបានឡើយ ។ ព្រោះមានសំឡេងខាងលើអាកាសបន្ទឺថា: នៅក្នុងពិភពលោកនេះ គ្មានបុគ្គលណាអាចគង់លើព្រះបល្ល័ង្កទិព្យនេះបានទេ ដូច្នេះសូមឲ្យព្រះអង្គជីកដីហើយកប់ព្រះបល្ល័ង្កទិព្យនេះតំកល់ទុកក្នុងកន្លែងដើម

វិញទៅ ។ រូបទេពនិម្មិតទីមួយនោះពោលទៅទៀតថា: "សូមព្រះអង្គទ្រង់ជ្រាប, ព្រះបល្ល័ង្កនេះ គឺព្រះបល្ល័ង្កដែលព្រះអង្គទ្រង់បានបាត់ឲ្យគេឃើញនេះឯង"

## ពាក្យនិទានរបស់រូបទេពនិម្មិតទីមួយ

រូបទេពនិម្មិតទីមួយពោលថា: ឧមហារាជគោជ: សូមព្រះអង្គសវនាអំពីកិត្តិគុណនៃព្រះមហាក្សត្រិយ៍វិក្រមទិត្យដូចតទៅនេះ ។ មានកាលមួយថ្ងៃ ព្រះបាទវិក្រមទិត្យ ទ្រង់គង់លើព្រះបល្ល័ង្កទិព្វ ក្នុងកណ្ដាលមន្ទីរព្រះរាជក្រុមប្រឹក្សាក្នុងព្រះបរមរាជវាំង ក្នុងព្រះរាជធានីអវន្តី, ស្រាប់តែមានទុគ្គតបុរសម្នាក់មកដល់ទីនោះ បានចូលទៅជិតព្រះអង្គ ឈរស្ងៀមស្ងាត់ ។ ព្រះមហាក្សត្រិយ៍ទ្រង់បានទតឃើញដូច្នោះ, ទ្រង់ព្រះចិន្តាថា: "ជនជាសមូហយាចកប្រៀបដូចជាបុគ្គលដែលជិតធ្វើមរណភាព តែងមានកាយញាប់ញ័រ, មាត់ស្ងៀមស្ងាត់ មិនអាចមានសព្ទសំដីមួយម៉ាត់ចេញសោះឡើយ ។ បើអញប្រៀបធៀបនូវសភាពទាំងពីរបែបនេះ ខ្លួនអញយល់ថា មនុស្សនេះមកដើម្បីសុំទាន បានជាមិនអាចពោលសព្ទសំដីមួយម៉ាត់ឡើយ" ។ ដល់ព្រះមហាក្សត្រិយ៍ទ្រង់ព្រះតម្រិះដូច្នោះហើយ ព្រះអង្គបានប្រគល់ប្រាក់មួយពាន់ប៉ាគូដ (១) ឲ្យបុគ្គលនោះៗទទួលហើយ នៅឈរស្ងៀមមួយកន្លែងតទៅទៀត ឥតមានពោលពាក្យអ្វីឡើយ ។ ព្រះមហាក្សត្រិយ៍ទ្រង់មានព្រះបន្ទូលសួរថា: "នែ

---

១ ប៉ាគូដ ជារូបបិយវត្ថុមាសនៅប្រទេសឥណ្ឌា មានតម្លៃ ៨ ស្លឹង ឬ ១០ ត្រណោក; ប៉ាគូដ បើហៅតាមភាសាឥណ្ឌា ថា «ហូន» ។

រូប, អ្នកឯងម្ដេចក៏មិននិយាយអ្វីដូច្នេះ?" ។ បុរសនោះក្រាបទូលថា "មកពីមានសេចក្ដីអៀនខ្មាស បានជាទូលបង្គំជាខ្ញុំពោលពាក្យអ្វីមិនកើត" ។ ព្រះមហាក្សត្រិយ៍ទ្រង់ព្រះសណ្ដាប់នូវពាក្យបុរសនេះហើយ ទ្រង់ចាត់ឲ្យប្រគល់ប្រាក់មួយពាន់ប៉ាក់ូដទៀត ហើយទ្រង់មានព្រះរាជ-ឱង្ការទៅកាន់បុរសនោះថា: "នែបុរស បើអ្នកចង់ពោលពាក្យអ្វីក៏ពោលមកចុះ" ។ បុរសនោះក៏ក្រាបថ្វាយបង្គំទូលតបវិញថា "បពិត្រមហារាជ, កិត្តិគុណនៃបច្ចាមិត្តរបស់ព្រះអង្គមិនអាចចេញចាកគេហស្ថានរបស់វាបាន, មិនអាចផ្សាយពាសពេញទៅខាងក្រៅបានទេ បណ្ឌិតពោលថា កិត្តិគុណនោះជាណាមកជាយ៉ាងក្រៃលែង; ចំណែកកិត្តិគុណរបស់ព្រះអង្គអាចធ្វើឲ្យរង្វើនពួកជីវលោកនៅក្នុងបាតាល, អ្នកករីពោលថា កិត្តិគុណរបស់ទ្រង់នេះវិសេសវិសាលណាស់, នេះគួរឲ្យធ្ងល់ពន់ពេកណាស់" ។ ព្រះមហាក្សត្រិយ៍ទ្រង់បានសវនានូវវាចាបុរសនោះហើយ មានព្រះទ័យសោមនស្សពន់ពេក ទ្រង់ក៏ចាត់ឲ្យប្រគល់ប្រាក់មួយពាន់ប៉ាក់ូដទៀត ។ ក្នុងពេលនោះទុគ្គតបុរសក៏ក្រាបបង្គំទូលថា "បពិត្រព្រះមហាក្សត្រិយ៍, ទូលព្រះបង្គំមានប្រាថ្នាចង់ដឹងថា បើព្រះមហាក្សត្រិយ៍អង្គណាមួយមានគុណសម្បត្តិ ដោយទ្រង់ចបត្តម្ភប្រជារាស្ត្ររបស់ព្រះអង្គយ៉ាងជិតស្និទ្ធ, ព្រះមហាក្សត្រិយ៍អង្គនោះមិនបានទទួលនូវសេចក្ដីនិន្ទាពីប្រជារាស្ត្រឡើយ ហើយអាចនឹងចៀសផុតពីសេចក្ដីលំបាកសព្វយ៉ាង, សូមព្រះអង្គទ្រង់ព្រះមេត្តាប្រោសសវនានូវរឿងដូចខាងក្រោមនេះ ៖

មានព្រះមហាក្សត្រិយ៍មួយព្រះអង្គទ្រង់ព្រះនាម ឧទុះ សោយរាជ្យនៅទីក្រុងឈ្មោះ វិសាលា ។ ស្ដេចអង្គនេះមានព្រះរាជបុត្រព្រះនាម វិជយបាល, ព្រះរាជទីប្រឹក្សាឈ្មោះ ពហុស្សុត, លោកសារទានន្ទ ជារាជគ្រូ, ព្រះនាងរានី(១) ភាណុមតី ជាអគ្គមហេសី ។ ព្រះមហាក្សត្រិយ៍ ទ្រង់សព្វព្រះរាជហឫទ័យពន់ពេកនឹងរូបឆោមលោមពណ៌នៃព្រះនាងរានី ភាណុមតី ទាល់តែទ្រង់ភ្លេចមិនបានទ្រង់ព្រះចិន្ដាដល់រដ្ឋបុរសព្រះអង្គ តើសម្បូណ៌ដោយភោគទ្រព្យប្លំបាកយ៉ាងណាៈសោះឡើយ ។ បើព្រះអង្គទ្រង់បំពេញព្រះរាជករណីយកិច្ច ក្នុងរយៈវេលាម្ដងមួយកាល- ក៏ទ្រង់គង់នៅលើព្រះបល្ល័ង្កទិព្យជិតព្រះនាងរានី ភាណុមតី ។ មានមួយថ្ងៃ ព្រះរាជទីប្រឹក្សា បានក្រាបបង្គំទូលថា "សូមព្រះករុណាទ្រង់ព្រះមេត្តាប្រោសព្រះរាជានុញ្ញាត ទូលព្រះបង្គំជាខ្ញុំសូមថ្វាយយោបល់ សូមទ្រង់ជ្រាបថាៈ ព្រះអង្គមិនគួរឲ្យព្រះនាងរានីចូលមកប្រជុំជាមួយក្រុមប្រឹក្សាក្នុងព្រះបរមរាជវាំងឡើយ" ។ ព្រះមហាក្សត្រិយ៍ទ្រង់តបវិញថាៈ "លោកទីប្រឹក្សា! អ្នកឯងពោលនេះប្រកបដោយវិចារណញ្ញាណពិតហើយ តែយើងមិនអាចស្ថិតនៅបានតែមួយនាទី ដោយមិនឃើញព្រះនាងរានីសោះឡើយ" ។ ព្រះរាជទីប្រឹក្សាក្រាបទូលទៀតថា "សូមព្រះអង្គទ្រង់ចាត់ឲ្យពួកវិចិត្រករគូររូបព្រះនាងរានី ភាណុមតី នៅលើសំពត់ក្រាស់ ហើយទ្រង់រក្សាទុកជិតព្រះអង្គ" ។ ព្រះមហាក្សត្រិយ៍ ក៏ទ្រង់ត្រាស់បង្គាប់ឲ្យពួកវិចិត្រករ

១ រានី ព្រះអគ្គមហេសី ទីមួយ ។

មើលនូវសភាពលំអ ឆវិវណ្ណនៃរូបព្រះនាងពន្ទី ភាណុមតី ហើយក៏យក លំអនោះទៅប្រតិស្ឋានទៅលើសំពត់ ។ ពួកវិចិត្រករបានធ្វើតាមព្រះរាជឧង្ការហើយ ក៏ថ្វាយទៅព្រះមហាក្សត្រិយ៍ ។ បានបង្ហាញរូបគំនូរនោះទៅលោកគ្រូសារទានន្ទ ហើយមានព្រះបន្ទូលថា "តើលោកគ្រូមើលរូបគំនូរនេះយល់ឃើញដូចម្ដេច?" ។ លោកសារទានន្ទទូលតបថា: "នេះជារូបគំនូរព្រះនាងពន្ទីភាណុមតីហើយ តែព្រះនាងមានគ្រាប់លំអភិនភាគគួរឲ្យស្នេហា.(១) ស្ថិតនៅភ្លៅខាងឆ្វេង ដែលពួកវិចិត្រករភ្លេចគូរនៅលើរូបនេះ គឺជាគុណវិបត្តិតែម្យ៉ាងនៃរូបគំនូរនេះ" ។ ព្រះមហា-ក្សត្រិយ៍ទ្រង់សវនានូវវាចាលោកគ្រូនេះហើយ ទ្រង់ព្រះតម្រិះថា: "ហេតុម្ដេច ក៏លោកគ្រូសារទានន្ទបានឃើញនូវគ្រាប់លំអ ស្ថិតនៅភ្លៅព្រះនាងពន្ទីភាណុមតី? ប្រហែលជាមានហេតុអ្វីមួយក្នុងរឿងនេះ" ។ ព្រះមហាក្សត្រិយ៍ទ្រង់ព្រះក្រោធជាខ្លាំង ក៏ទ្រង់ចាត់ឲ្យព្រះរាជាទីប្រឹក្សាយកលោកគ្រូសារទានន្ទទៅពិឃាដចោល ។ ព្រះរាជទីប្រឹក្សាបាននាំលោកសារទានន្ទទៅឯគេហដ្ឋានរបស់ខ្លួន ហើយក៏នឹកពិចារណារឿងនេះថា: ព្រះមហាក្សត្រិយ៍ ទ្រង់មិនបានតម្រិះឲ្យហ្មត់ចត់នូវបទឧក្រិដ្ឋនៃលោកសារទានន្ទ ហើយទ្រង់ត្រាស់បង្គាប់ឲ្យយកទៅធ្វើឃាដកម្ម; អញមិនគួរនឹងសម្លាប់នូវមហាបុរសនេះដោយមិនដឹងហេតុពិតប្រាកដយ៉ាងនេះសោះ, បើអញចាត់ឲ្យធ្វើឃាដកម្មលោកនេះ គឺទុកជាអញធ្វើឲ្យព្រះមហាក្សត្រិយ៍

---

១ បើតាមព្យញ្ជនៈថា គ្រាប់លួ ជាសម្មតិនាម ប្រែថា ភិនភាគដ៏ល្អផុត ។ ភិនភាគនេះ ប្រហែលជាប្រជ្រុយទេដឹង ! ។

ប្រព្រឹត្តបទខុសក្រិដ្ឋទៅវិញ" ។ ព្រះរាជទីប្រឹក្សាដល់បានពិចារណារឿងនេះសព្វគ្រប់ទៅ បានចាត់ឲ្យធ្វើកន្ទេលមួយនៅក្នុងដីក្នុងគេហដ្ឋានរបស់លោក ហើយក៏លាក់បំពួនខ្លួនលោកត្រសាររាននូវនៅទីនោះ ។

មានកាលមួយថ្ងៃ, ព្រះអង្គម្ចាស់វិជយបាលជាព្រះរាជបុត្រព្រះមហាក្សត្រិយ៍នេះ ទ្រង់យាងទៅបាញ់សត្វក្នុងព្រៃ ។ កាលព្រះអង្គម្ចាស់ទ្រង់យាងដល់អរញ្ញប្រទេស ទ្រង់បានទតឃើញជ្រូកព្រៃមួយ ហើយក៏ទ្រង់ដេញតាមរហូតទៅដល់ព្រៃជ្រៅ ដើម្បីនឹងសម្លាប់នូវជ្រូកព្រៃនោះ ។ ព្រះរាជបរិវារក៏វង្វេងខ្ចាត់ខ្ចាយពីគ្នា មិនដឹងទៅទិសតំបន់ណា ។ ព្រះអង្គម្ចាស់ ដោយទ្រង់ស្រេកព្រះសីតរស ក៏ទ្រង់ខំស្វែងរកទីដែលមានទឹក, ទ្រង់បានជួបប្រទះនូវត្រពាំងមួយ ហើយក៏ទ្រង់ឈប់ដើម្បីនឹងសោយនូវព្រះឧទកៈ ។ ក្នុងពេលនោះទទួលមានខ្លាមួយមកដល់ ។ ព្រះអង្គម្ចាស់វិជយបាលកាលទតយល់នូវខ្លានោះ ទ្រង់ខំឡើងលើវុក្ខជាតិមួយដើម ដែលមានពានរមួយនៅទីនោះ ។ ពានរនោះក៏ក្រាបទូលព្រះរាជបុត្រថា: "សូមព្រះអង្គម្ចាស់ទ្រង់ជ្រាបថានៅទីនេះ ទ្រង់មិនត្រូវខ្លាចអ្វីឡើយ, ទ្រង់ស្តេចមកខាងលើជិតទូលបង្គំជាខ្ញុំចុះ" ។ ព្រះរាជបុត្រក៏ទ្រង់ឡើងទៅលើព្រឹក្សជាតិ តាមពាក្យពានរ ។

(មានត)

# កំណត់ដឹងប្រវត្តិការណ៍

## សុន្ទរកថា

ថ្លែងក្នុងឱកាសពិធីបុណ្យស្រោចទឹកបំរើនព្រះជន្ម នៃសម្តេចព្រះសុធម្មាធិបតីសង្ឃនាយកគណៈធម្មយុត្តិវត្តបទុមវតី ដែលធ្វើឡើងក្រោមព្រះរាជាធិបតីនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង កាលពីព្រឹកថ្ងៃទី ២០ កុម្ភៈ ឆ្នាំ ១៩៥៥

## របស់អាចារ្យវត្តបទុមវតី

---

*សូមព្រះតេជៈដំកល់លើត្បូង*

*សូមព្រះរាជទានក្រាបបង្គំទូល ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង,*

*ទ្រង់, ឯកឧត្តម*

*អស់លោកអ្នកទាំងឡាយ !*

*សម័យនេះ ទូលព្រះបង្គំ ខ្ញុំប្របាទ និងឧបាសកឧបាសិកា ព្រមទាំងព្រះថេរានុត្ថេរ ក្នុងក្រុងភ្នំពេញនិងខេត្តក្រៅ មានព្រះមង្គលទេព្វាចារ្យជាប្រធាន, មានកតវេទិតាធម៌កើតមានឡើងចំពោះសម្តេចព្រះសុធម្មាធិបតីជាសង្ឃនាយកគណៈធម្មយុត្តិ ដែលជាមហាថេរ១អង្គប្រកបដោយគុណសម្បត្តិ, ទាំងមានទឹកព្រះទ័យ ប្រកបដោយខន្តិមេត្តាទកៈ និងសោរច្ចៈស្មោះស្ម័គ្រចំពោះពុទ្ធសាសនា និងពុទ្ធបរិស័ទជានិច្ច ។*

*សម្តេចព្រះសុធម្មាធិបតីអង្គនេះ ជាព្រះសមណៈមួយរូបមានគុណធម៌ដ៏បរិសុទ្ធ ជាមហាស្ចារ្យ ទាំងចរិយាវត្ត ផ្លូវកាយនិងវាចាក៏រៀបរយសមរម្យល្អគួរជាទីគោរព គួរជាទីនមស្ការរបស់បព្វជិតនិងគ្រហស្ថទាំងពួង ។*

គេជាទុក្ខភាពរបស់ព្រះអង្គលោកបែបនេះ មានអាការហាក់បីដូចជាមកចាប់ចុចកន្ត្រាក់ចិត្តចេតសិករបស់ទូលព្រះបង្គំខ្ញុំប្របាទជានិរន្តរ៍ ។ បានជាព្រះថេរានុត្ថេរៈ និងទូលព្រះបង្គំខ្ញុំប្របាទព្រមទាំងឧបាសកឧបាសិកា រួមគំនិតគ្នាជាឯកច្ឆន្ទ ប្រារព្ធធ្វើបុណ្យចំរើនព្រះជន្មព្រះអង្គលោក គឺបន្តព្រះជន្មឲ្យបានឋិតថេរចិរកាលតទៅទៀត ដើម្បីអប់រំគាំទ្រទនូវព្រះពុទ្ធសាសនា និងពុទ្ធបរិស័ទទាំងអស់ ឲ្យបានរុងរឿងចំរើនជោគនាការជាវិបុលភាព ។

បុណ្យអាយុវឌ្ឍនៈនេះ ជាបុណ្យមួយដែលគរុបណ្ឌិតព្រឹទ្ធាចារ្យទាំងឡាយធ្លាប់បដិវត្តន៍មកហើយ ដោយអនុវត្តន៍តាមគម្ពីរ ជិណកាលមាលិនី ទំព័រ២៨បន្ទាត់១២និពន្ធទុកមកថា ក្នុងក្រុងលង្កាទ្វីប មានមហាក្សត្រមួយព្រះអង្គ ទ្រង់ព្រះនាម វសភរាជ ព្រះអង្គមានព្រះរាជឧង្ការសួរហោរាថា ខ្លួនយើងនេះនៅប៉ុន្មានឆ្នាំទៀតនឹងទិវង្គត ។ ហោរាគិតគូរតាមក្បួនហោរាសាស្ត្រក៏ក្រាបទូលថា ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងនៅតែ១២ឆ្នាំទៀតនឹងទិវង្គត ។ ព្រះមហាក្សត្រទ្រង់មានព្រះរាជឧង្ការសួរថា យើងគិតធ្វើដូចម្តេច នឹងបន្តព្រះជន្មឲ្យបានយឺនយូរទៅទៀត? ។ ហោរាក្រាបទូលថា រឿងនេះ គួរសួរព្រះសង្ឃទើបជ្រាបច្បាស់ ។ ព្រះនរបតីទ្រង់មានព្រះរាជឧង្ការសួរព្រះសង្ឃៗថ្វាយព្រះពរថា ហេតុដែលនាំឲ្យចំរើនព្រះជន្មមាន ៦ ប្រការ ឈ្មោះថាអន្តរាយវិមោចនធម៌ ប្រែថា "ធម៌កំចាត់បំបាត់បង់នូវសេចក្តីអន្តរាយ" គឺ:

១ — បរិសាវិទានំ ឲ្យធម្មក្រកសម្រាប់ត្រងទឹក

២ — អាវាសទានំ កសាងអាវាស

៣ — គិលានវត្ថុទានំ ធ្វើគិលានវត្ថុ (ថ្នាំកែរោគ)

៤ — កាតព្វជិណ្ណការិសំ ជួសជុលអាវាសចាស់

៥ — បញ្ចសីលសមាទានំ សមាទាននិច្ចសីល

៦ — ឧបោសថុបវាសោ រក្សាឧបោសថ ។

ព្រះប្រិយមហាក្សត្រទ្រង់ព្យាយាម កសាងធម៌ទាំង ៦ យ៉ាងនេះ ព្រមទាំងវិសាខបូជា ព្រះជន្មាយុរបស់ព្រះអគ្គកវិយវឌ្ឍនាការបាន ៤៤ ឆ្នាំ ទើបទិវង្គត ។

ដោយអំណាចសទ្ធិចេតនារបស់ព្រះថេរានុត្ថេរៈ នឹងទូលព្រះបង្គំ, ខ្ញុំប្របាទព្រមទាំងឧបាសកឧបាសិកា ដែលប្រឹងប្រែងកសាងដោយផ្លូវកាយ - វាចា - ចិត្ត យ៉ាងនេះ សូមប្រគេនបុញ្ញរាសីដែលផុះផុសចេញអំពីសុទ្ធិចេតនាចំពោះសម្តេចជាម្ចាស់ ដែលជាប្រមុខនៃពុទ្ធសាសនិកជនគណៈធម្មយុត្តិកនិកាយ សូមសម្តេចជាម្ចាស់ទទួលអនុមោទនាយកភាគផលនេះ ហើយសូមប្រកបដោយព្រះជន្មាយុយឺនយូរតរៀងទៅ ព្រះទ័យបំណងបែបណា សូមសំរេចតាមប្រាថ្នាសព្វកាលទាំងពួង ។

ម្យ៉ាងទៀតព្រះថេរានុត្ថេរៈទាំងឡាយ នឹងទូលព្រះបង្គំ, ខ្ញុំប្របាទ សូមព្រះរាជទានព្រះបរមរាជឱកាស សូមថ្វាយព្រះរាជកុសលដល់ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង នឹងសម្តេចព្រះបរមរាជបិតា សម្តេច

ព្រះវររាជជននីនាថ ព្រមទាំងព្រះរាជវង្សានុវង្ស សូមទ្រង់ប្រកបដោយព្រះជន្មាយុបរិតថេរចិរកាល សូមព្រះក្សេមសុខក្នុងសិរីរាជសម្បត្តិសព្វទិនទិវារាត្រី ។

នៅទីបំផុតនេះ ដោយអំណាចតេជះនៃពុទ្ធសាសនានឹងតេជះនៃសកលលោក សូមពួកទេវតាទាំងឡាយដែលមានឥទ្ធានុភាពដ៏ធំទូលាយ មេត្តាអភិបាលសម្តេចព្រះសុធម្មាធិបតីសង្ឃនាយកគណធម្មយុត្តិកនិកាយ, ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង សម្តេចព្រះបរមរាជបិតា, សម្តេចព្រះវររាជជននីនាថ នឹងព្រះរាជវង្សានុវង្ស នឹងនាម៉ឺនសព្វមុខមន្ត្រី ព្រមទាំងយើងខ្ញុំទាំងអស់គ្នាកុំបីឃ្លៀងឃ្លាតឡើយ ។

---

## ទោសក្បត់ម្ចាស់ផែនដី

នរជនណា ដែលម្ចាស់បានតែងតាំងក្នុងឋានៈជាមន្ត្រី ហើយៗ ក្បត់ទំលាយការសម្ងាត់នៃម្ចាស់ នរជននោះ នឹងធ្លាក់ទៅនរកដោយខ្លួនឯង ព្រោះហេតុតែបំផ្លាញការងារនៃម្ចាស់នោះឯង ។

មន្ត្រីណា ក្បត់ទំលាយការសម្ងាត់នៃម្ចាស់ផែនដីណា ម្ចាស់ផែនដីនោះ នឹងត្រូវសម្លាប់មន្ត្រីនោះ ដោយមិនបាច់ប្រើអាវុធ នេះជាច្បាប់នៃអ្នកប្រាជ្ញនារទៈ ។

បញ្ចតន្ត្រៈ

# បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី

## របស់ក្រសួងធម្មការ

(តពីវិទ្យុលេខ ១ ឆ្នាំ ១៩៥៥)

---

សញ្ញាប័ត្រលេខ ៩៣២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ស្រី-តាំង នាមឆាយា ឥន្ទត្ថេរ កើតឆ្នាំមមែ អាយុ ៤៣ វស្សា ២០ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩៣៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ គិម-ផាន់ នាមឆាយា នន្ទបញ្ញោ កើតឆ្នាំជូត អាយុ ២៦ វស្សា ២ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩៣៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ព្រាប-ហង់ នាមឆាយា ចន្ទត្ថេរ កើតឆ្នាំមមី អាយុ ៥៦ វស្សា ៣៦ ជាចៅអធិការ វត្តចិញ្ចែង ឃុំដើមកូន ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩៣៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ក៉-តៅ នាមឆាយា សុវណ្ណត្ថេរ កើតឆ្នាំមមែ អាយុ ៥៥ វស្សា ៣៦ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩៣៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សំរិត-ផាន់ នាមឆាយា ធម្មជោត កើតឆ្នាំច អាយុ ២៨ វស្សា ៩ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩៣៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ

សេន-ម៉ុម នាមឆាយា ជោតត្ថេរ កើតឆ្នាំរក អាយុ ៤២ វស្សា ២០ ជាចៅអធិការ វត្តប្រាសាទនាងខ្មៅ ឃុំរវៀង ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៩៣៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សុខ-លុយ នាមឆាយា សុវណ្ណត្ថេរ កើតឆ្នាំកុរ អាយុ ៣៩ វស្សា ២០ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៩៣៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ គង់-ឈួង នាមឆាយា សុវណ្ណជោត កើតឆ្នាំឆ្លូវ អាយុ ៣៧ វស្សា ១៧ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៩៤០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ហ៊ិន-ចេង នាមឆាយា សុធម្មត្ថេរ កើតឆ្នាំរកា អាយុ ៤១ វស្សា ១៩ ជាចៅអធិការ វត្តដើមគួន ឃុំដើមគួន ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៩៤១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ុក-នន់ នាមឆាយា ឥន្ទជោត កើតឆ្នាំរកា អាយុ ៦៥ វស្សា ១៦ ជាគ្រូសូត្រឆ្វេង វត្តស្វារម ឃុំរវៀង ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៩៤២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ី-មាច នាមឆាយា ឥន្ទបញ្ញា កើតឆ្នាំកុរ អាយុ ៣៩ វស្សា ២០ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខែត្រដដែល ។

(មានត)